ចំពោះបេក្ខជន ដែលស្នើតែងតាំងត្រូវជ្រើសចេញពីមន្ត្រីរាជការស៊ីវិលក្របខ័ណ្ឌក្រសួងមហាផ្ទៃ ដែលបំពេញការងារនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ និងឧបនិស្ស័យ ដូចបានកំណត់ដោយលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល។ ក្នុងករណីដែលពុំអាចជ្រើសរើសបាននូវបេក្ខជនសមស្រប អភិបាលរាជធានី ខេត្ត បន្ទាប់ពីមានការឯកភាពពីគណៈអភិបាល និងក្រុមប្រឹក្សារបស់ខ្លួន ត្រូវស្នើសុំយោបល់ពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីស្នើសុំផ្ទេរមន្ត្រីមកពីក្រសួងមហាផ្ទៃ ឬពីសាលារាជធានី ខេត្តផ្សេង ឬពីក្របខ័ណ្ឌក្រសួង ស្ថាប័នផ្សេងទៀតតាមនីតិវិធីជាធរមាន។

ក្នុងករណីតម្រូវឲ្យមានការផ្លាស់ប្តូរ ឬបញ្ចប់ការកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងដូចមានចែងក្នុងវាក្យខ័ណ្ឌទី១នៃមាត្រានេះ អភិបាលរាជធានី ខេត្តត្រូវធ្វើការប្រជុំឲ្យមានការឯកភាពគ្នាក្នុងគណៈអភិបាលរបស់ខ្លួនអំពីមូលហេតុជាក់លាក់នៃការស្នើសុំផ្លាស់ប្តូរ ឬបញ្ចប់ការកិច្ចនេះ ដើម្បីស្នើសុំការអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន មុននឹងចេញដីកាផ្លាស់ប្តូរ ឬបញ្ចប់ការកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងនេះ។

មាត្រា ៨ .-

ត្រូវបានធ្វើប្រតិភូកម្មអំណាចដល់អភិបាលរាជធានី ខេត្តឲ្យចេញដីកាតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ការកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងនាយកទីចាត់ការហិរញ្ញវត្ថុនៃសាលារាជធានី ខេត្ត។

អភិបាលរាជធានី ខេត្ត ដោយមានការឯកភាពពីគណៈអភិបាលរបស់ខ្លួន ត្រូវលើកសំណើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ការកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងនេះមកក្រុមប្រឹក្សារបស់ខ្លួនដើម្បីពិនិត្យនិងសម្រេច។

បន្ទាប់ពីទទួលបានការសម្រេចពីក្រុមប្រឹក្សារបស់ខ្លួន អភិបាលរាជធានី ខេត្តត្រូវលើកសំណើនេះមករដ្ឋមន្ត្រីក្រសួងមហាផ្ទៃដើម្បីពិនិត្យ និងពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីផ្តល់ការឯកភាពលើសំណើនេះ។

ផ្អែកលើការឯកភាពខាងលើនេះ អភិបាលរាជធានី ខេត្ត ត្រូវចេញដីកាតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ការកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងនេះ។ ក្នុងករណីដែលពុំមានការឯកភាព រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវជូនដំណឹងទៅអភិបាលរាជធានី ខេត្ត ដោយបញ្ជាក់អំពីហេតុផលនៃការពុំឯកភាពនេះ និង/ឬស្នើឲ្យអភិបាលរាជធានី ខេត្ត លើកសំណើបេក្ខជនថ្មីសម្រាប់ការតែងតាំងមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងនេះ តាមនីតិវិធីដូចបានកំណត់ក្នុងវាក្យខ័ណ្ឌនានាខាងលើនៃមាត្រានេះ។

ក្នុងករណីតម្រូវឲ្យមានការផ្លាស់ប្តូរ ឬបញ្ចប់ការកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងដូចមានចែងក្នុងវាក្យខ័ណ្ឌទី១នៃមាត្រានេះ អភិបាលរាជធានី ខេត្ត ត្រូវធ្វើការប្រជុំពិភាក្សាឲ្យមានការឯកភាពគ្នាក្នុង

គណៈអភិបាលរបស់ខ្លួនអំពីមូលហេតុជាក់លាក់នៃការស្នើសុំផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចនេះ ដើម្បីស្នើសុំការអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន មុននឹងលើកសំណើជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដើម្បីពិនិត្យ និងពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចចាត់ឲ្យមានការស៊ើបអង្កេតជាមុនចំពោះមូលហេតុដែលស្នើសុំឲ្យមានការផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចនេះ។ ក្នុងករណីការស៊ើបអង្កេតរកឃើញថា សំណើនេះពុំមានមូលហេតុសមស្រប រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើលិខិតជម្រាបជូនអភិបាលរាជធានី ខេត្តអំពីការមិនគាំទ្រចំពោះសំណើសុំផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីនេះ។

មាត្រា ៥ .-

ត្រូវបានធ្វើប្រតិកូកម្មអំណាចដល់អភិបាលរាជធានី ខេត្តឲ្យចេញដីការតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងចាប់ពីថ្នាក់ក្រោមនាយករដ្ឋបាលនៃសាលាក្រុង ស្រុក ខណ្ឌ។

អភិបាលក្រុង ស្រុក ខណ្ឌ ដោយមានការឯកភាពពីគណៈអភិបាលរបស់ខ្លួន ត្រូវលើកសំណើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងខាងលើទៅក្រុមប្រឹក្សារបស់ខ្លួនដើម្បីពិនិត្យ និងអនុម័ត មុននឹងលើកសំណើជូនអភិបាលរាជធានី ខេត្តសាមី។

ចំពោះបេក្ខជនដែលស្នើតែងតាំង ត្រូវជ្រើសចេញពីមន្ត្រីរាជការស៊ីវិលក្របខ័ណ្ឌក្រសួងមហាផ្ទៃដែលបំពេញការងារនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ និងឧបនិស្ស័យដូចបានកំណត់ដោយលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល។ ក្នុងករណីដែលក្រុង ស្រុក ខណ្ឌពុំមានមន្ត្រីដែលមានលក្ខណៈវិនិច្ឆ័យ និងឧបនិស្ស័យសមស្របសម្រាប់ការស្នើសុំតែងតាំងក្នុងមុខតំណែងទាំងនេះទេនោះ អភិបាលក្រុង ស្រុក ខណ្ឌ ដោយមានការឯកភាពពីគណៈអភិបាល និងក្រុមប្រឹក្សារបស់ខ្លួន អាចស្នើសុំយោបល់ពីអភិបាលរាជធានី ខេត្ត ដើម្បីជ្រើសរើសបេក្ខជនដែលមានលក្ខណៈសមស្របពីសាលារាជធានី ខេត្ត ឬពីសាលាក្រុង ស្រុក ខណ្ឌផ្សេងទៀត ឬស្នើសុំផ្ទេរមន្ត្រីពីក្របខ័ណ្ឌក្រសួង ស្ថាប័នផ្សេងទៀតតាមនីតិវិធីជាធរមាន។

ផ្អែកតាមសំណើរបស់អភិបាលក្រុង ស្រុក ខណ្ឌ អភិបាលរាជធានី ខេត្តត្រូវពិនិត្យអំពីលក្ខណៈវិនិច្ឆ័យ និងឧបនិស្ស័យរបស់មន្ត្រីដែលត្រូវបានស្នើតែងតាំងដោយផ្អែកតាមការកំណត់នៃលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល។ ករណីបេក្ខជនដែលស្នើសុំតែងតាំងនោះពុំសមស្របនឹងលក្ខណៈវិនិច្ឆ័យ និងឧបនិស្ស័យដែលបានកំណត់ អភិបាលរាជធានី ខេត្ត ត្រូវធ្វើលិខិតជម្រាបជូនអភិបាលក្រុង ស្រុក ខណ្ឌ ដើម្បីជ្រើសរើសបេក្ខជនថ្មីដែលមានលក្ខណៈវិនិច្ឆ័យ និងឧបនិស្ស័យសមស្របមកជំនួស។ អភិបាលក្រុង ស្រុក ខណ្ឌសាមី ត្រូវធ្វើការប្រជុំពិភាក្សាឲ្យមានការឯកភាពគ្នាក្នុងគណៈអភិបាល និងស្នើសុំការអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន មុននឹងលើកសំណើបេក្ខជនថ្មីនេះជូនអភិបាលរាជធានី ខេត្ត។

ក្នុងករណីតម្រូវឲ្យមានការផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងដូចមានចែងក្នុងវាក្យខ័ណ្ឌទី១នៃមាត្រានេះ អភិបាលក្រុង ស្រុក ខណ្ឌត្រូវធ្វើការប្រជុំពិភាក្សាឲ្យមានការឯកភាពគ្នាក្នុងគណៈអភិបាល និងសុំការអនុម័តពីក្រុមប្រឹក្សារបស់ខ្លួនអំពីមូលហេតុជាក់លាក់នៃការស្នើសុំផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចនេះ ដើម្បីលើកសំណើជូនអភិបាលរាជធានី ខេត្តសាមី។ ក្នុងករណីចាំបាច់ អភិបាល

រាជធានី ខេត្ត អាចចាត់ឲ្យមានការស៊ើបអង្កេតជាមុនចំពោះមូលហេតុដែលស្នើសុំឲ្យមានការផ្លាស់ប្តូរ ឬបញ្ចប់ការកិច្ចនេះ។ ក្នុងករណីការស៊ើបអង្កេតរកឃើញថា សំណើនេះពុំមានមូលហេតុសមស្រប អភិបាលរាជធានី ខេត្ត ត្រូវធ្វើលិខិតជម្រាបជូនអភិបាលក្រុង ស្រុក ខណ្ឌអំពីការមិនគាំទ្រចំពោះសំណើសុំផ្លាស់ប្តូរ ឬបញ្ចប់ការកិច្ចមន្ត្រីនេះ។ ក្នុងករណីការស្នើសុំនេះមានមូលហេតុជាក់លាក់ អភិបាលរាជធានី ខេត្ត ត្រូវចេញដីកាផ្លាស់ប្តូរ ឬបញ្ចប់ការកិច្ចមន្ត្រីនោះតាមការស្នើសុំ។

មាត្រា ១០ ៖-

ត្រូវបានធ្វើប្រតិភូកម្មអំណាចដល់អភិបាលរាជធានី ខេត្តឲ្យចេញដីកាតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ការកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុនៃសាលាក្រុង ស្រុក ខណ្ឌ។

អភិបាលក្រុង ស្រុក ខណ្ឌ ដោយមានការឯកភាពពីគណៈអភិបាលរបស់ខ្លួន ត្រូវលើកសំណើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ការកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងនេះ មកក្រុមប្រឹក្សារបស់ខ្លួនដើម្បីពិនិត្យ និងសម្រេច។

បន្ទាប់ពីទទួលបានការសម្រេចពីក្រុមប្រឹក្សារបស់ខ្លួន អភិបាលក្រុង ស្រុក ខណ្ឌត្រូវលើកសំណើនេះ មកអភិបាលរាជធានី ខេត្តសាមី ដើម្បីលើកសំណើជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដើម្បីពិនិត្យ និងពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងការផ្តល់ការឯកភាពលើសំណើនេះ។

ផ្អែកលើការឯកភាពខាងលើនេះ អភិបាលរាជធានី ខេត្ត ត្រូវចេញដីកាតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ការកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងនេះ។ ក្នុងករណីដែលពុំមានការឯកភាព រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវជូនដំណឹងទៅអភិបាលរាជធានី ខេត្តដោយបញ្ជាក់អំពីហេតុផលនៃការពុំឯកភាពនេះ និង/ឬស្នើឲ្យអភិបាលរាជធានី ខេត្តសាមីពិភាក្សាជាមួយអភិបាលក្រុង ស្រុក ខណ្ឌសាមីក្នុងការលើកសំណើបេក្ខជនថ្មីសម្រាប់ការតែងតាំងមន្ត្រីក្នុងមុខតំណែងនេះ តាមនីតិវិធីដូចបានកំណត់ក្នុងវាក្យខ័ណ្ឌខាងលើនៃមាត្រានេះ។

ក្នុងករណីតម្រូវឲ្យមានការផ្លាស់ប្តូរ ឬបញ្ចប់ការកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងដូចមានចែងក្នុងវាក្យខ័ណ្ឌទី១នៃមាត្រានេះ អភិបាលក្រុង ស្រុក ខណ្ឌត្រូវធ្វើការប្រជុំពិភាក្សាឲ្យមានការឯកភាពគ្នាក្នុងគណៈអភិបាលរបស់ខ្លួនអំពីមូលហេតុជាក់លាក់នៃការស្នើសុំផ្លាស់ប្តូរ ឬបញ្ចប់ការកិច្ចនេះ ដើម្បីស្នើសុំការអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន មុននឹងលើកសំណើជូនអភិបាលរាជធានី ខេត្តសាមី។

ក្នុងករណីចាំបាច់អភិបាលរាជធានី ខេត្ត អាចចាត់ឲ្យមានការស៊ើបអង្កេតជាមុនចំពោះមូលហេតុនៃការស្នើសុំឲ្យមានការផ្លាស់ប្តូរ ឬបញ្ចប់ការកិច្ចនេះ។ ក្នុងករណីការស៊ើបអង្កេតរកឃើញថា សំណើនេះពុំមានមូលហេតុសមស្រប អភិបាលរាជធានី ខេត្ត ត្រូវធ្វើលិខិតជម្រាបជូនអភិបាលក្រុង ស្រុក ខណ្ឌសាមីអំពីការមិនគាំទ្រចំពោះសំណើសុំផ្លាស់ប្តូរ ឬបញ្ចប់ការកិច្ចមន្ត្រីនេះ។

ក្នុងករណីគណៈអភិបាលរាជធានី ខេត្តឯកភាពលើសំណើសុំផ្លាស់ប្តូរ និងបញ្ចប់ការកិច្ចនេះ អភិបាលរាជធានី ខេត្ត ត្រូវលើកសំណើជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដើម្បីពិនិត្យ និងពិគ្រោះយោបល់ជាមួយ

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីផ្តល់ការឯកភាពលើសំណើនេះ មុននឹងចេញដីកាផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីក្នុងមុខតំណែងនេះតាមនីតិវិធីជាធរមាន។

ផ្នែកទី២

មន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅតាមមន្ទីរ អង្គភាព និងការិយាល័យរបស់ក្រសួង ស្ថាប័ននានានៅថ្នាក់ក្រោមជាតិ

មាត្រា ១១ .–

ត្រូវបានធ្វើប្រតិភូកម្មអំណាចដល់អភិបាលរាជធានី ខេត្តឲ្យមានសិទ្ធិលើកសំណើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌក្រសួង ស្ថាប័ននានាក្នុងមុខតំណែងប្រធានមន្ទីរ ឬអង្គភាពថ្នាក់ប្រហាក់ប្រហែលនៅថ្នាក់រាជធានី ខេត្តមករដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីនីមួយៗ។

អភិបាលរាជធានី ខេត្ត ដោយមានការឯកភាពពីគណៈអភិបាល និងក្រុមប្រឹក្សារបស់ខ្លួនត្រូវលើកសំណើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងដូចមានចែងក្នុងវាក្យខ័ណ្ឌទី១ នៃមាត្រានេះ ដើម្បីសុំការសម្រេចពីរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី។

ចំពោះបេក្ខជនដែលស្នើតែងតាំង ត្រូវជ្រើសចេញពីមន្ត្រីរាជការស៊ីវិលក្របខ័ណ្ឌក្រសួង ស្ថាប័នសាមីនីមួយៗដែលកំពុងបំពេញការងារនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ដោយផ្អែកលើលក្ខណៈនិច្ឆ័យ និងឧបនិស្ស័យដូចបានកំណត់ដោយលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល។ ក្នុងករណីដែលពុំអាចជ្រើសរើសបាននូវបេក្ខជនសមស្រប អភិបាលរាជធានី ខេត្ត ដោយមានការឯកភាពពីគណៈអភិបាល និងក្រុមប្រឹក្សារបស់ខ្លួនត្រូវស្នើសុំយោបល់ពីរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីដើម្បីផ្ទេរមន្ត្រីមកពីក្រសួង ស្ថាប័នសាមី ឬពីមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័នសាមីនៅរាជធានី ខេត្តផ្សេង ឬពីក្របខ័ណ្ឌក្រសួង ស្ថាប័នផ្សេងទៀតតាមនីតិវិធីជាធរមាន។

ក្នុងករណីតម្រូវឲ្យមានការផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងដូចមានចែងក្នុងវាក្យខ័ណ្ឌទី១នៃមាត្រានេះ អភិបាលរាជធានី ខេត្ត ត្រូវធ្វើការប្រជុំពិភាក្សាឲ្យមានការឯកភាពគ្នាក្នុងគណៈអភិបាលរបស់ខ្លួនអំពីមូលហេតុជាក់លាក់នៃការស្នើសុំផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចនេះ ដើម្បីស្នើសុំការអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន មុននឹងលើកសំណើជូនរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី អាចចាត់ឲ្យមានការស៊ើបអង្កេតជាមុនចំពោះមូលហេតុដែលស្នើសុំឲ្យមានការផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចនេះ។ ក្នុងករណីការស៊ើបអង្កេតរកឃើញថាសំណើនេះពុំមានមូលហេតុសមស្រប រដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី ត្រូវធ្វើលិខិតជម្រាបជូនអភិបាលរាជធានី ខេត្តអំពីការមិនគាំទ្រចំពោះសំណើសុំផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីនេះ។ ក្នុងករណីការស្នើសុំនេះមានមូលហេតុជាក់លាក់ រដ្ឋមន្ត្រី ឬប្រធានស្ថាប័ននោះ ត្រូវចេញប្រកាសផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីនោះតាមការស្នើសុំ។

មាត្រា ១២ .-

ត្រូវបានធ្វើប្រតិភូកម្មអំណាចដល់អភិបាលរាជធានី ខេត្តឲ្យចេញដីកាតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ការកិច្ចមន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌក្រសួង ស្ថាប័ននានាក្នុងមុខតំណែងចាប់ពីថ្នាក់ក្រោមប្រធានមន្ទីរ ឬអង្គភាពថ្នាក់ប្រហាក់ប្រហែលនៅថ្នាក់រាជធានី ខេត្ត។

ប្រធានមន្ទីរ អង្គភាពសាមី ត្រូវលើកសំណើសម្រាប់ការតែងតាំង ឬការផ្លាស់ប្តូរ ឬការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងទាំងនេះមកអភិបាលរាជធានី ខេត្ត។ អភិបាលរាជធានី ខេត្ត ត្រូវយកសំណើនេះមកពិនិត្យ និងពិភាក្សាឲ្យមានការឯកភាពគ្នានៅក្នុងគណៈអភិបាល និងស្នើសុំការអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន មុននឹងចេញដីកាតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីក្នុងមុខតំណែងទាំងនេះតាមនីតិវិធីជាធរមាន។

ចំពោះបេក្ខជនដែលស្នើតែងតាំង ត្រូវជ្រើសចេញពីមន្ត្រីរាជការស៊ីវិលក្របខ័ណ្ឌក្រសួង ស្ថាប័នសាមីនីមួយៗដែលកំពុងបំពេញការងារនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ដោយផ្អែកលើលក្ខណៈនិច្ឆ័យ និងឧបនិស្ស័យដូចបានកំណត់ដោយលក្ខន្តិក:ដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល។ ក្នុងករណីដែលពុំអាចជ្រើសរើសបាននូវបេក្ខជនសមស្រប អភិបាលរាជធានី ខេត្តរួមជាមួយនឹងប្រធានមន្ទីរ អង្គភាពសាមីដោយមានការឯកភាពពីគណៈអភិបាល និងក្រុមប្រឹក្សារាជធានី ខេត្តសាមីអាចស្នើសុំយោបល់ពីរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី ដើម្បីផ្ទេរមន្ត្រីមកពីក្រសួង ស្ថាប័នសាមី ឬពីមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័នសាមីនៅរាជធានី ខេត្តផ្សេង ឬពីក្របខ័ណ្ឌក្រសួង ស្ថាប័នផ្សេងទៀតតាមនីតិវិធីជាធរមាន។

ក្នុងករណីតម្រូវឲ្យមានការផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងដូចមានចែងក្នុងវាក្យខ័ណ្ឌទី១នៃមាត្រានេះ ប្រធានមន្ទីរ អង្គភាពសាមីត្រូវបញ្ជាក់អំពីមូលហេតុជាក់លាក់នៃការស្នើសុំផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចនេះ ដើម្បីលើកសំណើជូនអភិបាលរាជធានី ខេត្តសាមី។

ក្នុងករណីចាំបាច់ អភិបាលរាជធានី ខេត្តអាចចាត់ឲ្យមានការស៊ើបអង្កេតជាមុនចំពោះមូលហេតុដែលស្នើសុំឲ្យមានការផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចនេះ។ ក្នុងករណីការស៊ើបអង្កេតរកឃើញថា សំណើនេះពុំមានមូលហេតុសមស្រប អភិបាលរាជធានី ខេត្ត ដោយមានការឯកភាពពីគណៈអភិបាល និងក្រុមប្រឹក្សារបស់ខ្លួន ត្រូវធ្វើលិខិតជម្រាបជូនប្រធានមន្ទីរ អង្គភាពសាមីអំពីការមិនគាំទ្រចំពោះសំណើសុំផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីនេះ។

ក្នុងករណីការស្នើសុំនេះមានមូលហេតុជាក់លាក់ អភិបាលរាជធានី ខេត្តដោយមានការឯកភាពពីគណៈអភិបាលត្រូវស្នើសុំការអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន មុននឹងចេញដីកាផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីនោះ។

ក្នុងករណីដែលមន្ត្រីណាមួយក្នុងមុខតំណែងទាំងនេះ ត្រូវបានរកឃើញថាមានភាពមិនប្រក្រតី ឬការប្រព្រឹត្តខុសឆ្គងមានលក្ខណៈធ្ងន់ធ្ងរ ឬតាមតម្រូវនៃច្បាប់ អភិបាលរាជធានី ខេត្ត ដោយមានការឯកភាពពីគណៈអភិបាល និងក្រុមប្រឹក្សារបស់ខ្លួនត្រូវផ្តល់ការណែនាំដល់ប្រធានមន្ទីរ អង្គភាពសាមី ដើម្បីលើក

សំណើផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមកអភិបាលរាជធានី ខេត្ត។ ក្នុងករណីដែលប្រធានមន្ទីរ អង្គភាពសាមីនោះពុំអនុវត្តតាមការណែនាំនេះទេ អភិបាលរាជធានី ខេត្ត ដោយមានការឯកភាពពីគណៈអភិបាល និងក្រុមប្រឹក្សារបស់ខ្លួនអាចមានសិទ្ធិផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីក្នុងមុខតំណែងនេះ ដោយពុំចាំបាច់មានសំណើពីប្រធានមន្ទីរ អង្គភាពសាមីនោះឡើយ។

មាត្រា ១៣ .-

ត្រូវបានធ្វើប្រតិភូកម្មអំណាចដល់អភិបាលរាជធានី ខេត្តឲ្យចេញដីកាតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌក្រសួង ស្ថាប័ននានាក្នុងមុខតំណែងចាប់ពីថ្នាក់ប្រធានការិយាល័យជំនាញ ឬថ្នាក់ប្រហាក់ប្រហែលចុះក្រោមនៅថ្នាក់ក្រុង ស្រុក ខណ្ឌ។

អភិបាលក្រុង ស្រុក ខណ្ឌដោយមានការឯកភាពពីគណៈអភិបាលរបស់ខ្លួន ត្រូវស្នើសុំការអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន មុននឹងលើកសំណើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងទាំងនេះមកអភិបាលរាជធានី ខេត្ត តាមរយៈប្រធានមន្ទីរ អង្គភាពសាមី។

ចំពោះសំណើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងចាប់ពីថ្នាក់ក្រោមប្រធានការិយាល័យជំនាញ ឬថ្នាក់ប្រហាក់ប្រហែលនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវមានការពិគ្រោះយោបល់បន្ថែមជាមួយប្រធានការិយាល័យជំនាញសាមី។

ផ្អែកលើសំណើរបស់អភិបាលក្រុង ស្រុក ខណ្ឌ និងមតិយោបល់របស់ប្រធានមន្ទីរ អង្គភាពសាមី អភិបាលរាជធានី ខេត្ត ត្រូវយកសំណើនេះមកពិនិត្យ និងពិភាក្សាឲ្យមានការឯកភាពគ្នានៅក្នុងគណៈអភិបាលរបស់ខ្លួន មុននឹងចេញដីកាតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីក្នុងមុខតំណែងទាំងនេះតាមនីតិវិធីជាធរមាន។

ចំពោះបេក្ខជនដែលស្នើតែងតាំងនេះ ត្រូវជ្រើសចេញពីមន្ត្រីរាជការស៊ីវិលក្របខ័ណ្ឌក្រសួង ស្ថាប័នសាមីនីមួយៗដែលកំពុងបំពេញការងារនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ និងឧបនិស្ស័យដូចបានកំណត់ដោយលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល។ ក្នុងករណីដែលពុំអាចជ្រើសរើសបាននូវបេក្ខជនសមស្របនេះទេ អភិបាលក្រុង ស្រុក ខណ្ឌ ដោយមានការឯកភាពពីគណៈអភិបាល និងក្រុមប្រឹក្សារបស់ខ្លួន ត្រូវស្នើសុំយោបល់ពីអភិបាលរាជធានី ខេត្ត ដើម្បីសម្របសម្រួលជាមួយប្រធានមន្ទីរ អង្គភាពសាមីក្នុងការស្នើសុំផ្ទេរមន្ត្រីមកពីក្រសួងស្ថាប័ន ឬពីមន្ទីរ អង្គភាពជំនាញនៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌផ្សេង ឬពីក្របខ័ណ្ឌក្រសួង ស្ថាប័នផ្សេងទៀតតាមនីតិវិធីជាធរមាន។

ក្នុងករណីតម្រូវឲ្យមានការផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងដូចមានចែងក្នុងវាក្យខ័ណ្ឌទី១នៃមាត្រានេះ អភិបាលក្រុង ស្រុក ខណ្ឌសាមីដោយមានការឯកភាពពីគណៈអភិបាលនិងក្រុមប្រឹក្សារបស់ខ្លួនត្រូវបញ្ជាក់អំពីមូលហេតុជាក់លាក់នៃការស្នើសុំផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចនេះ ដើម្បីលើកសំណើជូនអភិបាលរាជធានី ខេត្តសាមី តាមរយៈប្រធានមន្ទីរ អង្គភាពសាមី។

ក្នុងករណីចាំបាច់ អភិបាលរាជធានី ខេត្ត អាចចាត់ឲ្យមានការស៊ើបអង្កេតជាមុនចំពោះមូលហេតុដែលស្នើឲ្យមានការផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចនេះ។ ក្នុងករណីការស៊ើបអង្កេតរកឃើញថា សំណើនេះពុំមានមូលហេតុសមស្រប អភិបាលរាជធានី ខេត្ត ដោយមានការឯកភាពពីគណៈអភិបាល ត្រូវធ្វើលិខិតជម្រាបជូនអភិបាលក្រុង ស្រុក ខណ្ឌសាមីអំពីការមិនគាំទ្រចំពោះសំណើសុំផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីនេះ។

ក្នុងករណីការស្នើសុំនេះមានមូលហេតុជាក់លាក់ អភិបាលរាជធានី ខេត្តដោយមានការឯកភាពពីគណៈអភិបាលរាជធានី ខេត្ត ត្រូវចេញដីកាផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីនោះតាមការស្នើសុំ។

មាត្រា ១៤ ៖-

ចំពោះការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលនៃអង្គភាពរបស់ក្រសួងស្ថាប័ន ដែលមានមុខងារផ្តល់សេវាគ្របដណ្តប់លើវិសាលភាពដែនដីនៃរដ្ឋបាលថ្នាក់ក្រោមជាតិលើសពីមួយ អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌដែលអង្គភាពនោះមានការិយាល័យតាំងនៅក្នុងដែនដីរដ្ឋបាលរបស់ខ្លួន និងប្រធានអង្គភាពសាមី ត្រូវអនុវត្តតាមនីតិវិធីនានាដូចបានកំណត់នៅក្នុងមាត្រា១១ មាត្រា ១២ និងមាត្រា១៣នៃអនុក្រឹត្យនេះ ដោយមានការពិគ្រោះយោបល់ជាមួយនឹងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌដែលពាក់ព័ន្ធ។

មាត្រា ១៥ ៖-

ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់ក្រោមជាតិក្នុងមុខតំណែងផ្សេងទៀតដែលពុំបានចែងនៅក្នុងមាត្រា៧ មាត្រា៨ មាត្រា៩ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៣ និងមាត្រា១៤នៃអនុក្រឹត្យនេះ ត្រូវអនុវត្តដោយអនុលោមតាមច្បាប់ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

ជំពូកទី៤
ការតាមដាន ការត្រួតពិនិត្យ ការវាយតម្លៃ និងការគាំទ្រ

មាត្រា ១៦ ៖-

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) និងក្រសួងមុខងារសាធារណៈ ត្រូវសម្របសម្រួលជាមួយក្រសួង ស្ថាប័ននានាដើម្បីរៀបចំនូវយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តអំណាចដែលបានធ្វើប្រតិភូកម្មតាមស្មារតីនៃអនុក្រឹត្យនេះ ដើម្បីធានាថា ក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ថ្នាក់អនុវត្តអំណាចក្នុងការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីដោយអនុលោមទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន និងធានាឲ្យបាននូវគោលការណ៍ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព សមធម៌ និងអព្យាក្រឹតភាពនៃមន្ត្រីរាជការស៊ីវិល។

គ.ជ.អ.ប. ត្រូវធ្វើសេចក្តីរាយការណ៍ជូនរាជរដ្ឋាភិបាលរៀងរាល់ ០៦ខែម្តងៗអំពីការអនុវត្តអនុក្រឹត្យនេះ។

មាត្រា ១៧ ៖-

អភិបាលរាជធានី ខេត្ត ត្រូវបញ្ជូនដីកាតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលតាមគោលការណ៍នៃអនុក្រឹត្យនេះមកក្រសួងមុខងារសាធារណៈ និងរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីរបស់មន្ត្រីដែលបានតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចក្នុងរយៈពេលយ៉ាងយូរ ១៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីថ្ងៃតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ច ដើម្បីពិនិត្យនីត្យានុកូលភាព និងបំពេញបែបបទពាក់ព័ន្ធនឹងប្រាក់បៀវត្ស ប្រាក់បំណាច់មុខងារ ការងារក្របខ័ណ្ឌ និងការធានាការអនុវត្តតាមនីតិវិធីជាធរមាន។

ក្នុងការពិនិត្យនីត្យានុកូលភាព ប្រសិនបើពិនិត្យឃើញថា ការតែងតាំង ឬការផ្លាស់ប្តូរ ឬការបញ្ចប់ភារកិច្ចនេះធ្វើឡើងមិនត្រឹមត្រូវតាមគោលការណ៍ បែបបទ និងនីតិវិធីជាធរមាន រដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីត្រូវធ្វើលិខិតណែនាំដល់រដ្ឋបាលថ្នាក់ក្រោមជាតិនោះឲ្យធ្វើការកែតម្រូវឲ្យបានត្រឹមត្រូវឡើងវិញ។

ករណីរដ្ឋបាលថ្នាក់ក្រោមជាតិណាមួយមិនអនុវត្តតាមការណែនាំនេះ រដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី ត្រូវធ្វើអន្តរាគមន៍ដោយចេញប្រកាសលុបចោលដីកាដែលធ្វើឡើងមិនត្រឹមត្រូវតាមគោលការណ៍ បែបបទ និងនីតិវិធីជាធរមាននោះជាបន្ទាន់។

មាត្រា ១៨ ៖-

ក្នុងការអនុវត្តអំណាចប្រតិភូកម្មតាមស្មារតីនៃអនុក្រឹត្យនេះ ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវធ្វើការបណ្តុះបណ្តាលកសាងសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីអនុវត្តឲ្យបានត្រឹមត្រូវតាមច្បាប់ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលរបស់ក្រសួង ស្ថាប័ននានាដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រី ឬប្រធានស្ថាប័នពាក់ព័ន្ធ អាចពិគ្រោះយោបល់ជាមួយ គ.ជ.អ.ប. ដើម្បីចេញសេចក្តីណែនាំបន្ថែមតាមការចាំបាច់។

ជំពូកទី៥
អន្តរប្បញ្ញត្តិ

មាត្រា ១៩ ៖-

មន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ ដែលត្រូវបានតែងតាំងក្នុងមុខតំណែងណាមួយនៅមុនពេលអនុក្រឹត្យនេះចូលជាធរមាន ត្រូវបន្តស្ថិតក្នុងមុខតំណែង និងបំពេញការងាររហូតដល់មានតម្រូវការនៃការផ្លាស់ប្តូរ ឬការបញ្ចប់ភារកិច្ចក្នុងមុខតំណែងនោះ។

ជំពូកទី៦
អវសានប្បញ្ញត្តិ

មាត្រា ២០ ៖-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ២១ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
សូមមេត្តាចុះហត្ថលេខា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប.

ស ខេង

កន្លែងទទួល
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា២១*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

ឆ្នាំទី១៤ លេខ ៨៧ សប្តាហ៍ទី ៤ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៤ រាជកិច្ច ទំព័រ ១០៨៥១

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: [illegible]

អនុក្រឹត្យ

ស្តីពី

ការព្រឿសរើស ការត្រប់ត្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើស ដោយក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាត

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១៧១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីមូលនិធិឃុំ សង្កាត់
- អនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការធ្វើវិមជ្ឈការអំណាចតួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់
- អនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ ២១៩ អនក្រ.បក ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលនៃរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិក្រុង ស្រុក
- បានឃើញអនុក្រឹត្យលេខ ១៧២ អនក្រ.បក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក
- យោងតាមសំណើប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

សម្រេច

ជំពូកទី១

បទបញ្ញត្តិទូទៅ

មាត្រា ១.-

អនុក្រឹត្យនេះ មានគោលបំណងលើកកម្ពស់ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការប្រើប្រាស់នូវសិទ្ធិអំណាចរបស់ខ្លួន សម្រាប់អនុវត្តមុខងារជាជម្រើសរបស់ខ្លួន សំដៅលើកកម្ពស់ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន ប្រកបដោយគណនេយ្យភាព តម្លាភាព ប្រសិទ្ធភាព និងសមធម៌ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងវិធីនសមត្ថកិច្ចរបស់ខ្លួន។

មាត្រា ២.-

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពីគោលការណ៍ នីតិវិធី និងធនធានសម្រាប់ការគ្រប់គ្រងការចាត់ចែង និងការអនុវត្តនូវមុខងារជាជម្រើសរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

មាត្រា ៣.-

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តនៅគ្រប់ថ្នាក់រដ្ឋបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការជ្រើសរើស ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើសទាំងឡាយណា ដែលមិនស្ថិតនៅក្រោមអាណត្តិនៃក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាល ឬមុខងារទាំងឡាយដែលស្ថិតនៅក្រោមអាណត្តិរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា ហើយក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានាពុំជំទាស់ចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការជ្រើសរើស និងអនុវត្តនូវមុខងារទាំងនោះ។

អនុក្រឹត្យនេះ មិនគ្របដណ្តប់ទៅលើមុខងារជាជម្រើសដែលរដ្ឋបាលថ្នាក់ក្រោមជាតិបន្តគ្រប់គ្រង ចាត់ចែង និងអនុវត្តបន្តពីក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាល បន្ទាប់ពីក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលបានផ្ទេរមុខងារទាំងនេះឱ្យក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិឡើយ។

មាត្រា ៤.-

វាក្យសព្ទនៅក្នុងអនុក្រឹត្យនេះមានន័យដូចតទៅ ៖

- **មុខងារ** សំដៅដល់អំពើ ឬសកម្មភាពដែលរាប់បញ្ចូលទាំងការផ្តល់សេវាសាធារណៈ ហេដ្ឋារចនាសម្ព័ន្ធ និងមធ្យោបាយផ្សេងៗទៀត។
- **មុខងារជាជម្រើស** សំដៅដល់មុខងារទាំងឡាយដែលផ្តួចផ្តើមជ្រើសរើសដោយក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ នៅក្នុងក្របខ័ណ្ឌនៃអនុក្រឹត្យនេះ។ មុខងារជាជម្រើសរួមមាន ៖
  + មុខងារទាំងឡាយដែលមិនស្ថិតនៅក្រោមអាណត្តិនៃក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាល និង
  + មុខងារទាំងឡាយដែលស្ថិតនៅក្រោមអាណត្តិរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាល ប៉ុន្តែក្រសួង ស្ថាប័ន មន្ទីរ អង្គភាពពាក់ព័ន្ធពុំជំទាស់ចំពោះក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការជ្រើសរើស និងការអនុវត្តនូវមុខងារទាំងនោះ។

ជំពូកទី២

គោលការណ៍

មាត្រា ៥.-

ការជ្រើសរើសមុខងារជាជម្រើសរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុវត្តផ្អែកតាមគោលការណ៍ដូចខាងក្រោម ៖

- មុខងារដែលច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមានមិនហាមឃាត់
- មុខងារដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ
- មុខងារដែលអាចគ្រប់គ្រង និងអនុវត្តបានប្រកបដោយប្រសិទ្ធភាព ផ្អែកតាមលទ្ធភាព និងធនធានរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ
- មុខងារដែលបម្រើ ឬផ្តល់ផលប្រយោជន៍ជាចម្បងដល់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ

- មុខងារដែលជាតម្រូវការរបស់ប្រជាពលរដ្ឋ ឬអាទិភាពនៃមូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ជាពិសេសតម្រូវការរបស់ស្ត្រី យុវជន កុមារ និងជនងាយរងគ្រោះ។

មាត្រា ៦.-

បទដ្ឋាន នីតិវិធី និងធនធាន សម្រាប់ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើស ត្រូវសម្រេចដោយឆន្ទានុសិទ្ធិផ្ទាល់របស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។

មាត្រា ៧.-

ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើស ត្រូវផ្អែកលើគោលការណ៍ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព ការពិគ្រោះយោបល់ ការចូលរួម និងសមធម៌។

ជំពូកទី៣

នីតិវិធីនៃការជ្រើសរើស ការត្រួតពិនិត្យ ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើស

មាត្រា ៨.-

មុខងារជាជម្រើសណាមួយ ឬមួយចំនួន ដែលក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិមានបំណងជ្រើសរើសយកមកអនុវត្ត ចាំបាច់ត្រូវដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់រដ្ឋបាលសាមីនីមួយៗ។

ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិអាចធ្វើការកែសម្រួលនូវកម្មវិធីវិនិយោគរបស់ខ្លួន ដើម្បីដាក់បញ្ចូលនូវមុខងារជាជម្រើសថ្មី ឬមុខងារជាជម្រើសដែលត្រូវកែសម្រួល ដោយផ្អែកទៅលើសំណូមពរ និងតម្រូវការចាំបាច់របស់មូលដ្ឋាន។

មាត្រា ៩.-

ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ អាចផ្តួចផ្តើមជ្រើសរើសមុខងារជាជម្រើសមកអនុវត្តដោយផ្អែកលើតម្រូវការរបស់ប្រជាពលរដ្ឋ ឬអាទិភាពនៃមូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងផ្អែកទៅតាមសមត្ថភាពផ្នែករដ្ឋបាល បច្ចេកទេស និងហិរញ្ញវត្ថុដែលខ្លួនមាន។

ក្នុងការជ្រើសរើសមុខងារជាជម្រើស ក្រុមប្រឹក្សានីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិអាចពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិប្រភេទដូចគ្នា និងឬប្រភេទផ្សេងគ្នាដែលពាក់ព័ន្ធតាមការចាំបាច់។

ការសម្រេចយកមុខងារជាជម្រើសណាមួយឬមួយចំនួនមកអនុវត្តត្រូវមានការអនុម័តពីក្រុមប្រឹក្សា។

ចំពោះការសម្រេចយកមុខងារជាជម្រើសណាមួយ ឬមួយចំនួនដែលស្ថិតនៅក្រោមអាណត្តិរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញ ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវសម្របសម្រួល និងពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញពាក់ព័ន្ធទាំងនោះ មុននឹងក្រុមប្រឹក្សាអនុម័ត។

មាត្រា ១០.-

ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញ អាចធ្វើការជំទាស់ចំពោះមុខងារ ដែលស្ថិតនៅក្រោមអាណត្តិរបស់ខ្លួន ដែលក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិបានជ្រើសរើស។ ការជំទាស់នេះ ត្រូវធ្វើឡើងជាលាយ

លក្ខណ៍អក្សរ ក្នុងអំឡុងពេលនៃដំណើរការកសាង ឬការកែសម្រួលផែនការអភិវឌ្ឍន៍ ឬកម្មវិធីនិយោគ។

ការជំទាស់របស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញ អាចធ្វើឡើងក្នុងករណី ៖

- បញ្ហាសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើស
- មានភាពត្រួតស៊ីគ្នាជាមួយនឹងផែនការរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញ និងរដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀត។

មាត្រា ១១.-

ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ អាចគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើស ៖

- ដោយខ្លួនឯងផ្ទាល់ ឬ
- ដោយសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀត ឬក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញពាក់ព័ន្ធ ឬ
- ដោយសហការជាមួយផ្នែកឯកជន ឬសង្គមស៊ីវិល ឬអ្នកពាក់ព័ន្ធនានា។

មាត្រា ១២.-

អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ ក្នុងនាមក្រុមប្រឹក្សារបស់ខ្លួនត្រូវធានាអនុវត្តនូវមុខងារជាជម្រើសដែលបានអនុម័តដោយក្រុមប្រឹក្សាឱ្យមានប្រសិទ្ធភាព។

មាត្រា ១៣.-

ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ មានសិទ្ធិកែសម្រួល ឬបញ្ចប់នូវមុខងារជាជម្រើសដែលខ្លួនបានជ្រើសរើសក្នុងការអនុវត្ត។

ជំពូកទី៥

ធនធានសម្រាប់អនុវត្តមុខងារជាជម្រើស

មាត្រា ១៤.-

ក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តនូវមុខងារជាជម្រើស ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ អាចប្រើប្រាស់ធនធានផ្ទាល់របស់ខ្លួន អំណោយដែលបានមកពីប្រភពខាងក្នុង និងខាងក្រៅដែនសមត្ថកិច្ចរបស់ខ្លួន និងឬចំណូលពីប្រភពផ្សេងទៀតដែលច្បាប់ និងលិខិតបទដ្ឋានគតិយុត្តអនុញ្ញាត។

មាត្រា ១៥.-

រដ្ឋបាលថ្នាក់ក្រោមជាតិ អាចប្រមូលកម្រៃពីការប្រើប្រាស់សេវា ដែលពាក់ព័ន្ធនឹងមុខងារជាជម្រើសរបស់ខ្លួន។

ចំណូលដែលប្រមូលបានពីការផ្តល់សេវាដែលពាក់ព័ន្ធនឹងមុខងារជាជម្រើស ជាចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ហើយចំណូលនេះអាចប្រើប្រាស់សម្រាប់កំប៉ុងលើការចំណាយមួយផ្នែក ឬទាំងស្រុងនៃការផ្តល់សេវាទាំងនោះ។

តារាងតម្លៃសម្រាប់ការប្រមូលចំណូលពីការប្រើប្រាស់សេវា ដែលពាក់ព័ន្ធនឹងមុខងារជាជម្រើស ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមសំណើរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

មាត្រា ១៦.-

ការរៀបចំផែនការ ការរៀបចំគម្រោងថវិកា និងនីតិវិធីលទ្ធកម្មពាក់ព័ន្ធនឹងមុខងារជាជម្រើស ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុវត្តតាមលិខិតបទដ្ឋាន និងសេចក្តីណែនាំស្តីពីការរៀបចំផែនការ ការរៀបចំគម្រោងថវិកា និងនីតិវិធីលទ្ធកម្មជាធរមាន លើកលែងតែមានលិខិតបទដ្ឋានដោយឡែកសម្រាប់អនុវត្តចំពោះមុខងារជាជម្រើស។

ជំពូកទី៥

ការតាំ្រ ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ

មាត្រា ១៧.-

ដើម្បីធានាឱ្យការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើសប្រកបដោយប្រសិទ្ធភាព គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធផ្សេងទៀតក្នុងការគាំទ្របច្ចេកទេស សមត្ថភាព និងមធ្យោបាយចាំបាច់ផ្សេងៗទៀតដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។

មាត្រា ១៨.-

ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវចាត់ចែងឱ្យមានការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃទៅលើការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើស។

អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ ត្រូវរាយការណ៍អំពីលទ្ធផលនៃការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើសជូនក្រុមប្រឹក្សារបស់ខ្លួន។

មាត្រា ១៩.-

ក្នុងករណីចាំបាច់ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិអាចដាក់ចេញនូវឯកសារបច្ចេកទេស ដើម្បីជួយគាំទ្រដល់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការជ្រើសរើស ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើស។

ជំពូកទី៦

អនុសាសនបញ្ញត្តិ

មាត្រា ២០.-

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ២១.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ២០១៤

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

នៃព្រះរាជាណាចក្រកម្ពុជា

សូមហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប.

ស ខេង

កន្លែងទទួល ÷

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការអាជ្ញាកណ្តាល
- ទុទ្ធការិយាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទុទ្ធការិយាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋមន្ត្រីទាំង២១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការបង្កើតយន្តការប្រកបេញចុលតែមួយ

សម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពសមាជិករាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្តដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមកពា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ

- បានឃើញអនុក្រឹត្យលេខ២១៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ១៦៨ អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ៦៦៨ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

សម្រេច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

មាត្រា១.-

អនុក្រឹត្យនេះ មានគោលបំណងលើកកម្ពស់គុណភាព ប្រសិទ្ធភាព ប្រសិទ្ធផល តម្លាភាព និងគណនេយ្យភាពនៃការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការប្រមូលផ្តុំការផ្តល់សេវារដ្ឋបាលលើវិស័យនានានៅកន្លែងតែមួយ ដើម្បីបង្កលក្ខណៈងាយស្រួល និងឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។

មាត្រា២.-

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពីយន្តការ គោលការណ៍ បែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការគាំទ្រ ការតាមដាននិត្យភាព និងការវាយតម្លៃទៅលើការផ្តល់សេវារដ្ឋបាលទាំងនោះ។

មាត្រា៣.-

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងក្របខ័ណ្ឌសមត្ថកិច្ចដែលទទួលបានតាមរយៈការប្រគល់ឬការធ្វើប្រតិភូកម្មពីក្រសួង ស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល និងក្នុងក្របខ័ណ្ឌសមត្ថកិច្ចនៃអាណត្តិទូទៅរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ជំពូកទី២

យន្តការនៃការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលរាជធានី ខេត្ត

ផ្នែកទី១

រចនាសម្ព័ន្ធនិងតួនាទី

មាត្រា៤.-

រដ្ឋបាលរាជធានី ខេត្តនីមួយៗ ត្រូវបង្កើតឱ្យមាន**អង្គភាពច្រកចេញចូលតែមួយ**សម្រាប់ផ្តល់សេវាដ្ឋបាលជូនប្រជាពលរដ្ឋនៅក្នុងក្របខ័ណ្ឌសមត្ថកិច្ចបេស់ខ្លួន។

មាត្រា៥.-

អង្គភាពច្រកចេញចូលតែមួយ គឺជាកន្លែងប្រមូលផ្តុំការផ្តល់សេវាដ្ឋបាលនៅកន្លែងតែមួយតាមនីតិវិធីសាមញ្ញ ប្រកបដោយគុណភាព ប្រសិទ្ធភាព ប្រសិទ្ធផល តម្លាភាព និងគណនេយ្យភាព។

អង្គភាពច្រកចេញចូលតែមួយ ត្រូវរៀបចំជាពីផ្នែកគឺ ផ្នែកជួរមុខ និងផ្នែកជួរក្រោយ។

ផ្នែកជួរមុខ គឺជាកន្លែងសម្រាប់ប្រជាពលរដ្ឋប្រាស្រ័យទាក់ទងដោយផ្ទាល់ ដើម្បីទទួលព័ត៌មាននានាអំពីការផ្តល់សេវារដ្ឋបាល ទទួលទម្រង់បែបបទ ដាក់ពាក្យស្នើសុំ បង់ប្រាក់កម្រៃ និងទទួលលទ្ធផលសម្រេចជាផ្លូវការនៃសេវារដ្ឋបាលដែលបានស្នើសុំ។

ផ្នែកជួរក្រោយ គឺជាកន្លែងពិនិត្យ និងផ្តល់យោបល់ផ្នែកបច្ចេកទេសលើសំណុំបែបបទនៃការស្នើសុំសេវារដ្ឋបាល។

មាត្រា៦.-

អង្គភាពច្រកចេញចូលតែមួយត្រូវដឹកនាំដោយប្រធានមួយ(១)រូប និងអនុប្រធានយ៉ាងច្រើនពីរ(២)រូបជាជំនួយការ។

ប្រធានអង្គភាពច្រកចេញចូលតែមួយ មានឋានៈស្មើនាយកទីចាត់ការនៃសាលារាជធានី ខេត្ត។

អនុប្រធានអង្គភាពច្រកចេញចូលតែមួយ មានឋានៈស្មើនាយករងទីចាត់ការនៃសាលារាជធានី ខេត្ត។

ការតែងតាំងប្រធាននិងអនុប្រធានអង្គភាពច្រកចេញចូលតែមួយ ត្រូវអនុលោមលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និងលិខិតបទដ្ឋានគតិយុត្តដែលមានជាធរមាន។

មាត្រា៧.-

ការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ផ្នែកទី២

ទីកន្លែងធ្វើការ បុគ្គលិក ទិងប្រតេនសេវារដ្ឋបាល

មាត្រា៨.-

អភិបាលរាជធានី ខេត្ត ត្រូវរៀបចំឱ្យមានទីកន្លែងបំពេញការងារបេស់អង្គភាពច្រកចេញចូលតែមួយឱ្យបានសមស្រប និងបំពាក់នូវសម្ភារៈ បរិក្ខារ ឧបករណ៍ និងមធ្យោបាយសម្រាប់ភាំទ្រដល់បុគ្គលិកបំពេញការងារនៅក្នុងអង្គភាពនេះ ព្រមទាំងបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការទទួលសេវារដ្ឋបាល។

មាត្រា៩.-

រដ្ឋបាលរាជធានី ខេត្ត ត្រូវរៀបចំចាត់តាំងបុគ្គលិកដែលមានសមត្ថភាព និងបទពិសោធការងារក្នុងចំនួនសមស្របតាមទំហំការងារ និងស្ថានភាពជាក់ស្តែងនៃរដ្ឋបាលរាជធានី ខេត្តនីមួយៗសម្រាប់បំពេញការងារនៅផ្នែកជួរមុខនៃអង្គភាពច្រកចេញចូលតែមួយ។

មាត្រា១០.-

រាជធានី ខេត្ត ត្រូវសម្របសម្រួលជាមួយប្រធានមន្ទីរ អង្គភាពជំនាញពាក់ព័ន្ធនឹងការផ្តល់សេវារដ្ឋបាលដើម្បីចាត់តាំងបុគ្គលិកជំនាញយ៉ាងតិចចំនួនមួយ (១) អ្នក ដែលមានសមត្ថភាព និងបទពិសោធមកបំពេញការងារពេញម៉ោងនៅផ្នែកជួរក្រោយនៃអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត។

អភិបាលរាជធានី ខេត្ត ត្រូវរាយការណ៍អំពីការចាត់តាំងបុគ្គលិកមកបំពេញការងារនៅអង្គភាពច្រកចេញចូលតែមួយនេះជូនក្រុមប្រឹក្សារបស់ខ្លួន។

បុគ្គលិកដែលត្រូវបានចាត់តាំងឱ្យមកបំពេញការងារនៅផ្នែកជួរក្រោយនៃអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវបានប្រគល់សិទ្ធិក្នុងការពិនិត្យ និងការផ្តល់យោបល់បច្ចេកទេសលើសេវារដ្ឋបាលតាមវិស័យជំនាញរបស់ខ្លួន លើកលែងតែប្រភេទសេវារដ្ឋបាលមួយចំនួនដែលមានលក្ខណៈបច្ចេកទេសសាំញ៉ាំ ស្មុគស្មាញ មានតម្រូវការបច្ចេកទេសច្រើន និងតម្រូវឱ្យមានការទទួលខុសត្រូវខ្ពស់។

ក្នុងករណីខាងលើនេះ អភិបាលរាជធានី ខេត្ត ត្រូវពិគ្រោះយោបល់ជាមួយប្រធានមន្ទីរ អង្គភាពជំនាញនីមួយៗ ដើម្បីកំណត់អំពីប្រភេទសេវារដ្ឋបាលមួយចំនួនដែលមានលក្ខណៈបច្ចេកទេសសាំញ៉ាំ ស្មុគស្មាញ មានតម្រូវការបច្ចេកទេសច្រើន និងតម្រូវឱ្យមានការទទួលខុសត្រូវខ្ពស់ ព្រមទាំងចាត់តាំងបុគ្គលិកជំនាញទទួលខុសត្រូវឱ្យបានច្បាស់លាស់នៅតាមមន្ទីរ អង្គភាពពាក់ព័ន្ធ ដើម្បីពិនិត្យ និងផ្តល់យោបល់បច្ចេកទេសលើប្រភេទសេវារដ្ឋបាលទាំងនេះ។

មាត្រា១១.-

អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវផ្តល់សេវារដ្ឋបាលតាមប្រភេទសេវារដ្ឋបាលដូចបានកំណត់នៅក្នុងតារាងឧបសម្ព័ន្ធទី១ ភ្ជាប់នឹងអនុក្រឹត្យនេះ។

តម្លៃសេវា រយៈពេលនៃការផ្តល់សេវា និងសុពលភាពនៃសេវារដ្ឋបាល ត្រូវអនុវត្តតាមប្រកាសអន្តរក្រសួងរវាងក្រសួង ស្ថាប័នពាក់ព័ន្ធនីមួយៗ ជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើកលែងតែមានការកំណត់ផ្សេងពីនេះ។

ក្រសួង ស្ថាប័នពាក់ព័ន្ធនានា ត្រូវបន្តផ្ទេរមុខងារក្នុងការផ្តល់សេវារដ្ឋបាលបន្ថែមទៀតទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ដើម្បីបង្កលក្ខណៈងាយស្រួល និងបង្ខិតការផ្តល់សេវារដ្ឋបាលឱ្យកាន់ជិតអ្នកប្រើប្រាស់សេវា។

មាត្រា១២.-

ក្រសួងមហាផ្ទៃដោយមានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា ត្រូវផ្តល់ការណែនាំអំពីទម្រង់បែបបទ នីតិវិធី និងលក្ខខណ្ឌភ្ជាប់សម្រាប់ស្នើសុំសេវារដ្ឋបាលឱ្យមានលក្ខណៈសាមញ្ញងាយយល់និងច្បាស់លាស់។

ជំពូកទី៣

យន្តការនៃការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ

ផ្នែកទី១

ទេនាសម្ព័ន្ធនិងតួនាទី

មាត្រា១៣.-

រដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗ ត្រូវបង្កើតឱ្យមានការិយាល័យច្រកចេញចូលតែមួយ ឬយន្តការច្រកចេញចូលតែមួយសម្រាប់ផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋនៅក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់ខ្លួន។

លក្ខណសម្បត្តិនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ សម្រាប់បង្កើតការិយាល័យច្រកចេញចូលតែមួយ ត្រូវកំណត់ដោយសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

មាត្រា១៤.-

ការិយាល័យច្រកចេញចូលតែមួយ គឺជាកន្លែងប្រមូលផ្តុំការផ្តល់សេវារដ្ឋបាលនៅកន្លែងតែមួយ តាមនីតិវិធីសាមញ្ញ ប្រកបដោយគុណភាព ប្រសិទ្ធភាព ប្រសិទ្ធផល តម្លាភាព និងគណនេយ្យភាព។

ការិយាល័យច្រកចេញចូលតែមួយ ត្រូវរៀបចំជាពីរផ្នែកគឺ ផ្នែកជួរមុខ និងផ្នែកជួរក្រោយ។

ផ្នែកជួរមុខ គឺជាកន្លែងសម្រាប់ប្រជាពលរដ្ឋប្រាស្រ័យទាក់ទងដោយផ្ទាល់ ដើម្បីទទួលព័ត៌មាននានាអំពីការផ្តល់សេវារដ្ឋបាល ទទួលទម្រង់បែបបទ ដាក់ពាក្យស្នើសុំ បង់ប្រាក់កម្រៃ និងទទួលលទ្ធផលសម្រេចជាផ្លូវការនៃសេវារដ្ឋបាលដែលបានស្នើសុំ។

ផ្នែកជួរក្រោយ គឺជាផ្នែកដែលទ្រទ្រង់ជំរំខាន់លើការងារបច្ចេកទេស។ ផ្នែកជួរក្រោយមានតួនាទីពិនិត្យ និងផ្តល់យោបល់ផ្នែកបច្ចេកទេសលើការផ្តល់សេវារដ្ឋបាលតាមវិស័យជំនាញ។

មាត្រា១៥.-

ការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តតាមប្រកាសលេខ ៩២៨ប្រក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៩ របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃការិយាល័យច្រកចេញចូលតែមួយនៅក្រុង ស្រុក ខណ្ឌតាលដៅ។

បែបបទនិងនីតិវិធីនៃការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ផ្នែកទី២

ទីកន្លែងធ្វើការ បុគ្គលិក និងម៉ោងបម្រើសេវារដ្ឋបាល

មាត្រា១៦.-

អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំឱ្យមានទីកន្លែងបំពេញការងាររបស់ការិយាល័យច្រកចេញចូលតែមួយឱ្យបានសមស្រប និងបំពាក់នូវសម្ភារៈ បរិក្ខារ ឧបករណ៍ និងមធ្យោបាយសម្រាប់គាំទ្រដល់

បុគ្គលិកបំពេញការងារនៅក្នុងការិយាល័យនេះ ក្រមទាំងបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការទទួលសេវារដ្ឋបាល។

មាត្រា១៧.

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវចាត់តាំងបុគ្គលិកមានសមត្ថភាព និងបទពិសោធការងារក្នុងចំនួនសមស្របតាមទំហំការងារ និងតាមស្ថានភាពជាក់ស្តែងនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗឱ្យមកបំពេញការងារនៅផ្នែកជួរមុខនៃការិយាល័យប្រកបចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញពាក់ព័ន្ធនានា ត្រូវចាត់តាំងបុគ្គលិកជំនាញមានសមត្ថភាព និងបទពិសោធការងារឱ្យមកបំពេញការងារជាផ្នែកជួរក្រោយនៅក្នុងការិយាល័យប្រកបចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវរាយការណ៍អំពីការចាត់តាំងបុគ្គលិកមកបំពេញការងារនៅការិយាល័យប្រកបចេញចូលតែមួយនេះជូនក្រមប្រឹក្សារបស់ខ្លួន។

ក្នុងករណីដែលក្រសួង ស្ថាប័ន មន្ទីរ អង្គភាពណាមួយពុំទាន់មានបុគ្គលិកជំនាញសម្រាប់ចាត់តាំងឱ្យមកបំពេញការងារនៅផ្នែកជួរក្រោយ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវចាត់តាំងបុគ្គលិករដ្ឋបាលរបស់ខ្លួនឱ្យមកបំពេញការងារជាបុគ្គលិកផ្នែកជួរក្រោយទទួលភ័ប់រងក្នុងនាមជាភ្នាក់ងារគត់ណាងឱ្យវិស័យជំនាញនោះ។ ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញ ត្រូវផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិកដែលត្រូវបានចាត់តាំងនោះ។

បុគ្គលិកដែលបំពេញការងារនៅក្នុងការិយាល័យប្រកបចេញចូលតែមួយ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់អភិបាលក្រុង ស្រុក ខណ្ឌ។ ក្របខ័ណ្ឌ និងបៀវត្សរបស់បុគ្គលិកមកពីក្រសួង ស្ថាប័នពាក់ព័ន្ធនានាដែលបំពេញការងារនៅការិយាល័យប្រកបចេញចូលតែមួយ ត្រូវស្ថិតនៅក្នុងក្រសួង ស្ថាប័នសាមីដោយទទួលបានការជំរឿងថ្នាក់ ឋានន្តរស័ក្តិ គ្រឿងឥស្សរិយយស ការលើកទឹកចិត្ត និងអត្ថប្រយោជន៍នានាតាមនីតិវិធីជាធរមាន។

មាត្រា១៨.

ការិយាល័យប្រកបចេញចូលតែមួយ និងយន្តការប្រកបចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវផ្តល់សេវារដ្ឋបាលដូចបានកំណត់នៅក្នុងតារាងឧបសម្ព័ន្ធទី២ ភ្ជាប់នឹងអនុក្រឹត្យនេះ។

កម្រៃសេវា រយៈពេលនៃការផ្តល់សេវា និងសុពលភាពនៃសេវារដ្ឋបាល ត្រូវអនុវត្តតាមប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើកលែងតែមានការកំណត់ផ្សេងពីនេះ។

ក្រសួង ស្ថាប័នពាក់ព័ន្ធនានា ត្រូវបន្តផ្នែរមុខងារក្នុងការផ្តល់សេវារដ្ឋបាលបន្ថែមទៀតទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីបង្កលក្ខណៈងាយស្រួល និងបង្ខិតការផ្តល់សេវារដ្ឋបាលឱ្យទៅជិតអ្នកប្រើប្រាស់សេវា។

មាត្រា១៩._

ក្រសួងមហាផ្ទៃ ដោយហានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា ត្រូវផ្តល់ការណែនាំអំពីទម្រង់បែបបទ នីតិវិធី និងលក្ខខណ្ឌក្បាប់សម្រាប់ស្នើសុំសេវារដ្ឋបាលឱ្យមានលក្ខណៈសាមញ្ញ ងាយយល់ និងច្បាស់លាស់។

ជំពូកទី៤

យន្តការនៃការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលឃុំ សង្កាត់

មាត្រា២០._

រដ្ឋបាលឃុំ សង្កាត់ត្រូវរៀបចំឱ្យមានយន្តការប្រកបចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋនៅក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់ខ្លួន។

យន្តការប្រកបចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់ ត្រូវស្ថិតនៅក្រោមការដឹកនាំរបស់មេឃុំ ចៅសង្កាត់ក្នុងនាមក្រុមប្រឹក្សាឃុំ សង្កាត់ ដោយមានស្មៀនឃុំ សង្កាត់ជាសេនាធិការ។

មេឃុំ ចៅសង្កាត់ អាចប្រគល់សិទ្ធិក្នុងការពិនិត្យ ការសម្រេច និងការចុះហត្ថលេខាលើលិខិតអនុញ្ញាតឬលិខិតបញ្ជាក់ចាំបាច់មួយចំនួនជូនជំទប់ ចៅសង្កាត់ដែរបស់ខ្លួនស្របតាមមាត្រា៤០នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

មាត្រា២១._

មេឃុំ ចៅសង្កាត់ ត្រូវចាត់តាំងស្មៀន ឬបុគ្គលិកជំនួយការរដ្ឋបាលឱ្យបំពេញភារកិច្ចជាបុគ្គលិកផ្តល់ព័ត៌មាន ទទួលប្រគល់ឯកសារ ទទួលភម្រៀសេវារដ្ឋបាល និងពិនិត្យផ្តល់យោបល់លើសំណើសុំសេវារដ្ឋបាលដើម្បីជាក់ជូនមេឃុំ ចៅសង្កាត់ពិនិត្យ និងសម្រេច។

ការចាត់តាំងឬការប្រគល់ភារកិច្ចជូនបុគ្គលិកផ្តល់ព័ត៌មាន ទទួលប្រគល់ឯកសារ និងទទួលភម្រៀសេវារដ្ឋបាល ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់រដ្ឋបាលឃុំ សង្កាត់។

មេឃុំ ចៅសង្កាត់ ត្រូវរៀបចំឱ្យមានទីកន្លែងសម្រាប់ការផ្តល់សេវារដ្ឋបាលឱ្យបានសមស្រប និងបំពាក់នូវសម្ភារៈ បរិក្ខារ ឧបករណ៍ និងមធ្យោបាយសម្រាប់គាំទ្រដល់ការផ្តល់សេវារដ្ឋបាល ព្រមទាំងបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការទទួលសេវារដ្ឋបាល។

មាត្រា២២._

យន្តការប្រកបចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់ ត្រូវផ្តល់សេវារដ្ឋបាលទៅតាមប្រភេទសេវាកម្រៀសេវា រយៈពេលនៃការផ្តល់សេវា និងសុពលភាពនៃសេវារដ្ឋបាល ដូចបានកំណត់នៅក្នុងប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើកលែងតែមានការកំណត់ផ្សេងពីនេះ។

មាត្រា២៣._

ក្រសួងមហាផ្ទៃត្រូវផ្តល់ការណែនាំអំពីទម្រង់បែបបទ នីតិវិធី និងលក្ខខណ្ឌក្បាប់សម្រាប់ស្នើសុំសេវារដ្ឋបាលឱ្យមានលក្ខណៈសាមញ្ញ ងាយយល់ និងច្បាស់លាស់។

ជំពូកទី៥

ការគ្រប់គ្រងនិងការចាត់ចែងចំណូលសេវាផ្ទៃបាល

មាត្រា២៤.-

រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិទទួលបានចំណូលពីកម្រៃសេវារដ្ឋបាល។

ចំណូលដែលទទួលបានពីកម្រៃនៃការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់នីមួយៗ ត្រូវបង់ចូលថវិកាថ្នាក់ជាតិ និង/ឬថវិកាថ្នាក់ក្រោមជាតិតាមគោលការណ៍កំណត់។

ការគ្រប់គ្រងចំណូល ចំណាយ ការកត់ត្រា និងការបែងចែកប្រាក់រង្វាន់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុវត្តតាមច្បាប់ លិខិតបទដ្ឋាន គោលការណ៍ និងនីតិវិធីនានាដែលពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

មាត្រា២៥.-

ការបែងចែកចំណូលដែលប្រមូលបានពីការផ្តល់សេវារដ្ឋបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងការបែងចែកប្រាក់រង្វាន់លើកទឹកចិត្តសម្រាប់ឧបត្ថម្ភដល់បុគ្គលិក និងសម្រាប់ពង្រឹងយន្តការផ្តល់សេវារដ្ឋបាលត្រូវអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន លើកលែងតែមានការកំណត់ផ្សេងពីនេះ។

ជំពូកទី៦

ការគាំទ្រ ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ

មាត្រា២៦.-

គ.ជ.អ.ប មានតួនាទីក្នុងការសម្របសម្រួលជាមួយក្រសួង ស្ថាប័នដែលពាក់ព័ន្ធនានាក្នុងការគាំទ្រផ្នែកគោលនយោបាយ ការកៀរគរធនធាន និងការគាំទ្របច្ចេកទេសពីអ្នកពាក់ព័ន្ធនានាក្នុងដំណើរការនៃការផ្ទេរមុខងារ និងដំណើរការអនុវត្តការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

គ.ជ.អ.ប អាចប្រើប្រាស់យន្តការដែលមានស្រាប់ដូចជា ក្រុមពិគ្រោះយោបល់បច្ចេកទេសអន្តរក្រសួងដើម្បីសម្របសម្រួលក្នុងដំណើរការនៃការផ្ទេរមុខងារ និងដំណើរការអនុវត្តការផ្តល់សេវារដ្ឋបាលនៅដ្ឋបាលថ្នាក់ក្រោមជាតិ។

មាត្រា២៧.-

ក្រសួងមហាផ្ទៃមានតួនាទីសម្របសម្រួលក្នុងការបង្កើតអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ការិយាល័យច្រកចេញចូលតែមួយនៃដ្ឋបាលក្រុង ស្រុក ខណ្ឌ និងយន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ ព្រមទាំងគាំទ្រផ្នែកបច្ចេកទេសដល់ដំណើរការផ្តល់សេវារដ្ឋបាល ការអភិវឌ្ឍសមត្ថភាព ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តការផ្តល់សេវារដ្ឋបាលដោយសហការជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធនានា។

ក្រសួងមហាផ្ទៃ ត្រូវសម្របសម្រួលជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងរដ្ឋបាលរាជធានី ខេត្ត ដើម្បីគាំទ្រដល់ការរៀបចំទីកន្លែងផ្តល់សេវា និងបំពាក់សម្ភារៈ បរិក្ខារ ឧបករណ៍ និងមធ្យោបាយដល់អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត និងការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

ក្រសួងមហាផ្ទៃ អាចប្រើប្រាស់ប្រព័ន្ធគ្រប់គ្រង ឬយន្តការដែលមានស្រាប់ដើម្បីជានារបើការគ្រប់គ្រង ការគាំទ្រ ការសម្របសម្រួល និងការអនុវត្តកិច្ចការនេះ។

មាត្រា២៨.-

ក្រសួង ស្ថាប័នពាក់ព័ន្ធនានា ត្រូវសម្របសម្រួល និងដំរូវមន្ទីរ អង្គភាពជំនាញរបស់ខ្លួនក្នុងការចាត់តាំងបុគ្គលិកដែលមានសមត្ថភាព និងបទពិសោធការងារឱ្យមកបំពេញការងារជាបុគ្គលិកផ្នែកដូរក្រោយនៅក្នុងអង្គភាពច្រកចេញចូលតែមួយ ការិយាល័យច្រកចេញចូលតែមួយ និងយន្តការច្រកចេញចូលតែមួយ ព្រមទាំងផ្តល់ការគាំទ្រលើការអភិវឌ្ឍសមត្ថភាព ការគាំទ្រផ្នែកបច្ចេកទេស ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃលើការផ្តល់សេវារដ្ឋបាលដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

មាត្រា២៩.-

រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវជានាឱ្យមានការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃជាប្រចាំ ព្រមទាំងទទួលដោះស្រាយនូវរាល់ភាពមិនប្រក្រតីក្នុងការផ្តល់សេវារដ្ឋបាលនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ជំពូកទី៧

អន្តរាប្បញ្ញត្តិ

មាត្រា៣០.-

រដ្ឋបាលរាជធានី ខេត្ត ត្រូវបង្កើតអង្គភាពច្រកចេញចូលតែមួយឱ្យបានយ៉ាងយូរត្រឹមដំណាច់ធមាសទី១នៃឆ្នាំ២០១៧។

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលមានលក្ខណសម្បត្តិស្របតាមការកំណត់របស់ក្រសួងមហាផ្ទៃ ត្រូវបង្កើតការិយាល័យច្រកចេញចូលតែមួយឱ្យបានយ៉ាងយូរត្រឹមដំណាច់ឆ្នាំ២០១៧។

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលពុំទាន់មានលក្ខណសម្បត្តិសមស្របសម្រាប់បង្កើតការិយាល័យច្រកចេញចូលតែមួយ និងរដ្ឋបាលឃុំ សង្កាត់ ត្រូវបង្កើតយន្តការច្រកចេញចូលតែមួយឱ្យបានយ៉ាងយូរត្រឹមដំណាច់ឆ្នាំ២០១៧។

ជំពូកទី៨

អនុសាសនប្បញ្ញត្តិ

មាត្រា៣១.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៣២.-

ផ្ទេមន្ត្រីទទួលបន្ទុកទីស្តីការគណៈផ្ទេមន្ត្រី ផ្ទេមន្ត្រីក្រសួងមហាផ្ទៃ ផ្ទេមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផ្ទេមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែកុម្ភៈ ឆ្នាំ២០១៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីសូមហត្ថលេខា

ទេសនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.

សម្តេចក្រឡាហោម ស ខេង

ទទួលពណ្ឌៈ :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិខ្មែរ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការពេជ្រដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវទេសនាយករដ្ឋមន្ត្រី
- ឯកឧត្តមគ្រប់ជាន
- ពាក់ព័ន្ធ
- ឯកសារ-ឧត្តរបញ្ជី

តារាងឯកសណ្ឋានលិខិត

សេវាផ្តល់ជូនដោយទីស្នាក់ការអន្តោប្រវេសន៍ ខេត្ត

ក្នុងនីតិវិធីលេខ ២៥.អន្តោ.ឯ.ក. ចុះថ្ងៃទី ..ខែ កុម្ភៈ ឆ្នាំ២០១៧

ស្តីពីការបង្កើតយន្តការប្រកបដោយប្រសិទ្ធភាពសម្រាប់ការផ្តល់សេវាផ្តល់ជូនដោយទីស្នាក់ការអន្តោប្រវេសន៍

ល.រ	បរិយាយ
១. តារាងនីតិសាស្ត្រទូទៅ (ការចម្លាក់លើឯកសារដើមតម្លៃ)	
១	សេចក្តីអនុញ្ញាតឱ្យប្រកបអាជីវកម្ម អាហរណ៍ ទីហរណ៍ សណ្ឋាគារ និងភោគទុនបរទេស
២	លក្ខន្តិកៈក្រុមហ៊ុនអាជីវកម្មនានា ញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុន លិខិតក្រសួងពាណិជ្ជកម្ម កិច្ចសន្យា
៣	ប្លង់សាងសង់
៤	ញ្ញាបនបត្រសម្គាល់ម្ចាស់កម្មសិទ្ធិអចលនវត្ថុ
៥	សញ្ញាបត្រក្រោយឧត្តមសិក្សា(ក្នុងប្រទេស)
៦	សញ្ញាបត្រវុឌ្ឍិកសិក្សា
៧	លិខិតអនុញ្ញាតចុះបញ្ជីសមាគម អង្គការ ព្រះវិហារសាសនា និងសហគមន៍
៨	លិខិត ឬឯកសារផ្សេងៗទៀត(ដែលមិនមែនជាសមត្ថកិច្ចរបស់ស្ថាប័នណាមួយ)
២. ការសាងផ្ទះសម	
១	ការអនុញ្ញាតឱ្យជីកឆ្លងផ្លូវ ឬតាមបណ្តោយផ្លូវក្នុងរាជធានី ខេត្ត
២	លិខិត/បំណុលឆ្លងព្រំដែន(laissez-passer)
៣	លិខិតអនុញ្ញាតទីតាំងប៉ាណូអចលិត
៤	ការចេញលិខិតអនុញ្ញាតបំពេញអាចម៍ដីកម្មសិទ្ធិឯកជនចាប់ពី ១០០០ម៉ែត្រការ៉េឡើងទៅ
៥	ការចុះបញ្ជីវិនិយោគជាគម្រោងមានលក្ខណៈសម្បត្តិត្រប់គ្រាន់នៅអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត(ទុនវិនិយោគក្រោម២លានដុល្លារអាមេរិក)
៣. ទិដ្ឋសុខាភិបាល	
១	ការផ្តល់លិខិតអនុញ្ញាតដល់ឧស្ថានចំពោះ ការបើកថ្មី ការប្តូរទីតាំង ការប្តូរឈ្មោះឧស្ថការី និងការបន្តសុពលភាព
២	ការផ្តល់លិខិតអនុញ្ញាតដល់អគារឧស្ថប្បណាចំពោះ ការបើកថ្មី ការប្តូរទីតាំង ការប្តូរឈ្មោះគ្រូឧស្ថប្បណា និងការបន្តសុពលភាព
៣	ការផ្តល់ញ្ញាបនបត្របញ្ជាក់អនាម័យចំណីអាហារតាមភោជនីយដ្ឋាន និងអាហារដ្ឋានដែលមានចំណុះចាប់ពី៥១កៅអីឡើង(មិនមែនអាហារដ្ឋាននិងភោជនីយដ្ឋានប្រណីត)
៤. ទិដ្ឋសុខាភិបាល	
១	**អាជ្ញាប័ណ្ណទេសចរណ៍សម្រាប់សណ្ឋាគារ និងសៅកម្មស្នាក់នៅទេសចរណ៍**
	- សណ្ឋាគារ ឬសណ្ឋាគារអោយជាតមិន ឬសណ្ឋាគារស្មើត ឬសណ្ឋាគារសែត ឬបឹងហ្គាឡូ ឬម៉ូតែល ឬឡុដ(Lodge) ចំណុះត្រឹម២០បន្ទប់

ល.រ	បរិយាយ
	- ផ្ទះភ្ញៀវត្រូវបង់ថ្លៃអាជ្ញាប័ណ្ណទេសចរណ៍
	- អាជ្ញាប័ណ្ណទេសចរណ៍សម្រាប់ភោជនីយដ្ឋាន អាហារដ្ឋានទេសចរណ៍ចំណុះពី៥១ ដល់១០០នាក់
	- អាជ្ញាប័ណ្ណទេសចរណ៍សម្រាប់បៀរហ្គាឌិន
	- អាជ្ញាប័ណ្ណទេសចរណ៍សម្រាប់ខាត់អូខចាប់ពី៦បន្ទប់ឡើងទៅ
	- អាជ្ញាប័ណ្ណទេសចរណ៍សម្រាប់ម៉ាស្សាសុខភាពចំណុះពី០៦ ដល់១០គ្រែ ឬក៏អ៊ី
	- អាជ្ញាប័ណ្ណទេសចរណ៍សម្រាប់ស្ប៉ា
	- អាជ្ញាប័ណ្ណទេសចរណ៍សម្រាប់ឡេសាលង៉ីស្តែក ឬឡេសាល-ង៉ីស្តែក
	- អាជ្ញាប័ណ្ណទេសចរណ៍សម្រាប់ដឹកជញ្ជូនភ្ញៀវទេសចរណ៍តាមផ្លូវទឹក(មិនមែនជាលក្ខណៈក្រុមហ៊ុន)
	- អាជ្ញាប័ណ្ណទេសចរណ៍សម្រាប់ដឹកជញ្ជូនភ្ញៀវទេសចរណ៍តាមផ្លូវគោកចាប់ពី៦គ្រែឡើងទៅ
២	**អាជ្ញាប័ណ្ណទេសចរណ៍សម្រាប់កីឡាទេសចរណ៍**
	- កីឡាស្គុកយ៉ូរចាប់ពី៦គូឡើងទៅ
	- ម៉ាស៊ីនហ្គេម
	- កីឡាសៀក
	- កីឡាជិះកង់ឆ្ងង់
	- កីឡាជិះដំរី
	- កីឡាជិះសេះ
	- ថេយន្ត ឬរថក្លែងអត្តសនី
ជ. ចីរសំយសាធារណការ និងដឹកជញ្ជូន	
	ក. ផ្នែកដឹកជញ្ជូនផ្លូវគោក
១	**ការប្រឡងយកប័ណ្ណបើកបរយានយន្ត និងប្តូរ ពន្យារ ទុតិយតា តតិយតា(លើកលែងជនបរទេស)**
	- ប្រឡងយកប័ណ្ណបើកបរទោចក្រយានយន្តប្រភេទ ក
	- ប្រឡងយកប័ណ្ណបើកបរឡើងវិញ ទោចក្រយានយន្តប្រភេទ ក
	- ប្តូរ ពន្យារ ទុតិយតា ឬតតិយតាប័ណ្ណបើកបរទោចក្រយានយន្តប្រភេទ ក
	- ប្រឡងយកប័ណ្ណបើកបររថយន្តប្រភេទ ខ
	- ប្រឡងយកប័ណ្ណបើកបរឡើងវិញ រថយន្តប្រភេទ ខ
	- ប្តូរ ពន្យារ ទុតិយតា ឬតតិយតាប័ណ្ណបើកបររថយន្ត
២	**ការចុះបញ្ជីយានយន្ត**
	- ផ្ទេរកម្មសិទ្ធិទោចក្រយានយន្ត ឬត្រីចក្រយានយន្តក្នុងរាជធានី-ខេត្ត
	- ផ្ទេរកម្មសិទ្ធិទោចក្រយានយន្ត ឬត្រីចក្រយានយន្តឆ្លងរាជធានី-ខេត្ត
	- ផ្ទេរកម្មសិទ្ធិរ៉ឺម៉ក(ទោចក្រយានយន្ត) ក្នុងរាជធានី-ខេត្ត
	- ផ្ទេរកម្មសិទ្ធិរ៉ឺម៉ក(ទោចក្រយានយន្ត) ឆ្លងរាជធានី-ខេត្ត
	- ចុះបញ្ជីរថយន្តពុនតូច
	- ចុះបញ្ជីរថយន្តពុនធំ
	- ចុះបញ្ជីរ៉ឺម៉ក ឬសឺមីរ៉ឺម៉ករថយន្ត

ល.រ	បរិយាយ
	- ផ្ទេរកម្មសិទ្ធិរថយន្តធុនតូចក្នុងរាជធានី-ខេត្ត
	- ផ្ទេរកម្មសិទ្ធិរថយន្តធុនតូចឆ្លងរាជធានី-ខេត្ត
	- ផ្ទេរកម្មសិទ្ធិរថយន្តធុនធំក្នុងរាជធានី-ខេត្ត
	- ផ្ទេរកម្មសិទ្ធិរថយន្តធុនធំឆ្លងរាជធានី-ខេត្ត
	- ផ្ទេរកម្មសិទ្ធិម៉ែក ឬសឺម៉ីរ៉ឺម៉ែករថយន្តក្នុងរាជធានី-ខេត្ត
	- ផ្ទេរកម្មសិទ្ធិម៉ែក ឬសឺម៉ីរ៉ឺម៉ែករថយន្តឆ្លងរាជធានី-ខេត្ត
	- ប្តូរ ទុតិយតា ឬតតិយតាប័ណ្ណរថយន្តធុនតូច
	- ប្តូរ ទុតិយតា ឬតតិយតាប័ណ្ណរថយន្តធុនធំ រ៉ឺម៉ក ឬសឺម៉ីរ៉ឺម៉ក
	- ប្តូរ ទុតិយតា ឬតតិយតាផ្លាកលេខរថយន្តធុនតូច(ផ្លាកម្ខាង)
	- ប្តូរ ទុតិយតា ឬតតិយតាផ្លាកលេខរថយន្តធុនតូច(ផ្លាក ១គូ)
	- ប្តូរ ទុតិយតា ឬតតិយតាផ្លាកលេខរថយន្តធុនធំ រ៉ឺម៉ក ឬសឺម៉ីរ៉ឺម៉ក(ផ្លាកម្ខាង)
	- ប្តូរ ទុតិយតា ឬតតិយតាផ្លាកលេខរថយន្តធុនធំ(ផ្លាក ១គូ)
៣	**ការចុះបញ្ជី និងលិខិតអនុញ្ញាតធ្វើអាជីវកម្មសាលា និងសាខាសាលាបង្រៀនបើកបរយានយន្ត**
	- ផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មសាខាសាលាបង្រៀនបើកបរ
៤	**ការផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មយានយន្ត**
៤.១	**ការផ្តល់លិខិតអនុញ្ញាតយានយន្តធ្វើអាជីវកម្មក្នុងប្រទេស**
	- រថយន្តដឹកទំនិញមានចំណុះផ្ទុកមិនលើសពី៥តោន
	- រថយន្តដឹកទំនិញមានចំណុះផ្ទុកលើសពី៥តោន ដល់១០តោន
	- រថយន្តដឹកទំនិញមានចំណុះផ្ទុកលើសពី១០តោន
	- រថយន្តដឹកអ្នកដំណើរមានចំណុះផ្ទុកមិនលើសពី៩នាក់
	- រថយន្តដឹកអ្នកដំណើរមានចំណុះផ្ទុកចាប់ពី១០នាក់ ដល់២០នាក់
	- រថយន្តដឹកអ្នកដំណើរមានចំណុះផ្ទុកលើសពី២០នាក់
៤.២	**ការចុះបញ្ជី និងផ្តល់លិខិតអនុញ្ញាតក្រុមហ៊ុនដឹកជញ្ជូនក្នុងប្រទេស**
	- ផ្តល់លិខិតអនុញ្ញាតបើកស្នាក់ការ ឬសាខាក្រុមហ៊ុនដឹកជញ្ជូន
៥	**ការចុះបញ្ជី និងផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មយានដ្ឋានជួសជុលកែច្នៃ ដំឡើងយានយន្ត**
	- ចុះបញ្ជី និងផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មយានដ្ឋានក្នុងរាជធានី ខេត្ត
	ខ. សេវាសាធារណៈលើផ្នែកដឹកជញ្ជូនផ្លូវគោក
៦	**ការផ្តល់ប័ណ្ណសម្គាល់ជំលយាន**
៦.១	**ជំលយានដែលមានចំណុះផ្ទុក២០តោនចុះក្រោម កំលាំងម៉ាស៊ីន៨០សេះចុះក្រោម និង២៥កៅអីចុះក្រោម**
	- ផ្តល់ប័ណ្ណសម្គាល់ជំលយាន(បញ្ជាក់អ៊ូ/ប្លង់/ពន្ធនាំចូលជំលយាន ជាបន្ទុករបស់ម្ចាស់ជំលយាន)
	- ប្តូរម៉ាស៊ីន ពណ៌ កែមាន ឬផ្ទេរម្ចាស់កម្មសិទ្ធិជំលយាន(បញ្ជាក់អ៊ូ/ប្លង់កែមាន/ប្រថាប់ត្រា ជាបន្ទុកបេស់ម្ចាស់ជំលយាន)
	- ប្តូរ(ប្តូរឈ្មោះជំលយាន) ទុតិយតា ឬតតិយតាប័ណ្ណសម្គាល់ជំលយាន
៦.២	**ជំលយានដែលមានចំណុះផ្ទុកលើសពី២០តោន ដល់៨០តោន កំលាំងម៉ាស៊ីនលើសពី៨០សេះ ដល់៩០**

លរ	បរិយាយ
	សេះ និងលើសពី២៥កៅអី ដល់៥០កៅអី
	- ផ្តល់បំណុលសម្រាប់ជលយាន(បញ្ចាក់អ៊ូរ/ប្លង់/ពន្ធនាំចូលជលយាន ជាបន្ទុករបស់ម្ចាស់ជលយាន)
	- ប្តូរម៉ាស៊ីន ពណ៌ កែមាន ឬផ្ទេរម្ចាស់កម្មសិទ្ធិជលយាន(បញ្ចាក់អ៊ូរ/ប្លង់កែមាន/ប្រថាប់ត្រា ជាបន្ទុករបស់ម្ចាស់ជលយាន)
	- ប្តូរ(ប្តូរឈ្មោះជលយាន) ទុតិយតា ឬ តតិយតាបំណុលសម្រាប់ជលយាន
៧	**ត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយាន**
៧.១	**ជលយានដែលមានចំណុះផ្ទុក២០តោនចុះក្រោម កម្លាំងម៉ាស៊ីន៤០សេះចុះក្រោម និង២៥កៅអីចុះក្រោម**
	- ជលយានក្នុងស្រុក
	- ជលយានដចម្លង
៧.២	**ជលយានដែលមានចំណុះផ្ទុកលើសពី ២០តោន ដល់៤០តោន កំលាំងម៉ាស៊ីនលើសពី៤០សេះ ដល់៩០ សេះ និងលើសពី២៥កៅអី ដល់៥០កៅអី**
	- ជលយានក្នុងស្រុក
	- ជលយានដចម្លង
៨	**លិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវទឹក**
	- នាវាដឹកទំនិញ
	- សាឡង់ដឹកទំនិញ(គ្មានម៉ាស៊ីន)
	- នាវាដឹកអ្នកដំណើរ
	- ដចម្លង
	- នាវាសណ្តោង/ក្រៃ
៦. ទិសវិស័យសង្គម ធនធានមនុស្ស	
១	ការចេញលិខិតអនុញ្ញាតការប្រគំតន្ត្រីតាមទីសាធារណៈលក្ខណៈអន្តរជាតិ
២	ការផ្តល់បំណុលអនុញ្ញាតបើតអាជីវកម្មបណ្តាគារដែលមានផ្ទៃក្រឡាចាប់ពី៥០ម៉ែត្រការ៉េឡើងទៅ
៧. ទិសវិស័យពាណិជ្ជកម្ម	
១	**ការផ្តល់លិខិតអនុញ្ញាតចំពោះការស្នើសុំប្រកបអាជីវកម្ម និងបន្តសុពលភាព៖**
	- បោះពុម្ពដោយដៃ(អូសស្បែ) បោះពុម្ពលើអាវយឺត
	- តូបលក់កាសែត តូបលក់សៀវភៅ ផលិតផលបោះពុម្ព និងផលិតផលសោតទស្សន៍
	- សៀវភៅសុជុលម៉ាស៊ីនថត ម៉ាស៊ីនថតចំលង សៀវភៅសុជុលកុំព្យូទ័រ វាយកុំព្យូទ័រ សៀវភៅសុជុលវិទ្យុ ទូរទស្សន៍ ម៉ាញេ រ៉ូណេអូ អំភ្លី មេក្រូ
	- អគារលក់ឧបករណ៍សោតទស្សន៍
	- Internet Café
៨. ទិសវិស័យបរិស្ថាន	
១	ផ្តល់លិខិតអនុញ្ញាតបញ្ចេញសំណល់ការចេញពីទីតាំងអាជីវកម្ម ចំណុះតិចជាង៥០ម៉ែត្រគូប/ថ្ងៃ(តម្រូវឱ្យស្នើសុំ)
២	ផ្តល់លិខិតអនុញ្ញាតបញ្ចេញសំណល់រឹងចេញពីទីតាំងអាជីវកម្ម(តម្រូវឱ្យស្នើសុំ)

ល.រ	បរិយាយ
៩. ទិន្នន័យសង្ខេបសកម្ម និងទិន្នន័យបញ្ចូលសកម្ម	
១	ការជ្រើសរើសសហគ្រាស និងសិប្បកម្មដែលមានដើមទុនក្រោម២០០លានរៀល(៥០ ០០០ដុល្លារ) ដែលគ្មានហានិភ័យ
២	ការចេញវិញ្ញាបនបត្រជំនាញការសិប្បកម្ម(ថ្មី ឬបន្ត) ដែលមានដើមទុនក្រោម២០០លានរៀល (៥០ ០០០ដុល្លារ)
៣	ការចេញលិខិតអនុញ្ញាតពង្រីកសិប្បកម្ម ឬប្តូរទីតាំង ឬប្តូរម្ចាស់ ឬប្តូរឈ្មោះ ឬទុនិយភាពដែលមានដើមទុនក្រោម២០០លានរៀល(៥០ ០០០ដុល្លារ)
៤	ការត្រួតពិនិត្យផ្ទៀងផ្ទាត់ប្រភេទឧបករណ៍មាត្រសាស្ត្រដែលត្រូវបានប្រើសម្រាប់ការធ្វើអាជីវកម្ម(គិត១ឯកតានៃឧបករណ៍)
៤.១	**ផ្នែកទម្ងន់**
	ជញ្ជីងមិនស្វ័យប្រវត្តិ
	- ទម្ងន់តិចជាង ឬស្មើ១០គីឡូក្រាម(សម្រាប់ជញ្ជីងដាក់តាំងលក់)
	- ទម្ងន់លើសពី១០គីឡូក្រាម ដល់១០០គីឡូក្រាម(សម្រាប់ជញ្ជីងដាក់តាំងលក់)
	- ទម្ងន់លើសពី១០០គីឡូក្រាម ដល់១ ០០០គីឡូក្រាម
៤.២	**ឧបករណ៍បែងចែកវត្ថុរាវ(ប្រេងឥន្ធនៈ និងហ្គាស)**
	- ដៃបាញ់ប្រេងចំនួន១(តាមស្ថានីយ)
	- ធុងហ្គាស(អប្បបរមារ ៧គីឡូក្រាម)
	- ធុងហ្គាស(១៥ គីឡូក្រាម)
	- ធុងហ្គាស(លើសពី១៥ គីឡូក្រាម)
	- ដែរវៃបូមប្រេងចំនួន១
៥	**ត្រួតពិនិត្យផ្ទៀងផ្ទាត់បរិមាណ និងផ្ទាកសញ្ញាមាត្រាសាស្ត្រលើទំនិញផលិត និងទំនិញដចខ្ចប់**
៥.១	**ទំនិញផលិត**
	+ កាយនកិណ្ណ(មួយមុខផលិតផល)
	- សំលៀកបំពាក់
	- កំរាលព្រំ
	សម្ភារៈសំណង់(មួយមុខផលិតផល)
	បរិក្ខាអេឡិចត្រូនិច និងអុបទិក(មួយមុខផលិតផល)
៥.២	**ទំនិញដចខ្ចប់**
	+ ជាតុស្ងួន ផលិតផលចំណីអាហារ និងវត្ថុរាវគ្រប់ប្រភេទ(មួយមុខផលិតផល)
	- តិចជាង ឬស្មើ ៥គីឡូក្រាម ឬលីត្រ
	- លើសពី៥គីឡូក្រាម ឬលីត្រ ដល់១០គីឡូក្រាម ឬលីត្រ
	- លើសពី១០គីឡូក្រាម ឬលីត្រ ដល់២០គីឡូក្រាម ឬលីត្រ
	- លើសពី២០គីឡូក្រាម ឬលីត្រ ដល់៣០គីឡូក្រាម ឬលីត្រ
	- លើសពី៣០គីឡូក្រាម ឬលីត្រ ដល់៥០គីឡូក្រាម ឬលីត្រ

ល.រ	ហិរញ្ញវត្ថុ
	- លើសពី ៤០តឺឡូក្រាម ឬលើត្រែ
	- សំណើមក្នុងគ្រាប់ធញ្ញជាតិ
	- ភាពក្លីលើគ្រាប់ធញ្ញជាតិ
	+ ផលិតផលថ្នាំជក់ និងក្រដាស(មួយមុខផលិតផល)
	+ ផលិតផលគីមី
	- សាប៊ូដុំ ម្សៅសាប៊ូ គ្រឿងសំអាត ប៉ូលាគ្រឿងក្រអូប ឬគ្រឿងសំអាង
	- ថ្នាំសម្លាប់សត្វល្អិត ឬជីគីមីកសិកម្ម
	- ថ្នាំលាបពណ៌ វ៉ែនឺ ថ្នាំទ្រនាប់ ទឹកថ្នាំបោះពុម្ព ឬម៉ាស៊ូក
១០. ទីសំយោគ និងជាងកែច	
១	**ការផ្តល់អាជ្ញាប័ណ្ណជនជាតិ**
	- សេវាពិនិត្យ រៀបចំ និងដំណើរការឯកសារសម្រាប់ការផ្តល់អាជ្ញាប័ណ្ណសិប្បកម្មជនជាតិ និងអាជីវកម្មជនជាតិខ្នាតតូច(ការជាក់ពាក្យស្នើសុំ និងដំណើរការឯកសារ) ស្របតាមការកំណត់របស់ក្រសួងពាណិ និងជាមពល
	- សេវាពិនិត្យ រៀបចំ និងដំណើរការឯកសារសម្រាប់ការផ្តល់លិខិតអនុញ្ញាតលើសកម្មភាពធ្វើអាជីវកម្មដីកយកអាចម៍ដីសម្រាប់ប្រើប្រាស់ក្នុងមូលដ្ឋានដែលមានទំហំផ្ទៃក្រឡាមិនលើសពី ៣០០ម៉ែត្រក្រឡា និងជម្រៅមិនលើសពី ៣ម៉ែត្រ
២	**ការចុះបញ្ជីអាជ្ញាប័ណ្ណ**
	- អាជ្ញាប័ណ្ណសិប្បកម្មជនជាតិ និងអាជីវកម្មជនជាតិខ្នាតតូច
៣	**ការពិនិយអន្តរការណ៍ជាប្រាក់**
	ករណីដំណើរការដោយអាជ្ញាប័ណ្ណជនជាតិផុតសុពលភាពចំពោះ៖ - អាជ្ញាប័ណ្ណសិប្បកម្ម - អាជ្ញាប័ណ្ណអាជីវកម្មជនជាតិខ្នាតតូច
១១. ទីសំយោគជាជំនួញ	
១	ការចេញលិខិតអនុញ្ញាតប្រកបអាជីវកម្មលោហៈជាតុត្បូងថ្មមានតម្លៃជាងគ្រឿងអលង្ការ
២	ការចេញលិខិតអនុញ្ញាតបិទស្លាកថ្លៃជារូបិយប័ណ្ណបរទេស
១២. ទីសំយោគប្រៃសណីយ៍ ឧស្សាហកម្ម និងសង្គម	
	ក. សេវាអប្រិយសាស្ត្រ និងតួមិសាស្ត្រ
១	ការចុះបញ្ជីដីលើកដំបូង ដែលមានលក្ខណៈជាប្រព័ន្ធ(ក្នុង១ម^{2})
២	ការចុះបញ្ជីដីលើកដំបូងមានលក្ខណៈជាច់ដោយដុំ និងចេញប័ណ្ណ(ក្នុង១ក្បាលដី)
៣	ការផ្ទេរអចលនវត្ថុទាំងមូល(ក្នុង១ប័ណ្ណ)
៤	ការបំបែកក្បាលដីដោយផ្ទេរ ឬដោយមិនផ្ទេរអចលនវត្ថុ(ក្នុង១ក្បាលដីដែលបំបែក) និងការបង្រួមក្បាលដី(ក្នុង១ក្បាលដីដើម) (តាមការស្នើសុំ)
៥	ការស្វែងរកចំណាចត្រង់ដីឡើងវិញ(ក្នុង១បង្គោល)

ល.រ	បរិយាយ
៦	ការចេញលិខិតបញ្ជាក់ព័ត៌មានសុរិយោដីក្នុង១ក្បាលដី (ការចេញលិខិតបញ្ជាក់ ការចេញសំណៅប័ណ្ណ ព័ត៌មាន ការចេញលិខិតបញ្ជាក់សុរិយោដី)
៧	ការដាក់បន្ទុក និងការលើកលែង ៖ ឯកសិទ្ធិ ការដាក់បញ្ចាំ និងការដាក់ហ៊ីប៉ូតែក (ក្នុង១ក្បាលដី ឬ១ប័ណ្ណ)
៨	ការថតចម្លងឯកសារសុរិយោដី (ក្នុង១ទំព័រក្រដាស A4)
៩	ការប្តូរប្រភេទដី (ក្នុង១ម^{2})
១០	ការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ (ក្នុង១ចំណែកឯកជន)
១១	ការចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ (ក្នុង១ប័ណ្ណ)
១២	ការចុះបញ្ជីសិទ្ធិសម្បទានដីសេដ្ឋកិច្ច (ក្នុង១ប័ណ្ណ)
១៣	ការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី (ក្នុង១ប័ណ្ណ)
១៤	ផែនទីជាក្រដាស (ក្នុង១សន្លឹក)
១៥	ប្រថពតអ័ក្សហ្គុក ទំរង់ជាឌីជីថល (ក្នុង១គ.ម^{2})
១៦	ប្រថពតអ័ក្សហ្គុកទំរង់ជាក្រដាស (ចោះពុម្ពជាក្រដាសខ្នាតA0) ក្នុង០១សន្លឹក
១៧	ទិន្នន័យបង្គោលប្រថពតីភាគ (ប្លង់ទីតាំង និងនិយមកា) តឹតក្នុង០១បង្គោល (តាមការស្នើសុំ)
	ខ. សេវាសំណង់
១	លិខិតអនុញ្ញាតសាងសង់សំណង់លំនៅដ្ឋានដែលមានក្រឡាផ្ទៃសំណង់ទំហំ ≤៣០០០ម^{2}
២	សំណង់អគារផ្សេងៗក្រៅពីលំនៅដ្ឋានដែលមានក្រឡាផ្ទៃសំណង់ទំហំ ≤៣០០០ម^{2}
៣	សំណង់ផ្ទៃ សំណង់សប្បុរសជន ឬអង្គការមនុស្សធម៌ អំណោយដូនសហគមន៍ ឬជនក្រីក្រ ដែលមានក្រឡាផ្ទៃសំណង់ទំហំ ≤៣០០០ម^{2}
៤	ការផ្តល់គោលការណ៍សាងសង់ និងអភិវឌ្ឍន៍ដី
	ក. ការចុះបញ្ជីសេវាសាធារណៈ-ប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីសំណង់ ទ្រព្យសម្បត្តិសិក្សាគម្រោងប្លង់ ដីធ្លីជាសំណង់
១	ចុះបញ្ជីលើកដំបូង និងបន្តសុពលភាពសម្រាប់ក្រុមជាងសំណង់
	ឃ. ការផ្តល់ចម្លងឯកសារប្លង់ ដីធ្លីផែនទី (តាមការស្នើសុំ)
១	ឯកសារស្នើសុំសាងសង់ (ក្នុង១ច្បាប់)
២	ប្លង់ស្ថាបត្យកម្ម ឬប្លង់គ្រឿងផ្ទៃសំណង់ (ក្នុង១ច្បាប់)
៣	ផែនទី ទំហំ A-4 (ក្នុង១សន្លឹក)
៤	ផែនទី ទំហំ A-3 (ក្នុង១សន្លឹក)
៥	ផែនទី ទំហំ A-2 (ក្នុង១សន្លឹក)
៦	ផែនទី ទំហំ A-1 (ក្នុង១សន្លឹក)
៧	ផែនទី ទំហំ A-0 (ក្នុង១សន្លឹក)
	ង. សេវាពិគ្រោះយោបល់លើផ្នែកម្ចាស់ ដីធ្លីបច្ចេកទេស (តាមការស្នើសុំ)
១	លើការងារទាក់ទងទៅនឹងដីធ្លី និងសំណង់ទូទៅ (សម្រាប់មួយករណី)

ល.រ	បរិយាយ
១៣. ទីសំយកសំភារ ក្នុងប្រមាប្បំ ឆិទនេសាង	
១	**ជលផល**
	- ចេញលិខិតអនុញ្ញាតធ្វើការងារប្បកម្ម
២	**ផលិតកម្ម និងបសុព្យាបាល**
២.១	**ចេញលិខិតអនុញ្ញាតប្រមូលទិញសត្វនិងផលិតផលមានដើមកំណើតពីសត្វ ប្រភេទ ខ**
	- បង្កើតសត្តឃាតដ្ឋាន
	- ជ្រើអាជីវកម្មពិឃាតសត្វ
	- បង្កើតកន្លែងប្រមូលផ្តុំសត្វ
	- បង្កើតកន្លែងផលិត ឬលាយផ្សំចំណីសត្វ
	- បង្កើតកន្លែងផលិត តែថ្នែសាច់និងផលិតផលសត្វបឋម
	- បង្កើតកសិកដ្ឋានចិញ្ចឹមសត្វ
	- បង្កើតកន្លែងលក់សត្វកំដរ
	- បង្កើតកន្លែងពិនិត្យនិងព្យាបាលសត្វ
	- បង្កើតកន្លែងលក់បសុឱសថ និងសម្ភារៈ បរិក្ខាបសុពេទ្យ-ចំណីសត្វ
	- បង្កើតកន្លែងស្កុកនិងចែកចាយសាច់
	- បង្កើតកន្លែងឃ្យាំងស្កុកស្បែកគោក្របី
២.២	**សោហ៊ីយសោកម្មត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ និងការប្រមូលកម្រៃសោកម្មត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វនៅសត្តឃាតដ្ឋាន "ចាយក្នុងផ្ទៃប្រទេស"**
	សោត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ៖
	ក. សត្វ
	- សត្វចតុប្បាទស្រុកធំ(ពេញវ័យ)៖ គោ ក្របី សេះ...(ក្បាល)
	- សត្វចតុប្បាទស្រុកធំ(កូន)៖ គោ ក្របី សេះ...(ក្បាល)
	- សត្វចតុប្បាទតូច(ពេញវ័យ)៖ ជ្រូក ពពែ ចៀម...(ក្បាល)
	- សត្វចតុប្បាទតូច(កូន)៖ ជ្រូក ពពែ ចៀម...ចំពោះកូនជ្រូកមានទម្ងន់តិចជាង ៣០គ.ក្រ(ក្បាល)
	- បក្សីស្រុក(ពេញវ័យ)៖ មាន់ ទា មាន់បារាំង ក្រួច ...(ក្បាល)
	- បក្សី(កូន)៖ មាន់ ទា មាន់បារាំង ក្រួច ...ទម្ងន់តិចជាង ១៨៥ក្រាម(ក្បាល)
	- ស៊ុតបក្សីសម្រាប់ភ្ញាស់(ក្បាល)
	- ទឹកកាមសត្វ(ភាំរែត)
	- អំប្រីយ៉ុងសត្វ(ក្បាល)
	ខ. សាច់ និងផ្នែកបន្ទាប់បន្សំដទៃទៀតរបស់សត្វដែលអាចបរិភោគបាន "ចាយក្នុងផ្ទៃប្រទេស"
	- សាច់សត្វ ឬបក្សីទាំងមូល សាច់សត្វ ឬបក្សីពុះជា២ផ្នែក សាច់សត្វ ឬបក្សីកាប់ជាដុំ សាច់ជាប់ឆ្អឹង សាច់កាប់ជាប់ឆ្អឹង សាច់សុទ្ធ(គ្មានជាប់ឆ្អឹង) និងផ្នែកបន្ទាប់បន្សំដទៃទៀត ស្រស់ ឬរក្សាទុកក្នុងទឹកត្រជាក់ ឬបង្កក(គ.ក្រ)
	- សាច់ងៀត សាច់ក្រក ម្សៅសាច់ ស្បែកជ្រូកក្រៀម(គ.ក្រ)

ល.រ	បរិយាយ
	- ខ្លាញ់សត្វគ្រប់ប្រភេទ មិនទាន់ចំរាញ់ នៅស្រស់ បង្កក ប្រឡាក់ ត្រាំទឹកអំបិល ពពែ ឬ កក(គ.ក្រ)
	- ទឹកដោះស្រស់(លីត្រ)
	- ស៊ុតស្រស់ ប្រៃ កំណកក្មេង សម្ងួត ចំអិន និងបង្កក(គ្រាប់)
	ឧ. ផលិតផលមានដើមកំណើតពីសត្វសម្រាប់ប្រើក្នុងផ្នែកផ្សេងៗ ដែលមិនអាចបរិភោគបាន "បានចេញផ្ទៃប្រទេស"
	- ស្បែកស្រស់ប្រឡាក់អំបិល ឬ ស្ងួត(គ.ក្រ)
	- ផ្នែកបន្ទាប់បន្សំដទៃទៀតរបស់សត្វ ដុះជា ឈាមស្រស់ ម្សៅឈាម ធ្មេញ ម្សៅធ្មេញ...(គ.ក្រ)
	- ចំណីសត្វ(គ.ក្រ)
២.៣	**សេវាត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វនៅសត្តឃាតដ្ឋាន**
២.៤	**ប្រាក់រង្វាន់លើកទឹកចិត្តដល់មន្ត្រីដែលបានចូលរួមបង្ក្រាបបទល្មើសអនាម័យសត្វសាច់និងផលិតផលមានដើមកំណើតពីសត្វ**
	- ប្រាក់រង្វាន់បង្ក្រាបបទល្មើសអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ និងប្រាក់រង្វាន់បង្ក្រាបបទល្មើសអនាម័យសត្វ សាច់ និងផលិតផលសត្វនៅសត្តឃាតដ្ឋាន
៣	**នីតិកម្មកសិកម្ម**
៣.១	**តម្លៃសេវាកម្មលើការចេញលិខិតអនុញ្ញាតលក់ដុំលក់រាយថ្នាំកសិកម្ម ឬជីកសិកម្ម** - តម្លៃលើការចេញលិខិតអនុញ្ញាតសម្រាប់ជីកសិកម្មតាមបរិមាណស្នើសុំធ្វើប្រតិបត្តិការប្រចាំឆ្នាំ - តម្លៃលើការចេញលិខិតអនុញ្ញាតសម្រាប់ថ្នាំកសិកម្មតាមបរិមាណស្នើសុំធ្វើប្រតិបត្តិការប្រចាំឆ្នាំ - ការស្នើសុំលិខិតអនុញ្ញាតលក់ដុំលក់រាយចម្រុះនូវថ្នាំកសិកម្ម និងជីកសិកម្ម
៤	**តម្លៃសេវាកម្មលើដំណើរការឆ្លងវត្តអប់រំសមត្ថភាពវិជ្ជាជីវៈ សម្រាប់អ្នកផ្គត់ផ្គង់ចែកចាយ អ្នកលក់ដុំលក់រាយ និងប្រតិបត្តិការគម្លាត់សមាសភាពចង្រៃ**
	- ដំណើរការឆ្លងវត្តអប់រំសមត្ថភាពវិជ្ជាជីវៈ(ចេញវិញ្ញាបនបត្របញ្ជាក់ការឆ្លងវត្ត)
១៥. តំរង់ការចារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	
១	ការផ្តល់ប័ណ្ណការងារ និងសៀវភៅការងារបស់ជនភៀជា
២	ការចេញលិខិតទទួលស្គាល់ការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក
៣	ការចុះបញ្ជីការសំណុំបែបបទស្តីពីត្រីះស្ថាន
៤	លិខិតអនុញ្ញាតធ្វើការបន្តែមម៉ោង

តារាងទី២

សេចក្តីជូនដំណឹងរបស់ក្រុមប្រឹក្សាឃុំ ស្រុក ខេត្ត

ស្តីពីការបង្កើតយន្តការទទួលពាក្យបណ្តឹងសម្រាប់ការផ្តល់សេវាជូនដល់ប្រជាពលរដ្ឋ

លរ	បរិយាយ
១. ការបោះពិគ្រោះគុណភាព(ការចេញប័ណ្ណលើឯកសារចម្លង)	
១	ប័ណ្ណបន្តបត្របញ្ជាក់ការសិក្សា
២	ប័ណ្ណបន្តបត្របណ្តោះអាសន្ន មធ្យមសិក្សាកម្រិត១
៣	ប័ណ្ណបន្តបត្របណ្តោះអាសន្ន មធ្យមសិក្សាកម្រិត២
៤	ប័ណ្ណបន្តបត្របណ្តោះអាសន្ន មធ្យមសិក្សាបឋមភូមិ
៥	ប័ណ្ណបន្តបត្របណ្តោះអាសន្ន មធ្យមសិក្សាទុតិយភូមិ
៦	ប័ណ្ណបន្តបត្របញ្ជាក់ការសិក្សាថ្នាក់ទី១២
៧	ប័ណ្ណបន្តបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម
៨	ប័ណ្ណបន្តបត្រប្រកបអាជីវកម្ម
៩	បណ្ណប៉ាតង់
១០	ប័ណ្ណបន្តបត្រ
១១	លិខិតផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលមិនទាន់ចុះបញ្ជី
១២	លិខិតបញ្ជាក់លទ្ធផលនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាកម្រិត១
១៣	សញ្ញាបត្រមធ្យមសិក្សាកម្រិត២ (បំពេញថ្នៃ)
១៤	សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ
១៥	សញ្ញាបត្រមធ្យមសិក្សាគរុកោសល្យ
១៦	សញ្ញាបត្រមធ្យមសិក្សា
១៧	សញ្ញាបត្រគ្រូបង្រៀនកម្រិតឧត្តម
១៨	ព្រឹត្តិបត្រលទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ
១៩	បណ្ណាបត្រ
២០	បណ្ណាបត្ររង
២១	លិខិតបញ្ជាក់ការសិក្សា
២២	អត្តសញ្ញាណប័ណ្ណ
២៣	សៀវភៅស្នាក់នៅ/សៀវភៅគ្រួសារ
២៤	បណ្ណសំគាល់យានយន្ត
២៥	បណ្ណបើកបរជយន្ត

ល.រ	បរិយាយ
២៦	ព្រឹត្តិបត្រពិន្ទុ
២៧	ពាក្យសុំបញ្ជាក់សញ្ញាបត្រមធ្យមសិក្សាភម្រិត២ ចំណេះដឹងទូទៅ
២៨	វិញ្ញាបនបត្របណ្តោះអាសន្នថ្នាក់បរិញ្ញាបត្រ
២៩	វិញ្ញាបនបត្របណ្តោះអាសន្នថ្នាក់បរិញ្ញាបត្ររង
២. ការងារអចលនៈ	
១	ការចេញលិខិតអនុញ្ញាតបំពេញអាចម៍ដីតម្លៃដីឯកជនក្រោម១០០០ម៉ែត្រការ៉េ
៣. ការផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលតុំងាល់ទុះបញ្ចី	
១	ដី
	- ដីក្នុងរាជធានីភ្នំពេញ ឬក្នុងក្រុងនៃខេត្តកណ្តាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប
	- ដីក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្តាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប
	- ដីក្រៅក្រុង ឬជនបទ
២	លំនៅដ្ឋាន(ក្រៅពីភូមិគ្រឹះ)
	- ដីក្នុងរាជធានីភ្នំពេញ ឬក្នុងក្រុងនៃខេត្តកណ្តាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប
	- ដីក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្តាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប
	- ដីក្រៅក្រុង ឬជនបទ
៣	ភូមិគ្រឹះ
	- ដីក្នុងរាជធានីភ្នំពេញ ឬក្នុងក្រុងនៃខេត្តកណ្តាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប
	- ដីក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្តាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប
	- ដីក្រៅក្រុង ឬជនបទ
៤. ការខោះខាតគ្រោងទុកលេខដួង	
១	សេចក្តីចម្លងសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត
២	សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍
៣	សេចក្តីចម្លងសំបុត្រមរណភាព ឬសំបុត្របញ្ជាក់មរណភាព
៥. ទីតំណែងអំពី ឃុ.ស.ជ ឱ.ក.ស.ស	
១	អាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតបើក បន្តសុពលភាពសាលា ឬថ្នាក់មតេយ្យសិក្សាឯកជន(កម្មវិធីជាតិ)
២	អាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតបើក បន្តសុពលភាពសាលា ឬថ្នាក់មតេយ្យសិក្សាឯកជន(កម្មវិធីអន្តរជាតិ)
៣	អាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតបើក បន្តសុពលភាពថ្នាក់បណ្តុះបណ្តាលជំនាញ និងភាសាបរទេសត្រួតខ្លឹ២ និងជាង១ឆ្នាំ
៤	អាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតបើក បន្តសុពលភាពក្លឹបហាត់ប្រាណ
៥	អាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតបើក បន្តសុពលភាពអាជីវកម្មលក់សម្ភារៈកីឡា
៦. ទីតំណែងសុខាភិបាល	
១	លិខិតអនុញ្ញាតស្នើសុំបើកថ្មី បន្តសុពលភាព និងប្តូរទីតាំងបន្ទប់ពិនិត្យស្តីមានផ្ទៃពោះមុន និងក្រោយសម្រាល

ល.រ	បរិយាយ
២	លិខិតអនុញ្ញាតស្នើសុំបើកថ្មី បន្តសុពលភាព និងប្តូរទីតាំងបន្ទប់ព្យាបាលដោយចលនា
៣	លិខិតអនុញ្ញាតស្នើសុំបើកថ្មី បន្តសុពលភាព និងប្តូរទីតាំងបន្ទប់ថែទាំជម្ងឺ
៤	លិខិតអនុញ្ញាតស្នើសុំបើកថ្មី បន្តសុពលភាព និងប្តូរឈ្មោះឱសថការីនៃឱសថស្ថានរង ក
៥	លិខិតអនុញ្ញាតបន្តសុពលភាពឱសថស្ថានរង ខ
៦	លិខិតអនុញ្ញាតស្នើសុំបើកថ្មី បន្តសុពលភាព និងប្តូរទីតាំងបន្ទប់ពិគ្រោះព្យាបាលជំងឺមាត់ធ្មេញ
៧	លិខិតអនុញ្ញាតស្នើសុំបើកថ្មី បន្តសុពលភាព និងប្តូរទីតាំងបន្ទប់ពិគ្រោះជំងឺទូទៅ
៨	ការផ្តល់វិញ្ញាបនបត្របញ្ជាក់អនាម័យចំណីអាហារតាមភោជនីយដ្ឋាន និងអាហារដ្ឋានដែលមានចំណុះចាប់ពី៥០កៅអីចុះក្រោម
៧. ទិស់យនេសចរណ៍	
១	ផ្ទះសំណាក់ចាប់ពី០៨បន្ទប់ ចុះក្រោម
២	ផ្ទះជួលបន្ទប់ស្នាក់នៅ
៣	ភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍ ចាប់ពី៥០នាក់ ចុះក្រោម
៤	ភោជនីយដ្ឋាន និងអាហារដ្ឋានក្នុងស្រុក
៥	តូបលក់អាហារ
៦	ហាងលក់គុយទាវ កាហ្វេ
៧	ម៉ាស្សា ចាប់ពី០៥ត្រែ ឬចាប់ពី០៥កៅអី ចុះក្រោម
៨	ខារ៉ាអូរខ ចាប់ពី០៥បន្ទប់ ចុះក្រោម
៩	ស្នូកយ៉ា ចាប់ពី០៥តុ ចុះក្រោម
១០	រថយន្តជឹកទេសចរណ៍ ចំណុះចាប់ពី០៥កៅអី ចុះក្រោម
១១	ម៉ូតូឌុបទេសចរណ៍
១២	ម៉ូតូជួលទេសចរណ៍
១៣	រ៉ឺម៉កម៉ូតូជឹកទេសចរណ៍
៨. ទិស់យជីកជញ្ជូន	
១	**សេវាកម្មម៉ូតូ**
	- ចុះបញ្ជីថ្មី
	- ប្តូរប័ណ្ណសម្គាល់ (ពណ៌ លេខម៉ាស៊ីន)
	- ទុតិយាតាប័ណ្ណសម្គាល់
	- តតិយតាប័ណ្ណសម្គាល់
	- ទុតិយាតាស្លាកលេខ
	- តតិយតាស្លាកលេខ
២	**សេវាកម្មត្រីចក្រយានយន្ត ឬរ៉ឺម៉ក**
	- ចុះបញ្ជីត្រីចក្រយានយន្ត
	- ចុះបញ្ជីរ៉ឺម៉ក (ទោចក្រយានយន្ត)

ល.រ	បរិយាយ
	- ប្តូរ ទុតិយតា ឬតតិយតាប័ណ្ណសម្គាល់ត្រីចក្រយានយន្ត
	- ប្តូរ ទុតិយតា ឬតតិយតាផ្នាកលេខត្រីចក្រយានយន្ត
៣	**ការត្រួតពិនិត្យលក្ខណៈបច្ចេកទេសត្រីចក្រយានយន្ត**
	- ត្រីចក្រយានយន្ត ឬទោចក្រយានយន្តសណ្តោងរ៉ឺម៉ក
	- ទុតិយតា ឬតតិយតា ក្បាលបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេស
៤	**ត្រីចក្រយានយន្ត ឬ ទោចក្រយានយន្តសណ្តោងរ៉ឺម៉ក**
	- ការផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូន
	- ត្រីចក្រយានយន្ត
៥	**រ៉ឺម៉កសណ្តោងជាយោទាចក្រយានយន្ត**
	- ការបន្តលិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូន
	- ត្រីចក្រយានយន្ត
៤. ទីសំយោគឧស្សាហ៍ ដំណើរទេសចរណ៍ៈ	
១	**កម្មវិធីសម្តែងផ្សេងៗ (ក្រៅផ្លូវការ)**
	- ការប្រគំតន្ត្រីនៅទីសាធារណៈលក្ខណៈជាតិ
	- ការសម្តែងទស្សនីយភាពល្ខោន លក់សំបុត្រ
	- ការសម្តែងល្ខោនគ្រប់ទម្រង់
	- អាជីវកម្មរាំកំសាន្ត លក់សំបុត្រ
២	**ការបញ្ចាំងភាពយន្ត វីដេអូ**
	- ការបញ្ចាំងភាពយន្ត វីដេអូ ផ្សាយពាណិជ្ជកម្ម
	- ការបញ្ចាំងភាពយន្ត វីដេអូ កំដរពិធីបុណ្យផ្សេងៗ
	- ការបញ្ចាំងភាពយន្ត វីដេអូ កំដរភ្ញៀវ
៣	**អាជីវកម្មលក់ ជួលស្តាំងភាពយន្ត វីដេអូ**
	- ហាងលក់ ជួលស៊ីឌី ស៊ែស៊ីឌី ឌីវីឌី
	- អនាលក់ស៊ីឌី ស៊ែស៊ីឌី ឌីវីឌី
៤	**ស្លាកសញ្ញាអាជីវកម្ម**
	- ផ្ទាំងយីហោគ្រប់ប្រភេទ ទំហំក្រោម២ម៉ែត្រការ៉េ
	- ផ្ទាំងយីហោគ្រប់ប្រភេទ ទំហំចាប់ពី២ម៉ែត្រការ៉េ ដល់៤ម៉ែត្រការ៉េ
	- បដ្ឋាប្រកាសផ្សាយពាណិជ្ជកម្ម(Poster)
	- ផ្ទាំងរូបភាព និមិត្តសញ្ញាផ្សេងៗ ទំហំក្រោម២ម៉ែត្រការ៉េ
	- ផ្ទាំងរូបភាព និមិត្តសញ្ញាផ្សេងៗ ទំហំចាប់ពី២ម៉ែត្រការ៉េ ដល់៤ម៉ែត្រការ៉េ
	- បដ្ឋាផ្សាយពាណិជ្ជកម្ម
៥	**ការផ្តល់អាជ្ញាប័ណ្ណ**
	- ជំលិតស្លាកសញ្ញា ផ្ទាំងសញ្ញា ផ្ទាំងផ្សាយពាណិជ្ជកម្ម
៦	**អាជីវកម្មគ្រឿងបំពងសំឡេង**
	- ជួលធុងចាស់ និងឧបករណ៍សនសព្ទ

ល.រ	បរិយាយ
៣	**អាជីវកម្មលក់សៀវភៅ**
	- បណ្ណាគារដែលមានផ្ទៃក្រឡាក្រោម៥០មែត្រការ៉ែ
៤	**អាជីវកម្មសិល្បៈសូនរូប**
	- ទីតាំងផលិត និងលក់ចម្លាក់ ពុម្ពស៊ីម៉ង់ត៍
	- ទីតាំងផលិត លក់ចម្លាក់ម្នាងសិលា
	- ជាងគំនូរ
៥	**អាជីវកម្មថតរូប**
	- អគារផ្ទិតរូប ថតរូប ថតវីដេអូ
	- ផ្ទះថតរូប ផ្ទិតរូប ថតវីដេអូ
១០	**អាជីវកម្មកាត់សក់ អ៊ុតសក់ លម្ពក្រចក និងសម្ពាងការ (ហាង)**
	- កាត់សក់បុសេ(ចាប់ពី២ភៅអី ទៅ៤ភៅអី)
	- កាត់សក់បុសេ(ចាប់ពី៥ភៅអី ឡើងទៅ)
	- អ៊ុតសក់ កាត់សក់ លម្ពក្រចក(ចាប់ពី២ភៅអី ទៅ៤ភៅអី)
	- អ៊ុតសក់ កាត់សក់ លម្ពក្រចក(ចាប់ពី៥ភៅអី ឡើងទៅ)
	- សម្ពាងការ(ថ្លៃឈ្នួលក្រោម៥០០ដុល្លារអាមេរិក)
	- សម្ពាងការ(ថ្លៃឈ្នួលចាប់ពី៥០០ដុល្លារអាមេរិក ដល់ក្រោម១ ០០០ដុល្លារអាមេរិក)
	- សម្ពាងការ(ថ្លៃឈ្នួលចាប់ពី១ ០០០ដុល្លារអាមេរិកឡើងទៅ)
១០. ទិស៍យឧស្សាហកម្ម ពិធីសិប្បកម្ម ពិធីទិស៍យរៀ ពិធីទាមពល	
១	**ចុះបញ្ជីសិប្បកម្ម**
	- កែច្នៃក្រណាត់ ស្បែក ភៅស្ងួ ប្លាស្ទិក
	- កែច្នៃស័ង្គសី អាលុយមីញ៉ូម ដែក កញ្ចក់
	- កែច្នៃរតនវត្ថុ
	- ផលិតធើងតាង ពាង លូ ឥដ្ឋការ៉ូ
	- ធ្វើឡៀន ធូប
២	**ថាមពល**
	- ដំឡើងម៉ាស៊ីនអគ្គិសនីសម្រាប់ធ្វើសេវាកម្មបញ្ចូលអាគុយដែលមានកម្លាំងមិនលើសពី២៥គីឡូវ៉ាត់ (25KW)
៣	**សេវាកម្ម**
	- ជួសជុលគ្រឿងអគ្គិសនីអេឡិចត្រូនិក
	- លាងរថយន្ត ម៉ូតូ
	- លាងម៉ូតូ
១១. ទិស៍យពាណិជ្ជកម្ម	
	- លិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្មពាណិជ្ជកម្ម

ល.រ	បរិយាយ
១២. ទិសំយសំណង់	
១	លិខិតអនុញ្ញាតសាងសង់ដែលមានក្រឡាផ្ទៃសំណង់ទំហំ ≤៥០០ម២
២	លិខិតអនុញ្ញាតសាងសង់ពង្រីកបន្ថែម ព្រះរើ ជួសជុលដែលមានក្រឡាផ្ទៃសំណង់ទំហំ ≤៥០០ម២
៣	លិខិតអនុញ្ញាតបើកការដ្ឋានដែលមានក្រឡាផ្ទៃសំណង់ទំហំ ≤៥០០ម២
៤	លិខិតបិទការដ្ឋាន ឬញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវដែលមានក្រឡាផ្ទៃសំណង់ទំហំ ≤៥០០ម២
៥	សេវាកម្ម ជួសជុល និងសាងសង់របង(របងថ្ម/បេតុង)
១៣. ទិសំយកសិកម្ម	
១	លិខិតអនុញ្ញាតធ្វើអាជីវកម្មលក់ដុំ ពយ សម្ភារៈកសិកម្ម
២	ញ្ញាបនបត្រអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ២៤០ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការធ្វើប្រតិភូកម្មសិទ្ធិអំណាចទៅឱ្យគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ក្នុងការគ្រប់គ្រងបុគ្គលិកបំពេញការងារនៅថ្នាក់ក្រោមជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០១២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៨នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៩/១១ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា៥១នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៩ និងមាត្រា១០នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៧៣ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទីភារកិច្ច និងទំនាក់ទំនងរបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទីភារកិច្ច និងទំនាក់ទំនងរបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ២៨៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីនីតិវិធីសម្រាប់ការរៀបចំ ការកែប្រែ និងការលុបចោលដីការបស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ
- យោងតាមសំណើប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងប្រធានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

សម្រេច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

មាត្រា១ ..

អនុក្រឹត្យនេះមានគោលបំណងលើកកម្ពស់ប្រសិទ្ធភាព និងប្រសិទ្ធផលនៃការគ្រប់គ្រងបុគ្គលិកបំពេញការងារនៅថ្នាក់ក្រោមជាតិ តាមរយៈការធ្វើប្រតិភូកម្មសិទ្ធិអំណាចទៅឱ្យគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុកនិងការកែសម្រួលនីតិវិធីក្នុងការគ្រប់គ្រងបុគ្គលិកបំពេញការងារនៅថ្នាក់ក្រោមជាតិ។

មាត្រា២ ..

អនុក្រឹត្យនេះមានគោលដៅកំណត់អំពី ៖

- ការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- ការតែងតាំង និងការបញ្ចប់មុខតំណែងគ្រប់គ្រងរបស់មន្ត្រីរាជការស៊ីវិលនៃមន្ទីរ អង្គភាព និងការិយាល័យជំនាញនានានៃក្រសួងដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ។

មាត្រា៣ ..

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ត្រីរាជការស៊ីវិលនៃមន្ទីរ អង្គភាព និងការិយាល័យជំនាញនានានៃក្រសួងដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ លើកលែងតែមន្ត្រីរាជការស៊ីវិលក្រោមឱវាទនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកដ្ឋានពន្ធដារ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ និងមន្ត្រីរាជការដែលស្ថិតក្រោមបទប្បញ្ញត្តិដោយឡែករបស់រាជរដ្ឋាភិបាល។

មាត្រា៤ ៖

វាក្យសព្ទបច្ចេកទេសនៅក្នុងអនុក្រឹត្យនេះមានន័យដូចតទៅ៖

- **ប្រសិទ្ធផល** សំដៅដល់លទ្ធផលចុងក្រោយ ឬគុណភាពនៃលទ្ធផលដែលមានឥទ្ធិពល ឬផលប៉ះពាល់រយៈពេលវែង។
- **បុគ្គលិកបំពេញការងារនៅថ្នាក់ក្រោមជាតិ** សំដៅដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និងបុគ្គលិករបស់មន្ទីរ អង្គភាព និងការិយាល័យជំនាញនានានៃក្រសួង ស្ថាប័នដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ។
- **បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ** សំដៅដល់បុគ្គលិកជាមន្ត្រីរាជការស៊ីវិលដែលបានជ្រើសរើស និងតែងតាំងដោយរដ្ឋបាលថ្នាក់ក្រោមជាតិ បុគ្គលិកជាមន្ត្រីរាជការស៊ីវិលដែលបានផ្ទេរតាមដំណើរការនៃការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ បុគ្គលិកជាមន្ត្រីរាជការស៊ីវិលដែលត្រូវបានតែងតាំងឬចាត់តាំងដោយរាជរដ្ឋាភិបាល ក្រសួង ស្ថាប័នថ្នាក់ជាតិ ឱ្យទៅបំពេញការងារជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ និងបុគ្គលិកជាប់កិច្ចសន្យា បុគ្គលិកអណ្តែត និងទីប្រឹក្សាបច្ចេកទេសដែលបានជ្រើសរើសដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។

ជំពូកទី២
ការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

មាត្រា៥ ៖

ការគ្រប់គ្រងបុគ្គលិករបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលតម្រូវឱ្យមានការអនុម័តដោយក្រុមប្រឹក្សានៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក រួមមាន៖

- ការរៀបចំផែនការបុគ្គលិក
- ការតែងតាំង និងការបញ្ចប់មុខតំណែងនាយករងរដ្ឋបាលនិងនាយកទីចាត់ការ ឬ ប្រធានអង្គភាពដែលមានថ្នាក់ប្រហាក់ប្រហែលនៃរដ្ឋបាលរាជធានី ខេត្តសម្រាប់រដ្ឋបាលរាជធានី ខេត្ត។
- ការតែងតាំង និងការបញ្ចប់មុខតំណែងនាយករងរដ្ឋបាលនិងប្រធានការិយាល័យ ឬប្រធានអង្គភាពដែលមានថ្នាក់ប្រហាក់ប្រហែលនៃរដ្ឋបាលក្រុង ស្រុក សម្រាប់រដ្ឋបាលក្រុង ស្រុក
- ការកំណត់ប្រាក់ឧបត្ថម្ភរបស់បុគ្គលិក។

មាត្រា៦ ៖

ការគ្រប់គ្រងបុគ្គលិករបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលមិនតម្រូវឱ្យមានការអនុម័តដោយក្រុមប្រឹក្សានៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក រួមមាន៖

- ការជ្រើសរើសបុគ្គលិក
- ការធ្វើកម្មសិក្សា ការតាំងស៊ប់ និងការបញ្ឈប់កម្មសិក្សា
- ការតែងតាំង និងការបញ្ចប់មុខតំណែងគ្រប់គ្រងចាប់ពីនាយករងទីចាត់ការ ឬអនុប្រធានអង្គភាពដែលមានថ្នាក់ប្រហាក់ប្រហែលនៃរដ្ឋបាលរាជធានី ខេត្តចុះក្រោមសម្រាប់រដ្ឋបាលរាជធានី ខេត្ត។ ដោយឡែកសម្រាប់រដ្ឋបាលរាជធានីក្រៅពីមុខតំណែងខាងលើនេះត្រូវរួមបញ្ចូលទាំងមុខតំណែងចាប់ពីនាយករងរដ្ឋបាលនៃរដ្ឋបាលខណ្ឌចុះក្រោម
- ការតែងតាំង និងការបញ្ចប់មុខតំណែងគ្រប់គ្រងចាប់ពីអនុប្រធានការិយាល័យក្រុង ស្រុក ឬអនុប្រធានអង្គភាពដែលមានថ្នាក់ប្រហាក់ប្រហែលចុះក្រោមសម្រាប់រដ្ឋបាលក្រុង ស្រុក
- ការដំឡើងថ្នាក់និងហានន្តរស័ក្តិ

- ការផ្លាស់ប្តូរទីកន្លែងធ្វើការងារពីអង្គភាពមួយទៅអង្គភាពមួយនៅក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ
- ការដាក់ឱ្យស្ថិតនៅក្រៅក្របខ័ណ្ឌដើម ឬការដាក់ឱ្យនៅក្រៅតំណែង
- ការដាក់ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស
- ការដាក់ឱ្យចូលបម្រើការងារឡើងវិញ
- ការដាក់ឱ្យចូលនិវត្តន៍ ការដាក់ឱ្យបាត់បង់សម្បទាវិជ្ជាជីវៈ និងការស្នើសុំលាឈប់ពីការងារ
- ការដាក់ទណ្ឌកម្មខាងវិន័យ
- ការផ្ទេរពីរដ្ឋបាលថ្នាក់ក្រោមជាតិមួយទៅរដ្ឋបាលថ្នាក់ក្រោមជាតិមួយទៀតនិងការផ្ទេរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រសួង ស្ថាប័នថ្នាក់ជាតិ
- កិច្ចការពាក់ព័ន្ធនឹងការគ្រប់គ្រងបុគ្គលិកផ្សេងទៀត។

មាត្រា៧ ៖

ក្រសួងមុខងារសាធារណៈ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រោមការសម្របសម្រួលរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវរៀបចំ និងដាក់ចេញនូវសេចក្តីណែនាំស្តីពីគោលការណ៍ បែបបទ និងនីតិវិធីនៃការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

ជំពូកទី៣
ការតែងតាំង និងការបញ្ចប់មុខតំណែងគ្រប់គ្រងរបស់មន្ត្រីរាជការស៊ីវិលនៃមន្ទីរ អង្គភាព និងការិយាល័យជំនាញនានានៃក្រសួងដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ

មាត្រា៨ ៖

អភិបាលរាជធានី ខេត្ត ដោយមានការឯកភាពពីគណៈអភិបាលរបស់ខ្លួន ត្រូវលើកសំណើតែងតាំង និងបញ្ចប់មុខតំណែងប្រធានមន្ទីរ ឬប្រធានអង្គភាពជំនាញថ្នាក់ប្រហាក់ប្រហែលរបស់ក្រសួងដែលបំពេញការងារនៅរាជធានី ខេត្ត មករដ្ឋមន្ត្រីសាមី ដើម្បីពិនិត្យសម្រេច។

មាត្រា៩ ៖

ត្រូវបានធ្វើប្រតិភូកម្មសិទ្ធិអំណាចដល់គណៈអភិបាលរាជធានី ខេត្ត ក្នុងការតែងតាំងនិងការបញ្ចប់មុខតំណែងគ្រប់គ្រងរបស់មន្ត្រីរាជការស៊ីវិលនៃមន្ទីរ អង្គភាព និងការិយាល័យជំនាញនានារបស់ក្រសួងដែលបំពេញការងារនៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចាប់ពីអនុប្រធានមន្ទីរឬអនុប្រធានអង្គភាពថ្នាក់ប្រហាក់ប្រហែលចុះក្រោមតាមសំណើរបស់ប្រធានមន្ទីរឬអង្គភាពសាមី។

មាត្រា១០ ៖

ក្រសួងមុខងារសាធារណៈ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រោមការសម្របសម្រួលរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវរៀបចំ និងដាក់ចេញនូវសេចក្តីណែនាំស្តីពីគោលការណ៍ បែបបទ និងនីតិវិធីនៃការតែងតាំងនិងការបញ្ចប់មុខតំណែងគ្រប់គ្រងរបស់មន្ត្រីរាជការស៊ីវិលនៃមន្ទីរ អង្គភាព និងការិយាល័យជំនាញនានានៃក្រសួងដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ។

ជំពូកទី៤
ការរៀបចំ និងការដាក់ចេញដីកាដែលមានលក្ខណៈជាឯកត្តភូត
ក្នុងការគ្រប់គ្រងបុគ្គលិកបំពេញការងារនៅថ្នាក់ក្រោមជាតិ

មាត្រា១១ ៖

រាល់សេចក្តីសម្រេចនានាពាក់ព័ន្ធការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិដែលត្រូវធ្វើឡើងដោយដីការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមការកំណត់នៃព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិនិងអនុក្រឹត្យនេះ រដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថកិច្ច ត្រូវរៀបចំនិងដាក់ចេញដីកាមានលក្ខណៈជាឯកត្តភូត។

ដីកាដែលមានលក្ខណៈជាឯកត្តភូត ត្រូវចុះហត្ថលេខាដោយអភិបាលរាជធានី ខេត្ត ក្រុង ស្រុកមានសមត្ថកិច្ច បន្ទាប់ពីទទួលបានការអនុម័តពីក្រុមប្រឹក្សា ឬបន្ទាប់ពីទទួលបានការឯកភាពពីគណៈអភិបាល យោងតាមករណីដូចមានចែងក្នុងមាត្រា១២ និង១៣នៃអនុក្រឹត្យនេះ។

មាត្រា១២ ៖

ការដាក់ចេញដីកាដែលមានលក្ខណៈជាឯកត្តភូតសម្រាប់អនុវត្តន៍នូវសិទ្ធិអំណាចរបស់គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ក្នុងការគ្រប់គ្រងបុគ្គលិកដូចមានចែងក្នុងមាត្រា៦ និងមាត្រា៩នៃអនុក្រឹត្យនេះ ត្រូវចុះហត្ថលេខាដោយអភិបាលមានសមត្ថកិច្ច បន្ទាប់ពីមានការឯកភាពពីគណៈអភិបាល។

មាត្រា១៣ ៖

ការដាក់ចេញដីកាដែលមានលក្ខណៈជាឯកត្តភូតសម្រាប់ការគ្រប់គ្រងបុគ្គលិកដែលតម្រូវឱ្យមានការអនុម័តពីក្រុមប្រឹក្សានៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ដូចមានចែងនៅក្នុងមាត្រា៥នៃអនុក្រឹត្យនេះ ត្រូវចុះហត្ថលេខាដោយអភិបាលរាជធានី ខេត្ត ក្រុង ស្រុក បន្ទាប់ពីទទួលបានការអនុម័តពីក្រុមប្រឹក្សា។

ជំពូកទី៥
ការតាមដាន ការត្រួតពិនិត្យ និងការខាយតម្លៃ

មាត្រា១៤ ៖

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ត្រូវតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងផ្តល់គោលការណ៍ណែនាំដល់គណៈអភិបាលដើម្បីលើកកម្ពស់ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព យុត្តិធម៌ និងសមធម៌ក្នុងការគ្រប់គ្រងបុគ្គលិករដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក។

គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ត្រូវធ្វើរបាយការណ៍ជាទៀងទាត់ជូនកិច្ចប្រជុំក្រុមប្រឹក្សាអំពីស្ថានភាពនៃការគ្រប់គ្រងបុគ្គលិករដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក។

ក្នុងករណីគណៈអភិបាល បានដាក់ចេញនូវដីកាសម្រាប់ការគ្រប់គ្រងបុគ្គលិករដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក មិនស្របតាមគោលការណ៍ បែបបទ និងនីតិវិធីជាធរមាន ក្រុមប្រឹក្សា ត្រូវផ្តល់ការណែនាំដល់គណៈអភិបាលដើម្បីកែតម្រូវ ឬលុបចោលដីកាទាំងនោះ។

ក្នុងករណីដែលគណៈអភិបាលមិនព្រមចាត់វិធានការកែតម្រូវ ឬលុបចោលដីកាតាមការណែនាំ ក្រុមប្រឹក្សាត្រូវធ្វើសេចក្តីរាយការណ៍ជាលាយលក្ខណ៍អក្សរជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីមានវិធានការ។

មាត្រា១៥ ..

រាល់ដីកាពាក់ព័ន្ធនឹងការគ្រប់គ្រងបុគ្គលិក គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ត្រូវបញ្ជូនមក មន្ទីរមុខងារសាធារណៈរាជធានី ខេត្ត និង ចម្លងជូនក្រសួង ស្ថាប័ន អង្គភាពសាមី ដោយមានភ្ជាប់ឯកសារពាក់ព័ន្ធ។

ក្នុងករណីមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត ពិនិត្យឃើញថាដីកាខាងលើមិនសមស្របនឹងរចនាសម្ព័ន្ធមុខតំណែងនិងចំនួនមុខតំណែងគ្រប់គ្រង ឬ មិនស្របតាមបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងការគ្រប់គ្រងមុខងារសាធារណៈ មន្ទីរមុខងារសាធារណៈរាជធានី ខេត្ត មិនត្រូវរៀបចំការផ្លាស់ប្តូរស្ថានភាពរដ្ឋបាលរបស់មន្ត្រីរាជការស៊ីវិលក្នុងតារាងទូទាត់បៀវត្សឡើយ ហើយត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរដោយមានបញ្ជាក់អំពីមូលហេតុជូនអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ និង ប្រធានអង្គភាពសាមី ក្នុងរយៈពេលយ៉ាងយូរ០៧(ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានដីកាដើម្បីមានចំណាត់ការឱ្យសមស្របតាមបទប្បញ្ញត្តិជាធរមាន។

មាត្រា១៦ ..

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងក្រសួងមុខងារសាធារណៈត្រូវសម្របសម្រួលជាមួយក្រសួង ស្ថាប័ននានាដើម្បីរៀបចំនូវយន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តសិទ្ធិអំណាចដែលបានធ្វើប្រតិភូកម្មតាមស្មារតីនៃអនុក្រឹត្យនេះ ដើម្បីធានាថា ក្រុមប្រឹក្សានិងគណៈអភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុកអនុវត្តអំណាចក្នុងការគ្រប់គ្រងបុគ្គលិកដែលបំពេញការងារនៅថ្នាក់ក្រោមជាតិអនុលោមតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋាន គតិយុត្តជាធរមាន និងគោលការណ៍ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព សមធម៌ និងអព្យាក្រឹតភាពនៃមន្ត្រីរាជការស៊ីវិល។

ជំពូកទី៦

បទប្បញ្ញត្តិដោយឡែក

មាត្រា១៧ ..

បែបបទ និងនីតិវិធីនៃការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ត្រីរាជការស៊ីវិលនៃមន្ទីរអង្គភាព និងការិយាល័យជំនាញនានានៃក្រសួងដែលបំពេញការងារនៅថ្នាក់ក្រោមជាតិក្រោមបទប្បញ្ញតិនានានៃអនុក្រឹត្យនេះមិនត្រូវអនុវត្តចំពោះការគ្រប់គ្រងបុគ្គលិកជាមន្ត្រីរាជការស៊ីវិលដែលត្រូវបានតែងតាំង ឬ ចាត់តាំងដោយរាជរដ្ឋាភិបាល ឬដោយក្រសួង ស្ថាប័នថ្នាក់ជាតិឱ្យទៅបំពេញការងារជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ និងត្រូវអនុវត្តតាមបែបបទ និងនីតិវិធីជាធរមាន។

ជំពូកទី៧
អវសានប្បញ្ញត្តិ

មាត្រា១៨ .-

អនុក្រឹត្យលេខ៨៩៧ អនក្រ.បក ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការធ្វើប្រតិភូកម្មអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

មាត្រា១៩ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ១០កើត ខែ បុស្ស ឆ្នាំ ឆស័ ព.ស២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ៤៩ ខែ ធ្នូ គ.ស២០១៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី សូមហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
និងជាប្រធានក.ជ.អ.ប

សម្តេចក្រឡាហោម ស ខេង

រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ
និងជាប្រធានគណៈកម្មាធិការ
កែទម្រង់រដ្ឋបាលសាធារណៈ

ពេជ្រ ប៊ុនធិន

កន្លែងទទួល ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ទុទ្ធកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ទុទ្ធកាល័យសម្តេច ឯកឧត្តម លោកជំទាវបនាយករដ្ឋមន្ត្រី
- ជុំវិញមាត្រា១៩
- រាជកិច្ច
- ឯកសារ ការិយាល័យ

ប្រកាស

ស្តីពី

ការធ្វើប្រតិភូកម្មអំណាចដល់អភិបាលខេត្ត

ក្នុង

ក្នុងការជួយគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ : ១៨៨៤ប្រ.ក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ប្រកាស

ស្តីពី

ការធ្វើប្រតិភូកម្មអំណាចដល់អភិបាលខេត្ត ក្នុង ក្នុងការជួយគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់

សហរដ្ឋមន្ត្រី

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មិនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៥០១/១៧៥ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់

-បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ

-បានឃើញអនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ មិនា ឆ្នាំ ២០០២ ស្តីពីការធ្វើវិមជ្ឈការអំណាចតួនាទី និងភារកិច្ច ទៅអោយក្រុមប្រឹក្សាឃុំ សង្កាត់

-យោងតាមសេចក្តីសំរេចនៃអង្គប្រជុំរបស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ កាលពីថ្ងៃទី ១៤ ខែ មិនា ឆ្នាំ ២០០២

សំរេច

ឧបសម្ព័ន្ធ ១
អំពីបទប្បញ្ញត្តិទូទៅ

ប្រការ ១.-

ត្រូវបានធ្វើប្រតិភូកម្មអំណាចដល់អភិបាលខេត្ត ក្រុង ក្នុងនាមរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីសម្របសម្រួលការអនុវត្តន៍ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងការអនុវត្តន៍គោលនយោបាយវិមជ្ឈការ នៅតាមខេត្ត ក្រុងនីមួយៗ ផ្អែកតាមការសម្រេចរបស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ (គ.ឃ.ស) ។

បទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះចែងអំពីតួនាទី និងការទទួលខុសត្រូវចំបងៗរបស់អភិបាលខេត្ត ក្រុង ក្រោមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងគោលនយោបាយវិមជ្ឈការ ។

ប្រការ ២.-

អភិបាលខេត្ត ក្រុងត្រូវជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យមានសមត្ថភាពដើម្បីអនុវត្តអំណាច និងមុខងារស្របទៅតាម :

-ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

-ព្រះរាជក្រឹត្យ និង

-អនុក្រឹត្យ ប្រកាស ឬលិខិតបទដ្ឋាននានាដែលមានជាធរមាន ។

ប្រការ ៣.-

អភិបាលខេត្ត ក្រុងត្រូវជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការបន្តអនុវត្តកិច្ចព្រមព្រៀង ឬការចាត់ចែងបន្តនូវការងារដែលបានធ្វើឡើងក្នុងនាមឃុំ សង្កាត់មុនពេលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងករណីដែលកិច្ចព្រមព្រៀង ឬការងារទាំងនោះមានលក្ខណៈសមស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋាននានាដែលមានជាធរមាន ។

ចំពោះកិច្ចព្រមព្រៀង ឬការងារនានាដែលបានធ្វើឡើងក្នុងនាមឃុំ សង្កាត់ មុនពេលបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ក៏អាចបន្តអនុវត្តបាន ប្រសិនបើក្រុមប្រឹក្សាឃុំ សង្កាត់យល់ឃើញថា កិច្ចព្រមព្រៀង ឬការងារទាំងនោះមិនផ្ទុយនឹងគោលការណ៍ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងគោលនយោបាយវិមជ្ឈការ ប៉ុន្តែត្រូវជូនពត៌មានដល់អភិបាលខេត្ត ក្រុង ។

ចំពោះកិច្ចព្រមព្រៀង ឬការងារណាមួយដែលនៅស្រពិចស្រពិល ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវពិគ្រោះយោបល់ជាមួយអភិបាលខេត្ត ក្រុង តាមរយៈអភិបាលស្រុក ខ័ណ្ឌមុននឹងបន្តអនុវត្ត ។

ជំពូកទី ២

អំពីអង្គភាពរដ្ឋបាលមូលដ្ឋាន

ប្រការ ៤.~

ត្រូវបង្កើតអោយមានអង្គភាពរដ្ឋបាលមូលដ្ឋានចំណុះសាលាខេត្ត ក្រុង និងសាលាស្រុក ខ័ណ្ឌ ដើម្បីធ្វើជាសេនាធិការជូនអភិបាលខេត្ត ក្រុង ស្រុក ខ័ណ្ឌ ក្នុងការអនុវត្តគោលនយោបាយវិមជ្ឈការ ។

ការរៀបចំ និង ការប្រព្រឹត្តទៅនៃអង្គភាពរដ្ឋបាលមូលដ្ឋានត្រូវកំណត់ដោយប្រកាសដោយឡែករបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមការសម្រេចរបស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

ប្រការ ៥.~

អភិបាលខេត្ត ក្រុង គឺជាច្រកផ្លូវការនៃទំនាក់ទំនងរវាងក្រុមប្រឹក្សាឃុំ សង្កាត់ នៅក្នុងខេត្ត ក្រុងរបស់ខ្លួន ជាមួយរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន ឬភ្នាក់ងាររបស់រាជរដ្ឋាភិបាល ព្រមទាំងអង្គការជាតិ និងអន្តរជាតិនានា ។

ជំពូកទី ២

អំពីការកសាងសមត្ថភាព

ប្រការ ៦.~

អភិបាលខេត្ត ក្រុងត្រូវវាយតំលៃហើយធានាថា :

-អង្គភាពរដ្ឋបាលមូលដ្ឋានក្នុងខេត្ត ក្រុងរបស់ខ្លួនមានធនធានមនុស្ស និងធនធានសំភារៈ សមស្របក្នុងការអនុវត្តគោលនយោបាយវិមជ្ឈការ ។

-មន្ត្រីដែលបំរើការងារក្នុងអង្គភាពនេះ មានសមត្ថភាពគ្រប់គ្រាន់ និងអនុវត្តបានត្រឹមត្រូវតាមតួនាទី និងការទទួលខុសត្រូវក្នុងការអនុវត្តន៍ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងលិខិតបទដ្ឋាននានាសំរាប់អនុវត្តច្បាប់នេះ ។

ក្នុងករណីដែលមិនអាចធានាបាននូវបញ្ហាខាងលើនេះ អភិបាលខេត្ត ក្រុងត្រូវអន្តរាគមន៍មកក្រសួងមហាផ្ទៃក្នុងការផ្តល់នូវធនធានមនុស្ស និងធនធានសំភារៈ អោយបានសមស្រប និងទាន់ពេលវេលា ព្រមទាំងការបណ្តុះបណ្តាលសមត្ថភាព ដើម្បីបង្កលក្ខណៈអោយមន្ត្រីទាំងនោះទទួលបាននូវការយល់ដឹងសមស្របពីមុខជំនាញដែលពាក់ព័ន្ធ និងមានឥរិយាបថការងារឱ្យបានត្រឹមត្រូវ ។

ប្រការ ៧.~

អភិបាលខេត្ត ក្រុងត្រូវត្រួតពិនិត្យ និងវាយតំលៃ :

-អំពីការអនុវត្តន៍នូវតួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ និងមន្ត្រីដែលបានតែងតាំងដោយក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីរៀបចំការកសាងសមត្ថភាពឱ្យបានសមស្រប

-អំពីតំរូវការខាងធនធានមនុស្ស និងធនធានសំភារៈសមស្រប សម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់

-អំពីការយល់ដឹងជំនាញ និងតរិយាបថការងាររបស់មន្ត្រីដែលបានតែងតាំង និងដែលបានបោះឆ្នោតជ្រើសរើសឡើងដោយប្រជាពលរដ្ឋ ក្នុងការអនុវត្តតួនាទី និងការទទួលខុសត្រូវក្រោមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងលិខិតបទដ្ឋាននានាសំរាប់អនុវត្តច្បាប់នេះ ។

ប្រការ ៨.-

អភិបាលខេត្ត ក្រុងត្រូវពិនិត្យ និងវាយតំលៃ អំពីការកំណត់តួនាទី និងការទទួលខុសត្រូវរបស់មន្ត្រីនៃក្រសួងពាក់ព័ន្ធ ឬភ្នាក់ងាររបស់រាជរដ្ឋាភិបាលក្នុងរដ្ឋបាលខេត្ត ក្រុងរបស់ខ្លួន និងអំពីកិរិតយល់ដឹង និងតរិយាបថរបស់មន្ត្រីទាំងនោះដើម្បីអនុវត្តន៍តួនាទី និងការទទួលខុសត្រូវរបស់ខ្លួន ក្រោមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងលិខិតបទដ្ឋាននានាសំរាប់អនុវត្តច្បាប់នេះ ។

ប្រការ ៩.-

អភិបាលខេត្ត ក្រុងត្រូវពិនិត្យ និងវាយតំលៃអំពីសមត្ថភាព និងលទ្ធភាពរបស់ប្រជារាស្ត្រទូទៅ នៅក្នុងខេត្ត ក្រុងរបស់ខ្លួនដើម្បីធ្វើអន្តរាគមន៍លើការបង្កើនសមត្ថភាពអោយបានសមស្របតាមរយៈការអប់រំ ការបណ្តុះបណ្តាលដោយស្មៀវភៅ ឯកសារ ផ្ទាំងរូបភាព ការផ្សព្វផ្សាយ ពត៌មានផ្សេងៗ ព្រមទាំងការអប់រំ តាមរយៈវិទ្យុ ទូរទស្សន៍ កាសែត និងប្រព័ន្ធផ្សព្វផ្សាយដទៃទៀត ដើម្បីចូលរួមចំណែកក្នុងការគ្រប់គ្រងកិច្ចការឃុំ សង្កាត់របស់ខ្លួន ក្រោមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

ប្រការ ១០.-

អភិបាលខេត្ត ក្រុងត្រូវសហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីធានាឱ្យមានការបង្កើនសមត្ថភាព ការផ្តល់ធនធានឱ្យបានសមស្របដល់រដ្ឋបាលខេត្ត ក្រុងរបស់ខ្លួន ក្រុមប្រឹក្សាឃុំ សង្កាត់ មន្ត្រីរបស់រាជរដ្ឋាភិបាល និងភ្នាក់ងាររបស់ខ្លួន ព្រមទាំងប្រជារាស្ត្រទូទៅសំរាប់ ដំណើរការ និងចូលរួមក្នុងដំណើរការអភិបាលកិច្ចឃុំ សង្កាត់តាមបែបវិមជ្ឈការ ។

ជំពូកទី ៤
អំពីការត្រួតពិនិត្យ និងការធ្វើអន្តរាគមន៍

ប្រការ ១១.-

បន្ទាប់ពីកិច្ចប្រជុំដំបូងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ អភិបាលខេត្ត ក្រុងត្រូវពិនិត្យ និងតាមដានអំពីដំណើរការរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីធានាថា :

-ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់បានធ្វើជាអធិបតីក្នុងរាល់កិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់

-ក្រុមប្រឹក្សាឃុំ សង្កាត់បានប្រជុំយ៉ាងហោចណាស់មួយដងក្នុងមួយខែ

-បទបញ្ជាផ្ទៃក្នុងដែលក្រុមប្រឹក្សាឃុំ សង្កាត់ បានរៀបចំ និងអនុម័ត ត្រឹមត្រូវតាមគោលការណ៍ណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

-រាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានកោះប្រជុំ បានប្រព្រឹត្តទៅ និងបានកត់ត្រាត្រឹមត្រូវតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

-រាល់កិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានប្រព្រឹត្តឡើងជាសាធារណៈ និងក្នុងលក្ខណៈប្រជាធិបតេយ្យ

-រាល់កិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់មានរបៀបរៀបរយល្អ ។

ប្រការ ១២.-

អភិបាលខេត្ត ក្រុងត្រូវពិនិត្យ និងវាយតំលៃអំពីការបំពេញការងាររបស់មេឃុំ ចៅសង្កាត់អោយបានត្រឹមត្រូវតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងលិខិតបទដ្ឋានពាក់ព័ន្ធនានាក្នុងការ :

-អនុវត្តន៍សេចក្តីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

-អនុវត្តន៍តាមគោលនយោបាយរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

-ធ្វើសេចក្តីរាយការណ៍ប្រចាំខែជូនក្រុមប្រឹក្សាឃុំ សង្កាត់អំពីការអនុវត្តន៍ការងារ

-ជួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការធ្វើផែនការហិរញ្ញវត្ថុ និងការងារផ្សេងៗទៀតដែលក្រុមប្រឹក្សាឃុំ សង្កាត់ប្រគល់ឱ្យ ។

ប្រការ ១៣.-

អភិបាលខេត្ត ក្រុងត្រូវពិនិត្យ និងវាយតំលៃអំពីការបង្កើត និងកិច្ចដំណើរការនៃគណៈកម្មាធិការនានារបស់មេឃុំ ចៅសង្កាត់ ។

ទន្ទឹមនឹងនេះអភិបាលខេត្ត ក្រុងត្រូវពិនិត្យ វាយតំលៃ និងធានាឱ្យការប្រជុំ គណៈកម្មាធិការនីមួយៗបានដំណើរការសមស្របតាមបទបញ្ជាផ្ទៃក្នុងសំរាប់ក្រុមប្រឹក្សាឃុំ សង្កាត់ និងគណៈកម្មាធិការជំនួយការ ។

ប្រការ ១៤.-

អភិបាលខេត្ត ក្រុងត្រូវពិនិត្យ វាយតំលៃ និងធានាឱ្យការជ្រើសរើសមេភូមិ និងជំនួយការមេភូមិ ការផ្លាស់ប្តូរមេភូមិ និងជំនួយការមេភូមិ ព្រមទាំងការអនុវត្តន៍ភារកិច្ចរបស់មេភូមិ និងជំនួយការមេភូមិបានសមស្របទៅតាមសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ក្នុងករណីដែលការជ្រើសរើសមេភូមិ និងជំនួយការមេភូមិមិនបានដំណើរការសមស្របទៅតាមបែបបទ និងនីតិវិធីដែលបានចែងក្នុងសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្ត ក្រុងត្រូវធ្វើការណែនាំជាលាយលក្ខណ៍អក្សរដើម្បីឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើការកែតំរូវជាបន្ទាន់ ។

ក្នុងករណីដែលមេភូមិ ឬជំនួយការមេភូមិអនុវត្តមិនបានត្រឹមត្រូវទៅតាមតួនាទី ភារកិច្ច របស់ខ្លួន អភិបាលខេត្ត ក្រុងត្រូវស្នើសុំទៅក្រុមប្រឹក្សាឃុំ សង្កាត់ :

-ឱ្យធ្វើការស៊ើបអង្កេត និងវាយតម្លៃអំពីការខ្វះខាតទាំងនោះ និងវិធានការនានារបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីកែលំអរការខ្វះខាតទាំងនោះ

-ឱ្យធ្វើសេចក្តីរាយការណ៍ជាលាយលក្ខណ៍អក្សរអំពីលទ្ធផលនៃការដោះស្រាយ និងការកែលំអរចំណុចខ្វះខាតរបស់មេភូមិ ឬជំនួយការមេភូមិជូនអភិបាលខេត្ត ក្រុងវិញ ។

ប្រការ ១៥.-

អភិបាលខេត្ត-ក្រុង ត្រូវធ្វើអន្តរាគមន៍ក្នុងសមត្ថកិច្ចនៃសិទ្ធិអំណាចជាផ្លូវការរបស់ខ្លួន ហើយត្រូវរាយការណ៍ជាបន្ទាន់ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ពេលដែលសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាមួយទទួលការចោទប្រកាន់ ការចាប់ខ្លួន ឬការឃុំខ្លួនដោយសារការបញ្ឆោញមតិ ឬការនិយាយស្តីនៅក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប្រការ ១៦.-

អភិបាលខេត្ត ក្រុងត្រូវត្រួតពិនិត្យ និងធ្វើអន្តរាគមន៍ ចំពោះក្រុមប្រឹក្សាឃុំ សង្កាត់ណាមួយដែលធ្វើសកម្មភាពហួសពីសមត្ថកិច្ចនៃមុខងារ និងអំណាចរបស់ខ្លួន ឬក៏មិនអនុវត្តតាមនីតិវិធី និងភារកិច្ចដែលច្បាប់បានតំរូវ ។

អភិបាលខេត្ត ក្រុងត្រូវធានាកែតំរូវកំហុសឆ្គងទាំងនេះជាបន្ទាន់ ដោយអនុលោមទៅតាមគោលការណ៍ទូទៅដែលចែងក្នុងប្រកាសនេះ ។

ប្រការ ១៧.-

អភិបាលខេត្ត ក្រុងត្រូវផ្តួចផ្តើមគំនិត និងអនុវត្តការត្រួតពិនិត្យលើសេចក្តីសំរេច ឬសកម្មភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ឬធ្វើអន្តរាគមន៍លើសេចក្តីសំរេច ឬសកម្មភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងករណី :

-ការត្រួតពិនិត្យ និងការធ្វើអន្តរាគមន៍ ត្រូវបានតំរូវយ៉ាងជាក់លាក់ក្នុងក្របខ័ណ្ឌច្បាប់ ឬលិខិតបទដ្ឋានពាក់ព័ន្ធ

-មានការឆ្លើយតបទៅនឹងសេចក្តីរាយការណ៍ ឬការប្តឹងតវ៉ាដល់អភិបាលខេត្ត ក្រុង ។

ប្រការ ១៨.-

ក្នុងករណីដែលច្បាប់ ឬលិខិតបទដ្ឋានតំរូវអោយអភិបាលខេត្ត ក្រុងធ្វើអន្តរាគមន៍ទៅលើសេចក្តីសំរេច ឬសកម្មភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ឬធ្វើអន្តរាគមន៍លើឃុំ សង្កាត់ណាមួយ អភិបាល ខេត្ត ក្រុងត្រូវធានាថា ក្រុមប្រឹក្សាឃុំ សង្កាត់ បាន ឬ នឹងអនុវត្តតាមនីតិវិធីដែលបានតំរូវដោយ :

-ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់

-ព្រះរាជក្រឹត្យ

-អនុក្រឹត្យ ប្រកាស ឬលិខិតបទដ្ឋាននានាដែលបានអនុម័តយល់ព្រម ដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់

-បទបញ្ជាផ្ទៃក្នុង ដីកា ឬ សេចក្តីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប្រការ ១៩.-

ក្នុងករណីដែលអភិបាលខេត្ត ក្រុងទទួលបានពត៌មានថា ក្រុមប្រឹក្សាឃុំ សង្កាត់មិនអនុវត្តតាមនីតិវិធី និងភារកិច្ចដែលច្បាប់បានតំរូវ អភិបាលខេត្ត ក្រុងត្រូវស្វែងរកហេតុផលឱ្យបានគ្រប់គ្រាន់ ដើម្បីបញ្ជាក់ថា ពត៌មាននោះត្រឹមត្រូវ ឬមិនត្រឹមត្រូវ ។

អភិបាលខេត្ត ក្រុងអាចតែងតាំងបុគ្គលដែលមានសមត្ថភាពសមស្រប ឬគណៈកម្មការ ឱ្យស៊ើបអង្កេតបញ្ហានេះដើម្បីរាយការណ៍អោយខ្លួនវិញ ។

ប្រការ ២០.-

បុគ្គល ឬគណៈកម្មការដែលតែងតាំងដោយអភិបាលខេត្ត ក្រុងមានតួនាទីត្រឹមតែស៊ើបអង្កេត ដើម្បីធ្វើសេចក្តីរាយការណ៍ជូនអភិបាលខេត្ត ក្រុងរួចហើយអភិបាលខេត្ត ក្រុងត្រូវកំណត់ ថាតើក្រុមប្រឹក្សាឃុំ សង្កាត់នោះធ្វើសកម្មភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវតាមសមត្ថកិច្ចនៃមុខងារ និងអំណាចរបស់ខ្លួន និងនីតិវិធីដែលបានតំរូវដោយ :

-ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

-ព្រះរាជក្រឹត្យ

-អនុក្រឹត្យ ប្រកាស ឬលិខិតបទដ្ឋាននានាដែលបានអនុម័តយល់ព្រមដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់

-បទបញ្ជាផ្ទៃក្នុង ដីកា ឬសេចក្តីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប្រការ ២១.~

បុគ្គល ឬគណៈកម្មការដែលបានតែងតាំងដោយអភិបាលខេត្ត ក្រុងអាចត្រួតពិនិត្យឯកសារពាក់ព័ន្ធនីតិវិធី ឬសកម្មភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ និងអាចធ្វើការសាកសួរពត៌មានដែលពាក់ព័ន្ធសមស្រប ព្រមទាំងអាចតំរូវអោយស្មៀនឃុំ សង្កាត់ផ្តល់ពត៌មានដែលចាំបាច់ ។

ប្រការ ២២.~

ប្រសិនបើបុគ្គល ឬគណៈកម្មការនោះរកឃើញថា ក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើសកម្មភាព មិនស្របទៅតាមសមត្ថកិច្ចនៃមុខងារ ឬអំណាចរបស់ខ្លួន ឬមិនបានអនុវត្តតាមនីតិវិធី និងភារកិច្ចដែលច្បាប់បានតំរូវ បុគ្គល ឬគណៈកម្មការនោះត្រូវធ្វើរបាយការណ៍ជូនអភិបាលខេត្ត ក្រុង ។

របាយការណ៍នោះត្រូវដាក់បញ្ចូលនូវ :

-ហេតុផលនៃកំហុសឆ្គង

-វិធីសាស្ត្រកែតំរូវកំហុសឆ្គង

-ប្រភេទនៃសកម្មភាព ឬការធ្វើអន្តរាគមន៍ដទៃទៀតដែលត្រូវការ

-ការគាំទ្រ និងការកសាងសមត្ថភាពណាមួយដែលគួរតែផ្តល់អោយក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ប្រតិបត្តិអំណាច និងមុខងាររបស់ខ្លួនអោយបានត្រឹមត្រូវ និងដើម្បីជំរុញការអនុវត្តមុខងារ ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អោយកាន់តែប្រសើរឡើង ។

ប្រការ ២៣.~

ផ្អែកតាមសេចក្តីរាយការណ៍របស់បុគ្គល ឬគណៈកម្មការដូចមានចែងក្នុងប្រការ២២ នៃប្រកាសនេះអភិបាលខេត្ត ក្រុងត្រូវ :

-ផ្តល់យោបល់ជាលាយលក្ខណ៍អក្សរដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីបញ្ជាក់អំពីនីតិវិធី និងតំរូវការផ្អែកច្បាប់អ្វីខ្លះដែលក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុវត្ត

-ណែនាំជាលាយលក្ខណ៍អក្សរដល់ក្រុមប្រឹក្សាឃុំ សង្កាត់ អោយកែតំរូវកំហុសឆ្គងក្នុងកំឡុងពេលសមស្រប និងរាយការណ៍ជូនខ្លួនវិញពេលដែលការកែតំរូវនោះត្រូវបានបញ្ចប់រួចរាល់ ។

ប្រការ ២៤.~

នៅពេលដែលក្រុមប្រឹក្សាឃុំ សង្កាត់មិនមានសមត្ថភាពកែតំរូវកំហុសឆ្គងនោះ អភិបាលខេត្ត ក្រុងត្រូវធ្វើកិច្ចការនោះជំនួស ហើយត្រូវចាត់វិធានការចាំបាច់ដើម្បីអភិវឌ្ឍន៍សមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

អភិបាលខេត្ត ក្រុងត្រូវធ្វើសេចក្តីរាយការណ៍ និងផ្តល់អនុសាសន៍ដល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអំពីក្រុមប្រឹក្សាឃុំ សង្កាត់ណាមួយ :

-ដែលមិនបានកែតំរូវកំហុសឆ្គងក្នុងរយៈពេល៦ខែបន្ទាប់ពីការធ្វើអន្តរាគមន៍

-ដែលជាទូទៅមិនអនុវត្តតាមនីតិវិធី និងភារកិច្ចដែលច្បាប់បានតំរូវ

-ដែលប្រព្រឹត្តផ្ទុយនឹងរដ្ឋធម្មនុញ្ញ ឬផ្ទុយនឹងគោលនយោបាយរាជរដ្ឋាភិបាលដូចមានចែងក្នុងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋាននានាដែលបានអនុម័តយល់ព្រមដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ បទ-បញ្ជាផ្ទៃ ក្នុង ដីកា និងសេចក្តីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប្រការ ២៥.~

អភិបាលខេត្ត ក្រុងមិនអាចធ្វើសេចក្តីសំរេចណាមួយក្នុងនាមក្រុមប្រឹក្សាឃុំ សង្កាត់បានទេ លើកលែងតែក្នុងករណីដែលប្រកាសនេះបានអនុញ្ញាតិអោយ ។

ក្នុងករណីនេះអភិបាលខេត្ត ក្រុងត្រូវធានាថា ក្រុមប្រឹក្សាឃុំ សង្កាត់អនុវត្តតាមនីតិវិធី និងភារកិច្ចដែលច្បាប់បានតំរូវយ៉ាងជាក់លាក់ ។

ប្រការ ២៦.~

អភិបាលខេត្ត ក្រុងត្រូវធ្វើការកត់ត្រា ត្រួតពិនិត្យ និងវាយតំលៃចំពោះបញ្ហាទាំងឡាយដូចខាងក្រោម :

-ពេលដែលសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានគំរាមកំហែង ឃាត់ខ្លួន ឬឃុំខ្លួនដោយសារការបញ្ចេញមតិ ឬការនិយាយនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

-ការធ្វើសមាហរណកម្មរបស់កម្មវិធីអភិវឌ្ឍន៍នានាទៅក្នុងប្រព័ន្ធគ្រប់គ្រងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

-ពេលដែល :

-ការបោះឆ្នោត ឃុំ សង្កាត់មិនអាចប្រព្រឹត្តទៅបាន

-វិធានការដាក់វិន័យទៅលើសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

-សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបាត់បង់សមាជិកភាពពីក្រុមប្រឹក្សាឃុំ សង្កាត់

-ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានរំសាយ ហើយការបោះឆ្នោតឡើងវិញអាចប្រព្រឹត្តទៅបាន

-ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានរំសាយហើយការបោះឆ្នោតឡើងវិញមិនអាចប្រព្រឹត្តទៅបាន

-មានបទល្មើសឧក្រិដ្ឋ ឬបទល្មើសមជ្ឈឹមកើតមាននៅក្នុងក្រុមប្រឹក្សាឃុំ សង្កាត់

-ការសម្របសម្រួល និងការដោះស្រាយជម្លោះរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងការខ្វែងមតិគ្នារវាងក្រុមប្រឹក្សាឃុំ សង្កាត់ និងអភិបាលខេត្ត ក្រុង

-ការធ្វើប្រតិភូកម្មអំណាចរបស់រដ្ឋទៅអោយឃុំ សង្កាត់

-ទំនាក់ទំនង រវាងក្រុមប្រឹក្សាឃុំ សង្កាត់ និងអង្គការមិនមែនរដ្ឋាភិបាល ជាតិ និងអន្តរជាតិ

-ការចាត់ចែងរួម ឬកិច្ចសហការរវាងក្រុមប្រឹក្សាឃុំ សង្កាត់ និងក្រុមប្រឹក្សាឃុំ សង្កាត់

-សំណើបង្កើត លុបចោល កែប្រែព្រំប្រទល់ និងប្តូរឈ្មោះរបស់ឃុំ សង្កាត់

-បញ្ហាទាំងឡាយដែលតំរូវអោយអភិបាលខេត្ត ក្រុងអនុវត្តក្នុងការអនុម័ត ការត្រួតពិនិត្យ ការកសាងសមត្ថភាព ឬការធ្វើអន្តរាគមន៍ ។

ប្រការ ២៧.-

អភិបាលខេត្ត ក្រុងត្រូវត្រួតពិនិត្យ និងវាយតំលៃជាប្រចាំអំពីការវិវត្តន៍ប្រែប្រួល និងសមត្ថភាពរបស់ឃុំ សង្កាត់ ។

អភិបាលខេត្ត ក្រុងត្រូវធ្វើសេចក្តីរាយការណ៍ និងផ្តល់អនុសាសន៍រៀងរាល់ ៣ខែម្តង អំពីការវិវត្តន៍ប្រែប្រួល និងសមត្ថភាពរបស់ឃុំ សង្កាត់ ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

ប្រការ ២៨.-

គោលការណ៍ជាទូទៅដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យ និងការធ្វើអន្តរាគមន៍ ត្រូវដាក់អោយអនុវត្តផងដែរចំពោះបញ្ហាមួយចំនួនដែលទាក់ទងនឹងសេចក្តីសំរេច ឬសកម្មភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

បញ្ហាទាំងនោះរួមមាន :

-កិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់

-កិច្ចប្រជុំគណៈកម្មាធិការ

-ភារកិច្ចរបស់មេឃុំ ចៅសង្កាត់

-ការជ្រើសរើស និងរបៀបរបបធ្វើការងាររបស់មេភូមិ

-ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

-ហិរញ្ញវត្ថុ និងថវិកាឃុំ សង្កាត់

-ការអនុវត្តន៍ការងាររបស់ឃុំ សង្កាត់

-មោឃភាពសេចក្តីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងដីកាឃុំ សង្កាត់ ។

ប្រការ ២៩.-

អភិបាលខេត្ត ក្រុងត្រូវសម្រេចយល់ព្រម ឬមិនយល់ព្រមលើពាក្យស្នើរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីសុំកាត់មួយផ្នែក ឬទាំងអស់នៃប្រាក់ឧបត្ថម្ភរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាម្នាក់ ដែលទទួលវិន័យស្តីបន្ទោសក្នុងអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់នោះរួចហើយ ប៉ុន្តែសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រូបនោះ នៅតែបន្តប្រព្រឹត្តកំហុសតទៅទៀត ។

ក្នុងករណីដែលសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាម្នាក់មិនអនុវត្តតាមបទប្បញ្ញត្តិណាមួយ ឬច្រើននៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឬប្រព្រឹត្តផ្ទុយពីបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រូបនោះនឹងទទួលវិន័យជាបឋម ដោយការស្តីបន្ទោសក្នុងអង្គប្រជុំក្រុមប្រឹក្សា ឃុំ សង្កាត់របស់ខ្លួន ដោយមានកំណត់

ហេតុច្បាស់លាស់ ។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបញ្ជូនកំណត់ហេតុនេះជាបន្ទាន់ ទៅអភិបាលខេត្ត ក្រុងដើម្បីធ្វើការស៊ើបអង្កេត និងវាយតម្លៃ ។

បន្ទាប់ពីបានទទួលវិន័យខាងលើនេះហើយ ប៉ុន្តែសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រូបនោះនៅតែ បន្តប្រព្រឹត្តកំហុស ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវស្នើទៅអភិបាលខេត្ត ក្រុងដើម្បីស្នើសុំកាត់មួយផ្នែក ឬទាំងអស់នូវប្រាក់ឧបត្ថម្ភរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រូបនោះ ។

ក្នុងករណីអនុវត្តរូបភាពវិន័យទាំងពីរខាងលើរួចហើយ ប៉ុន្តែសមាជិកក្រុមប្រឹក្សារូបនោះនៅតែមិនរាងចាល ក្រុមប្រឹក្សាឃុំ សង្កាត់អាចបញ្ឈប់ជននោះពីមុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដោយការបោះឆ្នោតតាមសម្លេងភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល ។

អភិបាលខេត្ត ក្រុង ត្រូវធ្វើការស៊ើបអង្កេតដើម្បីវាយតម្លៃថា ក្រុមប្រឹក្សាឃុំ សង្កាត់បានអនុវត្តត្រឹមត្រូវតាមនីតិវិធីនេះ ។

ប្រការ ៣០.-

អភិបាលខេត្ត ក្រុងត្រូវសំរេចអំពីការបាត់បង់សមាជិកភាពរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដោយមូលហេតុណាមួយដូចខាងក្រោម :

-សាមីខ្លួនទទួលមរណភាព

-សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈខាងផ្លូវចិត្ត ឬផ្លូវកាយដោយមានការបញ្ជាក់ពីក្រសួង ឬស្ថាប័នមានសមត្ថកិច្ច

-សាមីខ្លួនសុំលាលែងជាលាយលក្ខណ៍អក្សរពីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

-សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈឹមណាមួយ

-សាមីខ្លួនត្រូវបានបណ្តេញចេញដោយប្រព្រឹត្តផ្ទុយនឹងបទបញ្ជាផ្ទៃក្នុង តាមលក្ខខណ្ឌដែលបានកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានពាក់ព័ន្ធ

-សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន ។

ប្រការ ៣១.-

ក្នុងករណីដែលមានភស្តុតាងជាក់លាក់ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាម្នាក់បាត់បង់សមាជិកភាពរបស់ខ្លួនដោយហេតុផលណាមួយក្នុងចំណោមហេតុផលដូចមានចែងក្នុងប្រការ ៣០ នៃប្រកាសនេះ អភិបាលខេត្ត ក្រុងត្រូវធ្វើសេចក្តីរាយការណ៍ជាបន្ទាន់ជូនដល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីស្នើដាក់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ថ្មីជំនួសស្របតាមច្បាប់ និងនីតិវិធីដែលបានកំណត់ ។

ប្រការ ៣២.-

អភិបាលខេត្ត ក្រុងត្រូវបញ្ជូនទៅអាជ្ញាធរតុលាការ ឬនគរបាលជាតិ និងក្រសួងមហាផ្ទៃនូវសេចក្តីរាយការណ៍ ឬការប្តឹងតវ៉ាណាមួយដែលបញ្ជាក់ថា សេចក្តីសំរេច ឬសកម្មភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ បុគ្គលិកនៃក្រុមប្រឹក្សាឃុំ សង្កាត់ បានប្រព្រឹត្តនូវបទឧក្រិដ្ឋ ឬបទមជ្ឈឹម ។

អភិបាលខេត្ត ក្រុងត្រូវតាមដានអោយបានជិតដល់នូវបញ្ហាខាងលើនេះ និងរាយការណ៍អំពីលទ្ធផលនៃដំណោះស្រាយជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ជំពូកទី ៥
អំពីការគ្រប់គ្រងឃុំ សង្កាត់ដែលទើបបង្កើតថ្មី និងឃុំ សង្កាត់ដែលក្រុមប្រឹក្សាត្រូវរំសាយ

ប្រការ ៣៣.-

អភិបាលខេត្ត ក្រុងត្រូវធានាចាត់ចែងកិច្ចការជាបណ្តោះអាសន្ន ចំពោះឃុំ សង្កាត់ដែលទើបបង្កើតថ្មី និងឃុំ សង្កាត់ដែលក្រុមប្រឹក្សាត្រូវរំសាយ ។

ប្រការ ៣៤.-

អភិបាលខេត្ត ក្រុងត្រូវតែងតាំងបុគ្គល ឬគណៈកម្មការជាបន្ទាន់ ដើម្បីចាត់ចែងកិច្ចការឃុំ សង្កាត់ដូចមានចែងក្នុងប្រការ ៣៣ នៃប្រកាសនេះ ។

អភិបាលខេត្ត ក្រុងត្រូវធ្វើការពិគ្រោះយោបល់ជាមួយនាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ ដើម្បីលើកយោបល់ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃពិនិត្យ និងសំរេចអំពីការងាររបស់បុគ្គល ឬគណៈកម្មការនោះ ។

ការកំណត់ការងារនេះ :

-ត្រូវផ្អែកលើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងលិខិតបទដ្ឋានពាក់ព័ន្ធនានា

-ត្រូវគ្រប់គ្រងកិច្ចការប្រចាំថ្ងៃ របស់ឃុំ សង្កាត់តែប៉ុណ្ណោះ

-មិនអាចអនុម័តលើផែនការអភិវឌ្ឍន៍ និងថវិកាឃុំ សង្កាត់ ឬចុះកិច្ចសន្យា ឬសកម្មភាពណាមួយដែលរំលោភលើសិទ្ធិអំណាចរបស់ឃុំ សង្កាត់ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីអភិបាលខេត្ត ក្រុងបានឡើយ ។

ជំពូកទី៦
អំពីការរំសាយក្រុមប្រឹក្សាឃុំ សង្កាត់ និងការគ្រប់គ្រងឃុំ សង្កាត់ជាបណ្តោះអាសន្ន

ប្រការ ៣៥.-

អភិបាលខេត្ត ក្រុងត្រូវរាយការណ៍ និងផ្តល់អនុសាសន៍ដល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មុនពេលដែលរដ្ឋមន្ត្រីក្រសួងមហាផ្ទៃធ្វើការរំសាយក្រុមប្រឹក្សាឃុំ សង្កាត់ដោយយោងតាមមាត្រា ៥៧ ឬមាត្រា៥៨ នៃច្បាប់ស្តីពីការគ្រប់គ្រង រដ្ឋបាលឃុំ សង្កាត់ ។

ករណីដែលរដ្ឋមន្ត្រីក្រសួងមហាផ្ទៃរំសាយក្រុមប្រឹក្សាឃុំ សង្កាត់យោងតាមមាត្រា ៥៧ ឬ៥៨នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ហើយអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ មានរយៈពេល មិនលើសពី ១៨០ថ្ងៃ គិត

ចាប់ពីថ្ងៃរំសាយក្រុមប្រឹក្សាឃុំ សង្កាត់ អភិបាលខេត្ត ក្រុង ត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ហើយការបោះឆ្នោតឡើងវិញនៅឃុំ សង្កាត់នោះមិនត្រូវរៀបចំឡើយ ។

ករណីដែលរដ្ឋមន្ត្រីក្រសួងមហាផ្ទៃរំសាយក្រុមប្រឹក្សាឃុំ សង្កាត់ដោយយោងតាមមាត្រា ៥៧ ឬមាត្រា ៥៨នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ហើយអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ លើសពី ១៨0ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការរំសាយក្រុមប្រឹក្សាឃុំ សង្កាត់ អភិបាលខេត្ត ក្រុងត្រូវស្នើសុំទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អោយកំណត់កាលបរិច្ឆេទ នៃការបោះឆ្នោតឡើងវិញ ។

ប្រការ ៣៦.~

ក្នុងករណីដែលអាណត្តិនៅសល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់មានរយៈពេលលើសពី ១៨0ថ្ងៃ អភិបាលខេត្ត ក្រុងត្រូវតែងតាំងបុគ្គល ឬគណៈកម្មការជាបន្ទាន់ដើម្បីចាត់ចែងកិច្ចការជាបណ្តោះអាសន្ននៅឃុំ សង្កាត់ដែលបានរំសាយក្រុមប្រឹក្សារហូតដល់ការបោះឆ្នោតឡើងវិញអាចប្រព្រឹត្តទៅបាន ។

អភិបាលខេត្ត ក្រុងត្រូវកំណត់ការងាររបស់បុគ្គល ឬគណៈកម្មការនោះ តាមលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ ៣៤ នៃប្រកាសនេះ ។

ប្រការ ៣៧.~

ក្នុងករណីដែលអាណត្តិនៅសល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ មានរយៈពេលមិនលើសពី ១៨0ថ្ងៃ អភិបាលខេត្ត ក្រុង ត្រូវតែងតាំងបុគ្គល ឬគណៈកម្មការជាបន្ទាន់ដើម្បីចាត់ចែងកិច្ចការឃុំ សង្កាត់ជាបណ្តោះអាសន្នរហូតដល់ក្រុមប្រឹក្សាឃុំ សង្កាត់ថ្មី ត្រូវបានបោះឆ្នោតជ្រើសរើសឡើងនាអាណត្តិបន្ទាប់ ។

អភិបាលខេត្ត ក្រុងត្រូវកំណត់ការងាររបស់បុគ្គល ឬគណៈកម្មការនោះតាមលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ ៣៤ នៃប្រកាសនេះ ។

ជំពូកទី ៧

អំពីដំណោះស្រាយជំលោះ

ប្រការ ៣៨.~

អភិបាលខេត្ត ក្រុងត្រូវសម្របសម្រួលរវាងឃុំ សង្កាត់ពីរ ឬច្រើន អំពីបញ្ហាណាមួយដែលមានភាពប្រទាញប្រទង់ ឬមានជម្លោះជាមួយគ្នាហើយដែលឃុំ សង្កាត់ទាំងនោះមិនអាចដោះស្រាយបាន ។

ការដោះស្រាយរបស់អភិបាលខេត្ត ក្រុងត្រូវឈរលើមូលដ្ឋាននៃការគោរពនូវផលប្រយោជន៍ទាំងសងខាង ។

អភិបាលខេត្ត ក្រុងត្រូវសហការ និងពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន ឬភ្នាក់ងារពាក់ព័ន្ធដើម្បីដោះស្រាយបញ្ហាដែលមានភាពប្រទាញប្រទង់ ឬមានជម្លោះពាក់ព័ន្ធនឹងការធ្វើប្រតិភូកម្មអំណាចរបស់រដ្ឋចំពោះឃុំ សង្កាត់ ឬសេចក្តីសំរេច ឬសកម្មភាពរបស់ក្រសួង ស្ថាប័ន ឬភ្នាក់ងារទាំងនោះ ។

ប្រការ ៣៩.~

ក្នុងករណីដែលអភិបាលខេត្ត ក្រុងបានដោះស្រាយបញ្ហាណាមួយដែលមានភាពប្រទាញប្រទង់ ឬមានជម្លោះជាមួយគ្នា លើមូលដ្ឋាននៃការធានាបាននូវប្រយោជន៍សំរាប់គ្រប់ភាគី និងអ្នកពាក់ព័ន្ធទាំងអស់ហើយអភិបាលខេត្ត ក្រុងត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ប្រការ ៤០.-

ក្នុងករណីដែលបញ្ហាណាមួយមានភាពប្រទាញប្រទង់ ឬមានជម្លោះជាមួយគ្នា ក្រោយពីបានដោះស្រាយហើយ តែគូភាគី និងអ្នកដែលពាក់ព័ន្ធនៅតែមិនស្រុះស្រួលជាមួយគ្នា អភិបាលខេត្ត ក្រុងត្រូវធ្វើសេចក្តីរាយការណ៍អំពីបញ្ហាទាំងនោះ និងផ្តល់អនុសាសន៍ដល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃដើម្បីបន្តដោះស្រាយ ។

ជំពូកទី ៨
អំពីការធ្វើអន្តរាគមន៍
ចំពោះការធ្វើវិសហមជ្ឈការអំណាចរបស់រដ្ឋ

ប្រការ ៤១.-

អភិបាលខេត្ត ក្រុងត្រូវធ្វើការពិនិត្យបញ្ជាក់គ្រប់កិច្ចព្រមព្រៀង ឬការងារដែលស្នើឡើងដោយក្រសួងស្ថាប័ន ឬភ្នាក់ងាររបស់រាជរដ្ឋាភិបាលក្នុងការធ្វើប្រតិភូកម្មអំណាច ឬការទទួលខុសត្រូវឱ្យដល់ឃុំ សង្កាត់បានអនុវត្តត្រឹមត្រូវតាមលក្ខខណ្ឌដែលកំណត់ដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

អភិបាលខេត្ត ក្រុងត្រូវបដិសេធគ្រប់កិច្ចព្រមព្រៀង ឬការងារដែលបានស្នើឡើងមិនស្របនឹងលក្ខខណ្ឌដែលកំណត់ដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ហើយត្រូវផ្តល់ពត៌មានដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

បន្ទាប់ពីបានពិនិត្យនិងបញ្ជាក់ចំពោះកិច្ចព្រមព្រៀងការងារដែលបានស្នើឡើងមានលក្ខណៈត្រឹមត្រូវរួចហើយអភិបាលខេត្ត ក្រុងត្រូវផ្តល់ពត៌មានដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប្រការ ៤២.-

ក្នុងការធ្វើប្រតិភូកម្មអំណាចរដ្ឋដល់ក្រុមប្រឹក្សាឃុំ សង្កាត់ អភិបាលខេត្ត ក្រុងត្រូវ :

-ត្រួតពិនិត្យការអនុវត្តន៍ កិច្ចព្រមព្រៀងការងារ ដែលក្រសួងស្ថាប័ន ឬភ្នាក់ងាររបស់រាជរដ្ឋាភិបាលបានយល់ព្រមប្រគល់ឱ្យឃុំ សង្កាត់ និងធានាឱ្យមានការប្រគល់នូវធនធាន សមត្ថភាព និងកំរៃបានសមស្រប

-ធ្វើសេចក្តីរាយការណ៍អំពីកង្វះខាតរបស់ក្រសួង ស្ថាប័ន ឬភ្នាក់ងាររបស់រាជរដ្ឋាភិបាលដែលបានធ្វើប្រតិភូកម្មអំណាចឱ្យដល់ឃុំ សង្កាត់ជូនគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ និងក្រសួងមហាផ្ទៃ ព្រមទាំងក្រសួងស្ថាប័ន ឬភ្នាក់ងាររបស់រាជរដ្ឋាភិបាល

-ផ្តល់អនុសាសន៍ដល់ក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័ន ឬភ្នាក់ងាររបស់រាជរដ្ឋាភិបាល អំពីការផ្លាស់ប្តូរ ឬការកែសម្រួលលើកិច្ចព្រមព្រៀងនានា ។

ប្រការ ៤៣.-

ក្នុងករណីដែលមានស្រុក ខណ្ឌ ឃុំ សង្កាត់ ឬភូមិចូលរួមក្នុងកម្មវិធី ឬគំរោងនានារបស់រដ្ឋ ហើយដែលមានការសំរេចពីគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ដើម្បីនឹងធ្វើសមាហរណកម្មកម្មវិធី ឬគំរោងទាំងនោះទៅក្នុងប្រព័ន្ធគ្រប់គ្រងថ្មីនៃឃុំ សង្កាត់ អភិបាលខេត្ត ក្រុង ត្រូវត្រួតពិនិត្យ និងធានាឱ្យមានការផ្ទេរ និងការអនុវត្តន៍អោយបានត្រឹមត្រូវនូវការទទួលខុសត្រូវ មុខងារ និងទ្រព្យសម្បត្តិ ពីកម្មវិធី ឬគំរោងទាំងនោះរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប្រការ ៤៤.-

អភិបាលខេត្ត ក្រុងត្រូវធ្វើការពិនិត្យ និងវាយតម្លៃមុននឹងធ្វើសេចក្តីរាយការណ៍ និងផ្តល់អនុសាសន៍ដល់ គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ និងក្រសួងមហាផ្ទៃ នូវ :

-កិច្ចព្រមព្រៀង ឬកម្មវិធី ឬគំរោងនានា ឬការចាត់ចែងណាមួយដោយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ

-ការចាត់ចែងណាមួយមុនការបោះឆ្នោតលើកទី១ នេះហើយដែលមិនទាន់បានពិភាក្សាគ្នា ក្នុងការធ្វើសមាហរណកម្មទៅក្នុងប្រព័ន្ធគ្រប់គ្រងថ្មី ឬការសម្របសម្រួលជាមួយប្រព័ន្ធគ្រប់គ្រងថ្មីនៃឃុំ សង្កាត់ដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

ជំពូកទី ៩
អំពីការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់
និងការប្តូរឈ្មោះរបស់ឃុំ សង្កាត់

ប្រការ ៤៥.-

អភិបាលខេត្ត ក្រុងត្រូវធ្វើសេចក្តីរាយការណ៍ និងផ្តល់អនុសាសន៍ជូនគណៈកម្មាធិការជាតិ គាំទ្រឃុំ សង្កាត់ និងក្រសួងមហាផ្ទៃនូវសំណើ ឬសំណូមពរនានាអំពីការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់ ឬការប្តូរឈ្មោះរបស់ឃុំ សង្កាត់ ។

ប្រការ ៤៦.-

អភិបាលខេត្ត ក្រុងត្រូវធ្វើសេចក្តីរាយការណ៍ និងផ្តល់អនុសាសន៍ ជូនគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ និងក្រសួងមហាផ្ទៃ អំពីផលលំបាកនានាដែលបណ្តាលមកពីការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់ ឬការប្តូរឈ្មោះរបស់ឃុំ សង្កាត់ ដែលបានស្នើឡើងដោយក្រុមប្រឹក្សាឃុំ សង្កាត់រួម ឬដោយអភិបាលស្រុក ខណ្ឌ រួមមានការចាត់ចែងកិច្ចសន្យាសំខាន់ៗ រចនាសម្ព័ន្ធ និងប្រព័ន្ធ អំណាច និងមុខងារ ការចាត់ចែង ហិរញ្ញវត្ថុ និងថវិកា ព្រមទាំងបុគ្គលិក ។

ជំពូកទី ១០
អំពីមោឃភាពនៃដីកា ឬសេចក្តីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

ប្រការ ៤៧.-

ក្នុងករណីពិនិត្យឃើញថា សេចក្តីសំរេច ឬដីកាណាមួយរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ផ្ទុយនឹងរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ឬលិខិតបទដ្ឋាននានា អភិបាលខេត្ត ក្រុងត្រូវធ្វើសំណើជាបន្ទាន់មករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីប្រកាសមោឃៈភាពជាលាយលក្ខណ៍អក្សរដល់ក្រុមប្រឹក្សាឃុំ សង្កាត់សាមី និងផ្សព្វផ្សាយជាសាធារណៈ ។

ជំពូកទី ១១
អំពីអន្តរប្បញ្ញត្តិ

ប្រការ ៤៨.-

អភិបាលខេត្ត ក្រុងត្រូវធ្វើសេចក្តីរាយការណ៍ដល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអំពីឃុំ សង្កាត់ដែលពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីអនុវត្តនយោបាយវិមជ្ឈការ ដើម្បីធ្វើការកំណត់អំពីរបបគ្រប់គ្រងរដ្ឋបាលអន្តរកាលចំពោះឃុំ សង្កាត់នោះ បន្ទាប់ពីបានសំរេចយល់ព្រមដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

ការកំណត់របបគ្រប់គ្រងរដ្ឋបាលអន្តរកាលនេះ ត្រូវអនុវត្តដូចមាត្រា ៣៤ នៃប្រកាសនេះ ។

ជំពូកទី ១២

អំពីអវសានប្បញ្ញត្តិ

ប្រការ ៤៩.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៥០.-

ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០០២

សហរដ្ឋមន្ត្រី

ហត្ថលេខា **ហត្ថលេខា**

ស ខេង **យូ ហុកគ្រី**

ចម្លងជូន

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-សមាជិក "គ.ឃ.ស"
-ក្រសួងស្ថាប័នពាក់ព័ន្ធ
-សាលាខេត្ត ក្រុង
-ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ និងក្រសួងផែនការ
លេខ/[illegible]/[illegible] ប្រក

ប្រកាសអន្តរក្រសួង
ស្តីពី
ការកសាងផែនការអភិវឌ្ឍន៍
និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

****

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងផែនការ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងអនុក្រឹត្យលេខ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- យោងអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងអនុក្រឹត្យលេខ ២១៩ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

យោងអនុក្រឹត្យលេខ ១៥២ អនក្រ.បក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា១២នៃអនុក្រឹត្យ
ស្តីពីផែនការអភិវឌ្ឍន៍ និងការកំណត់តំបន់ក្រោមបណ្តាក្រុង ខេត្ត ក្រុង ស្រុក ឃុំ
យោងតាមការសម្រេចនៃកិច្ចប្រជុំ គ.ជ.អ.ប លើកទី៣ កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៩

សម្រេច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

ប្រការ ១..

ប្រកាសនេះ មានគោលការណ៍ណែនាំក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងការរៀបចំ អនុម័ត និង អនុវត្តផែនការអភិវឌ្ឍនី និងការកំណត់តំបន់ក្រោមបណ្តាក្រុងរបស់ខ្លួន ដោយមានការចូលរួម និងពិគ្រោះយោបល់ ជាមួយអង្គភាពពាក់ព័ន្ធទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ព្រមទាំងអនុវត្តតាមនីតិវិធីនៃការចេញប្រកាសស្តីពីការកសាង ផែនការអភិវឌ្ឍន៍ និងការកំណត់តំបន់ក្រោមបណ្តាក្រុងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រោមការចុះហត្ថលេខាដោយក្រសួងនៃប្រកាសអន្តរក្រសួង នេះ ។

ប្រការ ២..

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំផែនការអភិវឌ្ឍន៍រយៈពេលប្រាំ ០៥ ឆ្នាំ យ៉ាងយូរបំផុត នៅ ក្នុងឆ្នាំទី២នៃអាណត្តិរបស់ខ្លួន។ផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គឺជាឯកសារយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងជាមូលដ្ឋានសម្រាប់រៀបចំកម្មវិធីវិនិយោគរយៈពេល ០៣ ឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលទាមទារត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។

ប្រការ ៣..

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវពាន្យឱ្យបានថា ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ កម្មវិធីវិនិយោគ បីឆ្នាំរំកិល ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងគម្រោងវិនិយោគប្រចាំឆ្នាំរបស់ខ្លួន ត្រូវបានដាក់បញ្ចូលបង្កើតផែនការអភិវឌ្ឍន៍ និងថវិការបស់ក្រសួង ស្ថាប័ន អគ្គី អង្គភាព និងអ្នកពាក់ព័ន្ធនានា ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានីមួយៗ។

ប្រការ ៤..

ផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ត្រូវរៀបចំឡើងដោយផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំ រំកិលខណ្ឌ និងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគសង្កាត់នានាក្នុងដែនសមត្ថកិច្ចរបស់រាជធានី។

ផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ត្រូវរៀបចំឡើងដោយផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគសង្កាត់ នានាក្នុងដែនសមត្ថកិច្ចរបស់ក្រុង។

ប្រការ ៥..

ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលដែលគោនអនុម័តដោយក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គឺជាឯកសារផ្លូវការ ហើយក្រុមប្រឹក្សានីមួយៗត្រូវរៀបចំចាត់ចែងផ្សព្វផ្សាយឯកសារនេះជាសាធារណៈ និងដាក់បង្ហាញនៅក្នុង ដែនសមត្ថកិច្ចរបស់ខ្លួន។

ជំពូកទី២

យន្តការ និងការកំណត់ក្នុងការគាំទ្រដល់ការងារគ្រប់គ្រងធនធានធម្មជាតិ និងការអភិវឌ្ឍន៍ និងកម្មវិធីនិងគោលបំណងរបស់ក្រុម

ប្រការ ៦.

ដើម្បីលើកកម្ពស់ការគាំទ្រដល់ការងារគ្រប់គ្រងធនធានធម្មជាតិ និងការអភិវឌ្ឍន៍ ក្នុងក្របខ័ណ្ឌនៃច្បាប់ និងបទប្បញ្ញត្តិជាធរមាន ក្រុមប្រឹក្សាឃុំ ខេត្ត ក្រុង ស្រុក ខណ្ឌ មានភារកិច្ចសំខាន់ៗដូចខាងក្រោម :

- ត្រួតពិនិត្យ និងចូលរួមក្នុងដំណើរការគ្រប់គ្រងធនធានធម្មជាតិ និងការអភិវឌ្ឍន៍
- ពិនិត្យ និងអនុម័តផែនការគ្រប់គ្រងធនធានធម្មជាតិ និងការអភិវឌ្ឍន៍ និងកម្មវិធីនិងគោលបំណងរបស់ក្រុម
- ពិនិត្យ និងអនុម័តសេចក្តីព្រាងផែនការគ្រប់គ្រងធនធានធម្មជាតិ និងការអភិវឌ្ឍន៍ និងកម្មវិធីនិងគោលបំណងរបស់ក្រុម
- ពិនិត្យ និងអនុម័តផែនការអភិវឌ្ឍន៍ និងកម្មវិធីនិងគោលបំណងរបស់ក្រុម
- ពិនិត្យ និងអនុម័តសំណើកែតម្រូវផែនការអភិវឌ្ឍន៍ និងកម្មវិធីនិងគោលបំណងរបស់ក្រុម
- តាមដាន និងវាយតម្លៃជារៀងរាល់ឆ្នាំលើការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីនិងគោលបំណងរបស់ក្រុម

ប្រការ ៧.

ក្នុងដំណើរការគ្រប់គ្រងផែនការអភិវឌ្ឍន៍ និងកម្មវិធីនិងគោលបំណងរបស់ក្រុម គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាឃុំ ខេត្ត ក្រុង ស្រុក ខណ្ឌ មានភារកិច្ចសំខាន់ៗដូចខាងក្រោម :

- ចូលរួមក្នុងដំណើរការគ្រប់គ្រងផែនការអភិវឌ្ឍន៍ និងកម្មវិធីនិងគោលបំណងរបស់ក្រុម
- សម្របសម្រួលការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីនិងគោលបំណងរបស់ក្រុម
- ក្រៅពីភារកិច្ចខាងលើ គណៈកម្មាធិការសម្របសម្រួលរបស់ក្រុមប្រឹក្សាឃុំ ខេត្ត ក្រុង ស្រុក ខណ្ឌ មានភារកិច្ចពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ និងកម្មវិធីនិងគោលបំណងរបស់ក្រុម មុនធ្វើឱ្យក្រុមប្រឹក្សាធ្វើការពិនិត្យ និងអនុម័ត។

ប្រការ ៨.

ក្នុងដំណើរការគ្រប់គ្រងផែនការអភិវឌ្ឍន៍ និងកម្មវិធីនិងគោលបំណងរបស់ក្រុម គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន មានភារកិច្ចសំខាន់ៗដូចខាងក្រោម :

- ដឹកនាំ និងសម្របសម្រួលការងារគាំទ្រសេចក្តីព្រាងផែនការអភិវឌ្ឍន៍ និងកម្មវិធីនិងគោលបំណង ស្របតាមការណែនាំរបស់ក្រុមប្រឹក្សា ដោយសហការជាមួយភាគីពាក់ព័ន្ធនានា
- ដឹកនាំសិក្ខាសាលា និងវេទិកាផ្សេងៗទៀតនានា ក្នុងដំណើរការគាំទ្រដល់ការអភិវឌ្ឍន៍ និងកម្មវិធីនិងគោលបំណង។
- ដាក់ជូនក្រុមប្រឹក្សាពិនិត្យនិងអនុម័តសេចក្តីព្រាងផែនការអភិវឌ្ឍន៍ និងកម្មវិធីនិងគោលបំណង
- តាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីនិងគោលបំណង

ប្រការ ៩.

ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ក្រុមការងារកសាងផែនការរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានភារកិច្ចសំខាន់ៗដូចខាងក្រោម :

- ត្រៀមចំណេះដឹងក្នុងការជំរុញផ្តល់យោបល់ក្នុងការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ចូលរួមក្នុងការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ជីកន្លាំ និងសម្របសម្រួលដំណើរការកសាងសេចក្តីព្រាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ចូលរួមពិភាក្សាសាលា និងវេទិកាក្រុងរយៈពេលជាមួយភាគីពាក់ព័ន្ធនានា ក្នុងដំណើរការកសាងសេចក្តីព្រាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ត្រៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល

ប្រការ ១០.

ក្នុងដំណើរការកសាងសេចក្តីព្រាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ទីភ្នាក់ងារ និងការិយាល័យនានានៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានភារកិច្ចសំខាន់ៗដូចខាងក្រោម :

- ជួយក្រុមប្រឹក្សា និងគណៈអភិបាលក្នុងការដឹកនាំ និងសម្រាលសម្រួលដំណើរការកសាង អនុម័ត តាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- សហការជាមួយក្រុមការងារកសាងផែនការក្នុងការដឹកនាំ និងសម្របសម្រួលការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល

ចូលរួមវិភាគស្ថានភាពនិងពិគ្រោះយោបល់ក្នុងការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល

- សម្របសម្រួល និងចូលរួមការបណ្តុះបណ្តាលអំពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ។

ជំពូកទី៣

ដំណើរការកសាងផែនការអភិវឌ្ឍន៍

និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ប្រការ ១១.

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួន តាមរយៈដំណើរការដែលមានការចូលរួមនិងពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ ប្រភេទក្រុមប្រឹក្សាផ្សេងទៀត សាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មន្ទីរ អង្គភាពពាក់ព័ន្ធ អង្គការសង្គមស៊ីវិល វិស័យឯកជន និងអ្នកពាក់ព័ន្ធដែលជួយដល់ការងារផែនសមត្ថកិច្ចរបស់ខ្លួន។

ដើម្បីត្រៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រកបដោយគុណភាព និងត្រូវបានអនុម័តឱ្យប្រើប្រាស់ ដូចមានចែងក្នុងមាត្រា ៦ នៃអនុក្រឹត្យលេខ២១៩ ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ និងប្រតិទិនស្តីពីដំណើរការកសាងផែនការឱ្យបានល្អស់រលស់ ដោយផ្តោតលើអត្ថប្រយោជន៍ការងារតម្រង់ទិសដៅ ស្ថានភាពនៃរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគោលនយោបាយរបស់ជាតិ ។

គោលការណ៍ណែនាំផ្ទែកគោលនយោបាយរបស់ក្រុមប្រឹក្សា ត្រូវរៀបចំតាមរយៈដីកា ឬសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា។

ការចំណាយនានាសម្រាប់ការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល គឺត្រូវរាប់រងដោយថវិការបស់ក្រុមប្រឹក្សានីមួយៗ។

ប្រការ ១២..

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំរបស់ខ្លួន ដោយបញ្ចូលនូវខ្លឹមសារសំខាន់ៗមួយចំនួនដូចខាងក្រោម :

- **ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច :** រៀបរាប់ដោយសង្ខេបអំពីព័ត៌មានក្នុងស្ថានភាពរចុប្បន្ន និងបញ្ហាប្រឈមនានាដែលពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច សង្គមកិច្ច ការប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ការគ្រប់គ្រងគ្រោះមហន្តរាយ ការប្រែប្រួលអាកាសធាតុ និងស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាល
- **ក្របខ័ណ្ឌអភិវឌ្ឍន៍ :** រៀបរាប់ពីចក្ខុវិស័យ គោលដៅ គោលបំណង និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមនៃផែនការអភិវឌ្ឍន៍
- **ការតាមដាននិងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ :** រៀបរាប់អំពីអ្នកទទួលខុសត្រូវនិងអ្នកចូលរួមក្នុងការវាយតម្លៃ វិធីសាស្ត្រវាយតម្លៃ និងការរៀបចំរបាយការណ៍។

ប្រការ ១៣..

ក្នុងការកសាងផែនការអភិវឌ្ឍន៍ ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវយកចិត្តទុកដាក់លើសកម្មភាពសំខាន់ៗមួយចំនួនដូចខាងក្រោម :

- ការត្រៀមរៀបចំសម្រាប់ការកសាងផែនការអភិវឌ្ឍន៍
- ការផ្សព្វផ្សាយពត៌មានអំពីដំណើរការ និងនីតិវិធីសម្រាប់ការកសាងផែនការអភិវឌ្ឍន៍
- ការកសាងផែនការអភិវឌ្ឍន៍ តាមរយៈការវិភាគស្ថានភាព និងការរៀបចំក្របខ័ណ្ឌអភិវឌ្ឍន៍ និង
- ការអនុម័តផែនការអភិវឌ្ឍន៍

ប្រការ ១៤..

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួន ដោយបញ្ចូលនូវខ្លឹមសារសំខាន់ៗមួយចំនួនដូចខាងក្រោម :

- **ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច :** រៀបរាប់ដោយសង្ខេបអំពីព័ត៌មានសេដ្ឋកិច្ច សង្គមកិច្ច ក្នុងស្ថានភាពរចុប្បន្ន បញ្ហាប្រឈម និងតម្រូវការជាអាទិភាពរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- **គម្រោងនៃកម្មវិធីវិនិយោគបីឆ្នាំរំកិល :** រៀបរាប់អំពីគម្រោងវិនិយោគ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងផែនការសកម្មភាពសម្រាប់អនុវត្តគម្រោងឆ្នាំទី១នៃកម្មវិធីវិនិយោគបីឆ្នាំរំកិល។
- **ការតាមដាននិងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគ :** រៀបរាប់អំពីអ្នកទទួលខុសត្រូវ និងអ្នកចូលរួមក្នុងការវាយតម្លៃ វិធីសាស្ត្រវាយតម្លៃ និងការរៀបចំរបាយការណ៍។

ប្រការ ១៥..

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំកម្មវិធីនិងនីតិវិធីនៃការបោះឆ្នោតជ្រើសរើសប្រធាន ដោយផ្អែកលើវិធានការអភិវឌ្ឍខ្លួន។ កម្មវិធីនិងនីតិវិធីនៃការបោះឆ្នោតជ្រើសរើសប្រធាន ត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំរាល់ឆ្នាំ។ សារធាតុអាចសំខាន់ៗនៃនិយតកម្មវិធីនិងនីតិវិធីនៃការបោះឆ្នោតជ្រើសរើសប្រធាន :

- ការរៀបចំស្ថានភាព ដោយផ្តោតលើការកំណត់បញ្ហា និងតម្រូវការជាអាទិភាព
- ការរៀបចំកម្មវិធីនិងនីតិវិធីនៃការបោះឆ្នោតជ្រើសរើស
- ការអនុម័តកម្មវិធីនិងនីតិវិធីនៃការបោះឆ្នោតជ្រើសរើស

ប្រការ ១៦..

ក្រសួងមុខងារសាធារណៈត្រូវជួយក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងការរៀបចំព័ត៌មានស្តីពីវឌ្ឍនភាព នៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍សហគ្រាសកម្ពុជា តាមរយៈសាខាស្ថានភាពសេដ្ឋកិច្ច សង្គមរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងធានាឲ្យមូលដ្ឋានមាន សម្ភាព និងទិន្នន័យផ្សេងទៀតដែលពាក់ព័ន្ធនឹងការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីនិងនីតិវិធីនៃការបោះឆ្នោតជ្រើសរើសប្រធានរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

ប្រការ ១៧..

ក្រោយរយៈពេលដែលក្រុមប្រឹក្សារាជធានី ខេត្ត បានពិនិត្យ និងអនុម័តលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្តរួចហើយ គណៈអភិបាលរាជធានី ខេត្តត្រូវធ្វើការកែសម្រួលដោយផ្អែកតាមការសម្រេចរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ហើយដាក់ជូនអភិបាលរាជធានី ខេត្តនូវសេចក្តីព្រាងផែនការដែលបានកែសម្រួលនេះ ដើម្បីពិនិត្យ និងផ្ញើរបកទៅអាជ្ញាធរ ន.ជ.អ.ប។ អាជ្ញាធរ ន.ជ.អ.ប ត្រូវធ្វើការឆ្លងកម្លងសេចក្តីព្រាងនេះជូនក្រសួងមហាផ្ទៃ ក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងត្រូវធ្វើការសម្របសម្រួល ពិនិត្យ ពិគ្រោះយោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ជាមួយក្រសួងទាំងបីខាងលើនេះ ព្រមទាំងជាមួយស្ថាប័នពាក់ព័ន្ធនានា ដើម្បីពិនិត្យ និងផ្តល់យោបល់លើភាពស្របច្បាប់ និងសង្គតិភាពនៃផែនការនេះជាមួយគោលនយោបាយជាតិ ច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនានា។ ក្រោយពេលពិនិត្យ និងពិគ្រោះយោបល់រួចរាល់ហើយ អាជ្ញាធរត្រូវធ្វើកំណត់បង្ហាញសុំយោបល់មកសន្តិមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីពិនិត្យ និងផ្តល់អនុលោមភាព។ ការពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ត្រូវធ្វើឡើងក្នុងរយៈពេលមិនលើសពី៣០ថ្ងៃ គិតពីថ្ងៃដែលទទួលបានការស្នើសុំពិនិត្យ និងផ្តល់យោបល់របស់អភិបាលរាជធានី ខេត្ត។ រយៈពេល៣០ថ្ងៃនេះ រួមមានពេលវេលាចាំបាច់សម្រាប់ការពិគ្រោះយោបល់ជាមួយក្រសួង សាថាប័នពាក់ព័ន្ធនានា ការធ្វើទំនាក់ទំនងជាមួយអភិបាលរាជធានី ខេត្ត ដើម្បីស្រាយបំភ្លឺ និងឯកភាពលើបញ្ហាដែលមានការជំទាស់ពីក្រសួងមហាផ្ទៃលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត។

ក្នុងករណីមិនមានការឯកភាពគ្នារវាងអភិបាលរាជធានី ខេត្ត និងក្រសួងមហាផ្ទៃលើកិច្ចមតិយោបល់ក្នុងសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ក្រសួងមហាផ្ទៃត្រូវរាយការណ៍ និងស្នើសុំ ន.ជ.អ.ប ដើម្បីធ្វើការសម្រេចសម្រាប់ដោះស្រាយ។

ក្នុងរយៈពេលពាក់ថ្ងៃ បើគ្មានការឆ្លើយតបជាលាយលក្ខណ៍អក្សរពីក្រសួងមហាផ្ទៃឆ្ងើទៅអភិបាលរាជធានី ខេត្តទេ នោះសេចក្តីព្រាងផ្ទៃនការអភិវឌ្ឍន៍ ត្រូវចាត់ទុកថាទទួលបានអនុលោមភាពពីក្រសួងមហាផ្ទៃ ។

ប្រការ ១៨..

ក្រោយពេលដែលក្រមប្រឹក្សាក្រុង ស្រុក ខណ្ឌ បានពិនិត្យ និងអនុម័តលើសេចក្តីព្រាងផ្ទៃនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌរួចហើយ គណៈអភិបាលក្រុង ស្រុក ខណ្ឌត្រូវធ្វើការកែសម្រួលដោយផ្ទៃកតាមការសម្រេចរបស់ក្រមប្រឹក្សាក្រុង ស្រុក ខណ្ឌ ហើយដាក់ជូនអភិបាលក្រុង ស្រុក ខណ្ឌនូវសេចក្តីព្រាងផ្ទៃនការដែលបានកែសម្រួលនេះ ដើម្បីពិនិត្យ និងផ្ទៃជូនអភិបាលរាជធានី ខេត្ត ដើម្បីពិនិត្យ និងផ្តល់យោបល់លើភាពស្របច្បាប់ និងសង្គតិភាពនៃផ្ទៃនការនេះជាមួយគោលនយោបាយជាតិ ច្បាប់ និងលិខិតបទដ្ឋានទានា ។ អភិបាលរាជធានី ខេត្ត ត្រូវធ្វើការពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងផ្ទៃនការអភិវឌ្ឍន៍ក្នុងរយៈពេលពាក់ថ្ងៃ គិតពីថ្ងៃដែលទទួលបានការស្នើសុំពិនិត្យ និងផ្តល់យោបល់ដោយអភិបាលក្រុង ស្រុក ខណ្ឌ ដោយសហការយ៉ាងជិតស្មិទ្ធជាមួយមន្ទីរ អង្គភាពពាក់ព័ន្ធទានា ។ រយៈពេលពាក់ថ្ងៃនេះ រួមមានពេលវេលាចំណាកសេម្រាប់ការធ្វើទំនាក់ទំនងរវាងអភិបាលក្រុង ស្រុក ខណ្ឌ ជាមួយនិងអភិបាលរាជធានី ខេត្ត ដើម្បីស្រាយប់ភ្ជឹ និងឯកភាពលើយោបល់ដែលផ្តល់ដោយអភិបាលរាជធានី ខេត្ត លើសេចក្តីព្រាងផ្ទៃនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ ។

ក្នុងការណីមិនទានការឯកភាពត្រាវាងអភិបាលក្រុង ស្រុក ខណ្ឌ និងអភិបាលរាជធានី ខេត្ត អំពីខ្លឹមសារនៃសេចក្តីព្រាងផ្ទៃនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ អភិបាលរាជធានី ខេត្តត្រូវរាយការណ៍ និងស្នើសុំមកលេខាធិការដ្ឋាន ត.ជ.អ.ប ដើម្បីធ្វើការសម្របសម្រួលដោះស្រាយ ។

ក្នុងរយៈពេលពាក់ថ្ងៃ បើគ្មានការឆ្លើយតបជាលាយលក្ខណ៍អក្សរពីអភិបាលរាជធានី ខេត្តទៅក្រមប្រឹក្សាក្រុង ស្រុក ខណ្ឌទេ នោះសេចក្តីព្រាងផ្ទៃនការអភិវឌ្ឍន៍ ត្រូវចាត់ទុកថាទទួលបានអនុលោមភាពពីអភិបាលរាជធានី ខេត្ត ។

ក្នុងការពិនិត្យ និងផ្តល់យោបល់ទៅលើសេចក្តីព្រាងផ្ទៃនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ អភិបាលរាជធានី ខេត្ត ត្រូវពិចារណាអំពីភាពស្របច្បាប់ និងសង្គតិភាពនៃខ្លឹមសារផ្ទៃនការអភិវឌ្ឍន៍ទៅនឹងគោលនយោបាយជាតិ ច្បាប់ស្តីពីការក្រប់ក្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងលិខិតបទដ្ឋានតតិយុត្តពាក់ព័ន្ធទានា ។

ប្រការ ១៩..

គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំបោះពុម្ព បែងចែក ផ្សព្វផ្សាយជាសាធារណៈនូវផ្ទៃនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលបានអនុម័តដោយក្រមប្រឹក្សា និងតម្កល់ទុកទៅសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មន្ទីរផ្ទៃនការរាជធានី ខេត្ត ការិយាល័យផ្ទៃនការក្រុង ស្រុក ខណ្ឌ និងផ្ទៃទៅក្រសួងផ្ទៃនការ ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអ្នកពាក់ព័ន្ធដទៃទៀត ។

ប្រការ ២០..

ផ្ទៃនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងសម្មាប៉ាកែប្រែផ្ទៃនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវតែអនុម័តដោយសម្លេងលើសពីពាក់ត្រឹមពាក់នៃសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌទាំងមូល ។

ក្នុងការណីក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានរំសាយមុនអាណត្តិ យោងតាមរដ្ឋាបាល នៃច្បាប់

ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌថ្មី អាចទទួលយកផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលកំពុងមានទាំងស្រុង ឬអាចរៀបចំកែសម្រួលផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនោះ សម្រាប់រយៈពេលអាណត្តិដែលនៅសល់ ។

ជំពូកទី៤

ការអនុវត្តផែនការអភិវឌ្ឍន៍

និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ប្រការ ២១.

បន្ទាប់ពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលត្រូវបានអនុម័ត ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើការណែនាំឱ្យគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចាត់ចែងការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ដោយមានតម្លាភាព អានគណនេយ្យភាព មានការចូលរួម និងមានប្រសិទ្ធភាព ។

ប្រការ ២២.

អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តគម្រោង និងសកម្មភាពនានានៃផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ដោយអនុលោមតាមច្បាប់ បទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ដូចជាការធ្វើលទ្ធកម្មការងារសាងសង់ សម្ភារៈ ឬទំនិញ និងសេវាកម្មជាដើម ។ល។

ជំពូកទី៥

ការតាមដាន ការវាយតម្លៃ និងរបាយការណ៍

ប្រការ ២៣.

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើការណែនាំឱ្យអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ធ្វើការតាមដាននិងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ដោយរួមទាំងគម្រោងនិង សកម្មភាពនានារំដែលអនុវត្ត និងគ្រប់គ្រងក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាដោយ :

ប្រភេទក្រុមប្រឹក្សាដូចគ្នា

- ប្រភេទក្រុមប្រឹក្សាផ្សេងទៀត
- មន្ទីរ អង្គភាពនានា
- អ្នកពាក់ព័ន្ធផ្សេងទៀតដូចជា អង្គការសង្គមស៊ីវិល និងវិស័យឯកជននានា ។

ប្រការ ២៤.

គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើការវាយតម្លៃអំពីលទ្ធផល និងសមិទ្ធផលនៃអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលជារៀងរាល់ឆ្នាំ ប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងមានការចូលរួមពីអ្នកពាក់ព័ន្ធនានា ។

គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើការវាយតម្លៃអំពីលទ្ធផល សមិទ្ធផល និងឥទ្ធិពលលើការអនុវត្តផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងរយៈពេល០៦ខែចុងក្រោយនៃអាណត្តិរបស់ក្រុមប្រឹក្សា ប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងមានការចូលរួមពីអ្នកពាក់ព័ន្ធនានា ។

នីតិវិធីនៃការវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តតាមសេចក្តីណែនាំរបស់ គ.ជ.អ.ប។

ប្រការ ២៥.

នៅចុងឆ្នាំនីមួយៗ គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំរបាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត។ ខ្លឹមសាររបាយការណ៍នេះរួមមាន :

- វឌ្ឍនភាពការងារអនុវត្តក្នុងឆ្នាំកន្លងមក
- ទិសដៅការងារសម្រាប់អនុវត្តឆ្នាំខាងមុខ
- សេចក្តីសន្និដ្ឋានរួម។

ក្រៅពីរបាយការណ៍ប្រចាំឆ្នាំស្តីពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំរបាយការណ៍ផ្សេងទៀត ដើម្បីរាយការណ៍ជូនក្រុមប្រឹក្សាជាប្រចាំ។

ប្រការ ២៦.

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវអនុម័តរបាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល និងរបាយការណ៍ស្តីពីលទ្ធផលនៃការតាមដាន និងវាយតម្លៃ មិនឱ្យលើសពីសែសិបប្រាំ (៤៥) ថ្ងៃ អន្ទាប់ពីដំណាច់ឆ្នាំនីមួយៗ។

របាយការណ៍ប្រចាំឆ្នាំរបស់រាជធានី ខេត្ត ត្រូវផ្ញើជូនគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមរយៈប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្រសួងមហាផ្ទៃ ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងភាគីពាក់ព័ន្ធនានា។

របាយការណ៍ប្រចាំឆ្នាំរបស់ក្រុង ស្រុក ខណ្ឌ ត្រូវផ្ញើជូនអភិបាលរាជធានី ខេត្ត គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្រសួងមហាផ្ទៃ ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងភាគីពាក់ព័ន្ធនានា។

របាយការណ៍ប្រចាំឆ្នាំដែលបានអនុម័តដោយក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវតម្កល់ទុកនៅសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មន្ទីរ ការិយាល័យផែនការរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

ជំពូកទី៦

ការរៀបចំ និងការផ្សព្វផ្សាយសេចក្តីណែនាំស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ប្រការ ២៧.

ក្រសួងផែនការ និងជាប្រធានអនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ គ.ជ.អ.ប ត្រូវសហការជាមួយក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លេខាធិការដ្ឋាន គ.ជ.អ.ប ក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធនានា ដើម្បីរៀបចំផ្សព្វផ្សាយ និងណែនាំឱ្យប្រើប្រាស់នូវសេចក្តីណែនាំបច្ចេកទេសស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនេះ ស្របតាមខ្លឹមសារនិងសកម្មភាពសំខាន់ៗដូចមានចែងក្នុងប្រការ១៣ ប្រការ១៤ ប្រការ១៥ និងប្រការ១៦នៃប្រកាសនេះ។

ប្រការ ២៨..

ក្រសួងផែនការ និងជាប្រធានអនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិនៃ គ.ជ.អ.ប អាចធ្វើការកែសម្រួលនូវសេចក្តីណែនាំស្តីពីការកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តាមការចាំបាច់ បន្ទាប់ពីបានពិភាក្សាជាមួយក្រសួងមហាផ្ទៃ លេខាធិការដ្ឋាន គ.ជ.អ.ប និងអ្នកពាក់ព័ន្ធផ្សេងទៀត។

ប្រការ ២៩..

ក្រសួងផែនការនិងជាប្រធានអនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិនៃ គ.ជ.អ.ប ត្រូវសហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប និងអ្នកពាក់ព័ន្ធនានា ដើម្បីរៀបចំឯកសារ កម្មវិធីផ្សព្វផ្សាយ និងការបណ្តុះបណ្តាលដល់អ្នកពាក់ព័ន្ធទាំងអស់ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អំពីនីតិវិធីកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដូចមានក្នុងសេចក្តីណែនាំបច្ចេកទេសនេះ។

ជំពូកទី៧
អវសានបញ្ញត្តិ

ប្រការ ៣០..

ប្រកាសនេះ ពុំមានអធិកភាពលើប្រកាសអន្តរក្រសួងស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំសង្កាត់ឡើយ ប៉ុន្តែប្រកាសទាំងពីរមានទំនាក់ទំនងជាមួយគ្នាយ៉ាងជិតស្និទ្ធ ជាពិសេសសម្រាប់សង្កាត់ដែលស្ថិតក្នុងដែនសមត្ថកិច្ចរាជធានី និងសង្កាត់ស្ថិតក្នុងដែនសមត្ថកិច្ចក្រុង។

ប្រការ ៣១..

ប្រកាស និងសេចក្តីណែនាំទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសអន្តរក្រសួងនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៣២..

ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែ ៨ ឆ្នាំ២០១០

ទេសរដ្ឋមន្ត្រី	ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ	រដ្ឋមន្ត្រីក្រសួងផែនការ

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- សមាជិក "គ.ជ.អ.ប"
- ក្រសួង.ស្ថាប័នពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- សាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
  "ដើម្បីអនុវត្ត"
- ឯកសារ.កាលប្បវត្តិ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ:២៤០៥.ប.ក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ២០១៣

ប្រកាស
ស្តីពី
ការធ្វើប្រតិភូកម្មអំណាចដល់អភិបាលខេត្តក្នុងការផ្ទៀងផ្ទាត់ លិខិតអំណាចនានានៃសំណើសុំផ្តេរមូលនិធិក្រុង ស្រុក

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- យោងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងព្រះរាជក្រមលេខ នស/រកម/ ០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- យោងព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- យោងព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- យោងអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងអនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិក្រុង ស្រុក

- យោងអនុក្រឹត្យលេខ ១៧២ អនក្រ.បក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក

សម្រេច

ប្រការ ១.-

ត្រូវបានធ្វើប្រតិភូកម្មអំណាចដល់អភិបាលខេត្ត ក្នុងការផ្តៀងផ្ទាត់លិខិតទូទាត់នានានៃសំណើសុំផ្ទេរមូលនិធិក្រុង ស្រុកសម្រាប់ត្រីមាសទី២ ទី៣ និងទី៤នៃឆ្នាំនីមួយៗរបស់រដ្ឋបាលក្រុង ស្រុកដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខេត្តសាមី ដើម្បីបញ្ជូនសំណើសុំផ្ទេរមូលនិធិក្រុង ស្រុក មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ប្រការ ២.-

រដ្ឋបាលក្រុង ស្រុកត្រូវធ្វើសំណើសុំផ្ទេរមូលនិធិក្រុង ស្រុកសម្រាប់ត្រីមាសទី២ ទី៣ និងទី៤នៃឆ្នាំនីមួយៗដោយភ្ជាប់មកជាមួយនូវរបាយការណ៍ចំណូល ចំណាយថវិកាដែលបានអនុវត្តនៅត្រីមាសមុនៗ និងរបាយការណ៍ប៉ាន់ស្មានអនុវត្តចំណូល ចំណាយថវិកាសម្រាប់ត្រីមាសបន្ទាប់ ព្រមទាំងឯកសារគាំទ្រជាមូលដ្ឋានមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈអភិបាលខេត្តសាមី ដើម្បីធ្វើការផ្តៀងផ្ទាត់លិខិតទូទាត់នានានៃការផ្ទេរមូលនិធិក្រុង ស្រុក។

ប្រការ ៣.-

អភិបាលខេត្ត ដោយមានការគាំទ្របច្ចេកទេសពីមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត រតនាគារខេត្ត និងទីចាត់ការហិរញ្ញវត្ថុសាលាខេត្ត ត្រូវធ្វើការពិនិត្យផ្តៀងផ្ទាត់លិខិតទូទាត់នានានៃសំណើសុំផ្ទេរមូលនិធិក្រុង ស្រុក ដោយផ្អែកតាមនីតិវិធីដែលកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ក្នុងករណីដែលពិនិត្យឃើញថា សំណើរបស់ក្រុង ស្រុក មិនបំពេញបានតាមលិខិតទូទាត់ដែលបានកំណត់ អភិបាលខេត្តត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ក្រុង ស្រុកសាមី ដោយមានបញ្ជាក់អំពីមូលហេតុជាក់លាក់ និងការណែនាំច្បាស់លាស់អំពីចំណុចដែលត្រូវកែតម្រូវក្នុងរយៈពេលយ៉ាងយូរបំផុត ០៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីបានទទួលសំណើពីក្រុង ស្រុកនីមួយៗ។ បន្ទាប់ពីទទួលបានការជូនដំណឹងនេះ ក្រុង ស្រុកសាមីត្រូវពិនិត្យ និងកែតម្រូវនូវសំណើរបស់ខ្លួន រួចបញ្ជូនសំណើដែលបានកែតម្រូវនេះ មកអភិបាលខេត្តវិញ។

ក្នុងករណីដែលពិនិត្យឃើញថា សំណើរបស់ក្រុង ស្រុក បំពេញបានតាមលិខិតទូទាត់ដែលបានកំណត់ អភិបាលខេត្តត្រូវបញ្ជូនសំណើនោះមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងចម្លងជូនក្រសួងមហាផ្ទៃក្នុងរយៈពេលយ៉ាងយូរបំផុត០៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលសំណើពីក្រុង ស្រុកនីមួយៗ

ប្រការ ៤.-

អគ្គនាយកដ្ឋានកស្តុការ និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ ត្រូវសហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងស្ថាប័នពាក់ព័ន្ធនានាដើម្បីគាំទ្រ និងផ្តល់ការអភិវឌ្ឍន៍សមត្ថភាពដល់អភិបាលខេត្ត និងមន្ត្រីនៃអង្គភាពពាក់ព័ន្ធនានានៅថ្នាក់ខេត្ត ព្រមទាំងធ្វើការត្រួតពិនិត្យ តាមដាន និងវាយតម្លៃលើការអនុវត្តអំណាចដែលបានធ្វើប្រតិភូកម្មនេះ។

ប្រការ ៥.-

អគ្គនាយកដ្ឋានកស្តុការ និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធនានានៃក្រសួងមហាផ្ទៃ អភិបាលខេត្ត អភិបាលក្រុង ស្រុក ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ខេង

ទទួលផល ÷
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ទទួលការិយាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នជាសមាជិក គ.ជ.អ.ប
- ដូចប្រការ ៥
- ឯកសារ កាលប្បវត្តិ

"ដើម្បីជូនជ្រាប"
"ដើម្បីអនុវត្ត"

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង ផែនការ

ក្រសួងមហាផ្ទៃ

លេខ : ០៤៥ ប្រក.

ប្រកាសរួមក្រសួង
ស្តីពី
ការដាក់ឲ្យអនុវត្តន៍ស្រុកសំរោងទង និងស្រុកជើងព្រៃ
ស្ថិតក្នុងខេត្តកំពង់ចាម

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងផែនការ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងអនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- យោងអនុក្រឹត្យលេខ ២១៩ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- យោងអនុក្រឹត្យលេខ ១៥២ អនក្រ.បក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា១២ នៃអនុក្រឹត្យស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- យោងតាមស្មារតីកិច្ចប្រជុំលើកទី១៣របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កាលពីថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៧។

សម្រេច

ប្រការ ១..

ដាក់ឲ្យប្រើប្រាស់ "សេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងការកសាងផែនការអភិវឌ្ឍន៍រាជធានី"។

ប្រការ ២..

ក្រុមប្រឹក្សារាជធានី គណៈអភិបាលរាជធានី និងក្រុមការងារកសាងផែនការរាជធានីត្រូវរៀបចំ និងកសាងផែនការអភិវឌ្ឍន៍របស់ខ្លួនស្របតាមសេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍រាជធានីឲ្យមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងការចូលរួមពីប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា ដោយមានការយកចិត្តទុកដាក់លើបញ្ហាបរិយាប័ន្ធ សមធម៌សង្គម និងការប្រែប្រួលអាកាសធាតុ។

ប្រការ ៣..

ក្រសួងផែនការ ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការផ្តល់ការអភិវឌ្ឍសមត្ថភាព និងការគាំទ្រជល់រដ្ឋបាលរាជធានី ដើម្បីឲ្យរដ្ឋបាលរាជធានីមានសមត្ថភាពគ្រប់គ្រាន់ក្នុងការប្រើប្រាស់សេចក្តីណែនាំបច្ចេកទេសនេះ សម្រាប់ការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍របស់ខ្លួនប្រកបដោយប្រសិទ្ធភាព។

ប្រការ ៤..

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៥..

ក្រសួងផែនការ ក្រសួងមហាផ្ទៃ លេខាធិការដ្ឋាន គ.ជ.អ.ប ក្រុមប្រឹក្សា និងគណៈអភិបាលរាជធានី ត្រូវអនុវត្តប្រកាសអន្តរក្រសួងនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី..០២.. ខែ..មីនា.. ឆ្នាំ២០១៧...

ឧបនាយកដ្ឋមន្ត្រី	**ឧសដ្ឋមន្ត្រី**
ដ្ឋមន្ត្រីក្រសួងមហាផ្ទៃ	**ដ្ឋមន្ត្រីក្រសួងផែនការ**
សម្តេចក្រឡាហោម ស ខេង	**តាយ ថន**

កន្លងឧទ្ទេស
- ទីស្តីការគណៈដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋសភា
- នុទ្ធការិយាល័យសម្តេចនាយកដ្ឋមន្ត្រី
- នុទ្ធការិយាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយកដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- រាជកិច្ច
- ដ្ឋចប្រការ ៥
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង ផែនការ　　　　　　　　　　ក្រសួងមហាផ្ទៃ

លេខ : ០៧៩ ផក.

ប្រកាសអន្តរក្រសួង
ស្តីពី
ការដាក់ឱ្យប្រើប្រាស់សេចក្តីណែនាំបច្ចេកទេស
ស្តីពីការរៀបចំ និងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី

ឧបនាយករដ្ឋមន្ត្រី　　　　　　ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ　　　　　　រដ្ឋមន្ត្រីក្រសួងផែនការ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៥ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងអនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- យោងអនុក្រឹត្យលេខ ២១៩ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- យោងអនុក្រឹត្យលេខ ១៨២ អនក្រ.បក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា១៨ នៃអនុក្រឹត្យស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- យោងតាមស្មារតីកិច្ចប្រជុំលើកទី ១៣ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កាលពីថ្ងៃទី ០៤ ខែមករា ឆ្នាំ ២០១៧។

សម្រេច

ប្រការ ១..

ដាក់ឲ្យប្រើប្រាស់ "សេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី"។

ប្រការ ២..

ក្រុមប្រឹក្សារាជធានី គណៈអភិបាលរាជធានី និងក្រុមការងារកសាងផែនការរាជធានី ត្រូវរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួន ស្របតាមសេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានីឲ្យមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងការចុលរួមពីប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានាដោយមានការយកចិត្តទុកដាក់លើបញ្ហាបរិយាប័ន្ធ សមធម៌សង្គម និងការប្រែប្រួលអាកាសធាតុ។

ប្រការ ៣..

ក្រសួងផែនការ ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការផ្តល់ការអភិវឌ្ឍសមត្ថភាព និងការគាំទ្រជល់រដ្ឋបាលរាជធានី ដើម្បីឲ្យរដ្ឋបាលរាជធានីមានសមត្ថភាពគ្រប់គ្រាន់ក្នុងការប្រើប្រាស់សេចក្តីណែនាំបច្ចេកទេសនេះ សម្រាប់ការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។

ប្រការ ៤..

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៥..

ក្រសួងផែនការ ក្រសួងមហាផ្ទៃ លេខាធិការដ្ឋាន គ.ជ.អ.ប ក្រុមប្រឹក្សា និងគណៈអភិបាលរាជធានី ត្រូវអនុវត្តប្រកាសអន្តរក្រសួងនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៣.. ខែ.មីនា. ឆ្នាំ ២០១៧...

ឧបនាយកដ្ឋមន្ត្រី ដ្ឋមន្ត្រីក្រសួងមហាផ្ទៃ	ទេសដ្ឋមន្ត្រី ដ្ឋមន្ត្រីក្រសួងផែនការ
សម្តេចក្រឡាហោម ស ខេង	នាយ ថន

កន្លែងនុល
- ទីស្តីការគណៈដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានសភា
- ខុទ្ទការិយាល័យសម្តេចនាយកដ្ឋមន្ត្រី
- ខុទ្ទការិយាល័យសម្តេច ឯកឧត្តម ឡោកជំទាវ ឧបនាយកដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- រាជធានី
- ប៉ូលប្រការ ៥
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង ផែនការ

លេខ : ០៤៦ ក.ក.

ក្រសួងមហាផ្ទៃ

ប្រកាសរួមក្រសួង
ស្តីពី
ការជាក់ឯ្យប្រើប្រាស់សេចក្តីណែនាំបរមួកនេស
ស្តីពីការរៀបចំ និងការកសាងផែនការអភិវឌ្ឍន៍ខេត្ត

ឧបនាយកដ្ឋមន្ត្រី
ដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

នេសដ្ឋមន្ត្រី
ដ្ឋមន្ត្រីក្រសួងផែនការ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការត្រប់ត្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការត្រប់ត្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ការកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត និងក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងអនុក្រឹត្យលេខ ២១៩ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- យោងអនុក្រឹត្យលេខ ១៥២ អនក្រ.បក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការកែលម្រលម្រាត្រា១២ នៃអនុក្រឹត្យស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- យោងតាមស្មារតីកិច្ចប្រជុំលើកទី១៣របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កាលពីថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៧។

សម្រេច

ប្រការ ១..

ដាក់ឲ្យប្រើប្រាស់ "**សេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងការកសាងផែនការអភិវឌ្ឍន៍ខេត្ត**"។

ប្រការ ២..

ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត និងក្រុមការងារកសាងផែនការខេត្តត្រូវរៀបចំ និងកសាងផែនការអភិវឌ្ឍន៍របស់ខ្លួន ស្របតាមសេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ខេត្តឲ្យមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងការចូលរួមពីប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា ដោយមានការយកចិត្តទុកដាក់លើបញ្ហាបរិយាប័ន្ន សមធម៌សង្គម និងការប្រែប្រួលអាកាសធាតុ។

ប្រការ ៣..

ក្រសួងផែនការ ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការផ្តល់ការអភិវឌ្ឍសមត្ថភាព និងការគាំទ្រដល់រដ្ឋបាលខេត្ត ដើម្បីឲ្យរដ្ឋបាលខេត្តមានសមត្ថភាពគ្រប់គ្រាន់ក្នុងការប្រើប្រាស់សេចក្តីណែនាំបច្ចេកទេសនេះសម្រាប់ការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍របស់ខ្លួនប្រកបដោយប្រសិទ្ធភាព។

ប្រការ ៤..

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៥..

ក្រសួងផែនការ ក្រសួងមហាផ្ទៃ លេខាធិការដ្ឋាន គ.ជ.អ.ប ក្រុមប្រឹក្សា និងគណៈអភិបាលខេត្ត ត្រូវអនុវត្តប្រកាសអន្តរក្រសួងនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី.០៦.. ខែ..មីនា.. ឆ្នាំ២០១៧..

ឧបនាយករដ្ឋមន្ត្រី	**ឧសរដ្ឋមន្ត្រី**
រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ	**រដ្ឋមន្ត្រីក្រសួងផែនការ**
សុខ ខេង	**នាយ ចិន**

កន្លែងទទួល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋាននីតិកម្ម
- អគ្គលេខាធិការដ្ឋាន
- ទូទាត់ប័ណ្ណសម្គាល់ឧបនាយករដ្ឋមន្ត្រី
- ទូទាត់ប័ណ្ណសម្គាល់ ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ឧដ្ឋានីតិ
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង ផែនការ

ក្រសួងមហាផ្ទៃ

លេខ : ០៧៤ ប្រក

ប្រកាសអន្តរក្រសួង
ស្តីពី
ការដាក់ឲ្យប្រើប្រាស់សេចក្តីណែនាំបច្ចេកទេស
ស្តីពីការរៀបចំ និងការអនុវត្តវិនិយោគបីឆ្នាំរំកិលខេត្ត

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ឧសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងផែនការ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត និងក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងអនុក្រឹត្យលេខ ២១៩ អនក្រ.បក ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- យោងអនុក្រឹត្យលេខ ១៩២ អនក្រ.បក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា១២ នៃអនុក្រឹត្យស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- យោងតាមស្មារតីកិច្ចប្រជុំលើកទី១៣របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កាលពីថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៧។

សម្រេច

ប្រការ ១.

ដាក់ឲ្យប្រើប្រាស់ "សេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត"។

ប្រការ ២.

ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត និងក្រុមការងារកសាងផែនការខេត្ត ត្រូវរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួន ស្របតាមសេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្តឲ្យមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងការចូលរួមពីប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានាដោយមានការយកចិត្តទុកដាក់លើបញ្ហាបរិយាបន្ន សមធម៌សង្គម និងការប្រែប្រួលអាកាសធាតុ។

ប្រការ ៣.

ក្រសួងផែនការ ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការផ្តល់ការអភិវឌ្ឍសមត្ថភាព និងការតាំទ្រដល់រដ្ឋបាលខេត្ត ដើម្បីឲ្យរដ្ឋបាលខេត្តមានសមត្ថភាពគ្រប់គ្រាន់ក្នុងការប្រើប្រាស់សេចក្តីណែនាំបច្ចេកទេសនេះ សម្រាប់ការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។

ប្រការ ៤.

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៥.

ក្រសួងផែនការ ក្រសួងមហាផ្ទៃ លេខាធិការដ្ឋាន គ.ជ.អ.ប ក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្ត ត្រូវអនុវត្តប្រកាសអន្តរក្រសួងនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១៧

ឧបនាយករដ្ឋមន្ត្រី	**រដ្ឋមន្ត្រី**
រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ	**រដ្ឋមន្ត្រីក្រសួងផែនការ**
សរសើរ ក្រឹស្ណាហោម ស ខេង	**ង៉ាយ ថន**

កន្លែងទទួល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានប្រចាំខុសភា
- រដ្ឋលេខាធិការដ្ឋានសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- រាជធានី
